ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ប្រជាជនដែលមិនព្រមចាកចេញពីទីក្រុងភ្នំពេញ គឺជាខ្មាំង
- វាលវែង៖ អតីតតំបន់គស្ទឹរបស់មេដឹកនាំខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៣២ ខែមេសា ឆ្នាំ២០១៩

ស្វែងរកការពិត

លេខ២៣២ ខែមេសា ឆ្នាំ២០១៩

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ ការបង្រៀន «ប្រវត្តិសាស្ត្រខ្មែរក្រហមនៅកម្ពុជា១៩៧៥.............១

### ផ្នែកឯកសារ

◆ ឡុក ប៊ុន យុទ្ធជន រៀនបកប្រែភាសាចិននៅសហករណ៍ស៊ឹងហាវ... ៥

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង..................... ៧
◆ ប្រជាជនដែលមិនព្រមចាកចេញពីទីក្រុងភ្នំពេញ គឺជាខ្មាំង........១២
◆ ចម្រៀងបដិវត្តន៍ បានជួយជីវិតខ្ញុំ ....................................... ១៦
◆ វាលវែង៖ អតីតតំបន់តស៊ូរបស់មេដឹកនាំខ្មែរក្រហម...............២២
◆ តំបន់អន្លង់វែង គឺជាទីតាំងចុងក្រោយនៃជីវិតតស៊ូរបស់ខ្ញុំ.......... ២៦
◆ ខ្ញុំបានរួចរស់ជីវិត ដោយសារលាក់ប្រវត្តិរូប..........................៣០
◆ ការចងចាំប្រវត្តិសាស្ត្រ និងសិល្បៈតន្ត្រីខ្មែរ...........................៣៣

### ផ្នែកច្បាប់

◆ សេចក្ដីសង្ខេបសាលក្រមសំណុំរឿង០០២/០២..................... ៣៨

### វេទិកាពិភាក្សាសាធារណៈ

◆ ការលើកឡើងពីអតីតកាល គឺជាការផ្សះផ្សា......................... ៤៣
◆ ការសិក្សាស្វែងយល់ប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការ .......៤៧
◆ ភាពរីករាយ និងសោកនាដកម្មរបស់ប្រជាជនកម្ពុជា...............៤៨

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ គង់ មារតី ៖ ធនាគារិក................................................... ៥១
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៥
◆ អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ ................................................៥៩



ការសម្ដែងនិយាយទម្លាយភាពស្ងៀមស្ងាត់នៅខេត្តកំពង់ចាម
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ៣៧៥ ព.មប្រក
ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

***ស្នេរលេខនេះ៖*** *សូ ហ្វារីណា, ផាត ចាន់សុនិតា, សួត វិចិត្រ,សុខ វណ្ណៈ, ព្រាំ គិតម៉ាន់ និង ណុប សុវណ្ណឧត្ដម, វ៉ាន់ថាន់ ពៅដារ៉ា, ឡុងដានី* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *អ៊ុន សុដាវី និង ដារ៉ារដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ថុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ការបង្រៀន «ប្រវត្តិសាស្ត្រខ្មែរក្រហមនៅកម្ពុជា ១៩៧៥-១៩៧៩» និងការអប់រំពីអំពើប្រល័យពូជសាសន៍ គឺជាការទប់ស្កាត់អំពើប្រល័យពូជសាសន៍

ក្រសួងអប់រំយុវជន និងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបចំវគ្គបណ្ដុះបណ្ដាលសម្រាប់សាស្ត្រាចារ្យកម្រិតសាកលវិទ្យាល័យ ដែលផ្ដោតសំខាន់លើ «អំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក»។ ការជ្រើសយកខែមេសា ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាលនេះ គឺដើម្បីរំឭកការចងចាំអំពើកាប់សម្លាប់ និងអំពើប្រល័យពូជសាសន៍ដែលកើតមានជាសកល ដូចជា ប្រទេសអាមេនី អំពើប្រល័យពូជសាសន៍បានកើតឡើងនៅថ្ងៃទី២៤ខែមេសាឆ្នាំ១៩១៥ ប្រទេសកម្ពុជា កងទ័ពខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, ប្រទេសរ៉្វាន់ដា មានការសម្លាប់រង្គាលជនជាតិទុតស៊ី នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៤។ ខែមេសាទៀតសោត ត្រូវបានអង្គការសហប្រជាជាតិជ្រើសយកជាថ្ងៃរំឭកខួបអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលសម្រាប់ប្រទេសរ៉្វាន់ដា។ (លោកនាយក ឆាំង យុ ក៏ត្រូវបានអញ្ជើញចូលរួមកម្មវិធីនេះនៅប្រទេសរ៉្វាន់ដារ ប៉ុន្តែមិនអាចចូលរួមបានដោយសារមានកម្មវិធីនៅថ្ងៃនេះដែរ)។

វគ្គបណ្ដុះបណ្ដាលថ្ងៃនេះ មានការចូលរួមពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យចំនួន៥០រូប តំណាងឲ្យសកលវិទ្យាល័យចំនួន៥០ លោកនាយកគរុកោសល្យភូមិភាគទាំង៦



រូបរាប់ពីឆ្វេងទៅស្ដាំ៖ លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាស្ត្រាចារ្យ មីលតុន អស្បន អ្នកសរសេរសៀវភៅអំពើប្រល័យពូជសាសន៍នៅកម្ពុជា ចូលរួមជាគណអធិបតីនៅថ្ងៃបើកវគ្គបណ្ដុះបណ្ដាលស្ដីពី «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក នៅវិចិត្រសាលសហសម័យវិទ្យាស្ថានស៊ីករីត ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកគ្រូអ្នកគ្រូថ្នាក់ជាតិ លោកគ្រូអ្នកគ្រូដែលកំពុងសរសេរសាច់រឿងចេញពីភូមិ ព្រមទាំងវាគ្មិនជាតិ និងអន្តរជាតិដែលមានបទពិសោធន៍ជាច្រើនឆ្នាំ។ វគ្គបណ្តុះបណ្តាលនេះ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពជាច្រើនទៀត ដែលបានរៀបចំឡើងតាំងពីឆ្នាំ២០១០ ដែលក្រោយមកត្រូវបានស្នើឡើងជាគម្រោងសំណងនៃសំណុំរឿង០០២ វគ្គ២ ហើយទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គម្រោងសំណងនេះមានឈ្មោះថា «ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការបណ្តុះបណ្តាលលោកគ្រូអ្នកគ្រូ និងលោក លោកស្រីសាស្ត្រាចារ្យ»។ គម្រោងនេះទទួលបានការឧបត្ថម្ភជាថវិកាមកពីសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ។

នេះជាវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យលើកទី៣ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំយុវជន និងកីឡារៀបចំឡើង។ វគ្គបណ្តុះបណ្តាលពីរលើកមុនៗ ដែលមានការចូលរួមពីលោក-លោកស្រីសាស្ត្រចារ្យចំនួន ២០០នាក់ ផ្តោតលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) និងការបញ្ជ្រាបខ្លឹមសារប្រវត្តិសាស្ត្រ និងវិធីសាស្ត្របង្រៀនទៅក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រ មុខវិជ្ជាខេមរសិក្សា និងមុខវិជ្ជាភូមិវិទ្យានៅកម្រិតសាកលវិទ្យាល័យ ។

វគ្គបណ្តុះបណ្តាលដែលនឹងប្រព្រឹត្តិទៅនេះ គឺផ្តោតលើការសិក្សាបែបប្រៀបធៀបដោយមានការរួមបញ្ចូលប្រទេសយ៉ាងហោចណាស់ចំនួន៨ទៀតដែលធ្លាប់បានឆ្លងកាត់ជម្លោះអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាល ដែលស្រដៀងនឹងប្រទេសកម្ពុជាដែរ មានដូចជា ប្រទេសអាមេនី ប្រទេស



លោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យ វាគ្មិន បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ថត
ខែមេសា ឆ្នាំ២០១៩ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជ

អាល្លឺម៉ង់ ប្រទេសបូស្នី និងប្រទេសរ៉្វាន់ដា។ ប្រទេសអាមេនី ជាប្រទេសដំបូងដែលកើតមានអំពើប្រល័យពូជសាសន៍នៅក្នុងសតវត្សរ៍ទី២០គឺនៅឆ្នាំ១៩១៥ ប្រសិនបើគិតមកដល់បច្ចុប្បន្នគឺមានរយៈពេល ១០៤ឆ្នាំហើយ។

ប្រទេសទាំង៥នេះ លើកលែងតែប្រទេសអាមេនី គឺបាន និងកំពុងធ្វើការជំនុំជម្រះទោសអតីតមេដឹកនាំជាន់ខ្ពស់ទាំងឡាយដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលប្រជាជន ព្រមទាំងប្រើប្រាស់វិធីមួយចំនួនទៀតដើម្បីការចងចាំនិងផ្សះផ្សាជាតិ។ សៀវភៅបែបប្រៀបធៀបនេះ និពន្ធដោយអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងត្រួតពិនិត្យនិងកែសម្រួលដោយអ្នកជំនាញប្រវត្តិសាស្ត្រជាតិនិងអន្តរជាតិ។ សៀវភៅនេះទៀតសោត បាននឹងកំពុងត្រួតពិនិត្យ ដោយគណៈកម្មការស្រាវជ្រាវនិងកំណែ




រូបជុំគ្នានៅខាងមុខវិចិត្រសាលសហសម័យវិទ្យាស្ថានស្ទីករីត ថ្ងៃទី៣
ា)

ទម្រង់មុខវិជ្ជាប្រវត្តិសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលផ្នែកខ្លះទៅក្នុងមុខវិជ្ជាប្រវត្តិសាស្ត្រសកលលោក។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងធំៗចំនួន៤គឺ ៖

១) ពង្រីក និងពង្រឹងសមត្ថភាព លោកលោកស្រីសាស្ត្រាចារ្យ ដើម្បីអាចយកទៅបញ្ជ្រាប ឬបង្រៀនទាំងស្រុង នៅក្នុងកម្មវិធីបង្រៀននៅឯសកលវិទ្យាល័យឲ្យមានប្រសិទ្ធភាព

២) ស្វែងរកការដោះស្រាយសំណួរលំបាកៗមួយចំនួនដែលសួរជាញឹកញាប់។ ដូច្នេះ ការអញ្ជើញចូលរួមរបស់វាគ្មិនដែលធ្លាប់ធ្វើការស្រាវជ្រាវ ធ្លាប់ជួបហេតុការណ៍ផ្ទាល់ ឬជាសាមីប្រទេសផ្ទាល់ អាចបកស្រាយសំណួរទាំងនេះបាន

៣) ជំរុញឲ្យមានការទទួលស្គាល់ ការឈឺចាប់ ការទទួលរងរបស់ជនរងគ្រោះ និងកាត់បន្ថយអារម្មណ៍ឯកោ និងភាពជាជនរងគ្រោះតែម្នាក់ឯងរបស់ប្រជាជនកម្ពុជា ដោយសារមានមនុស្សជាច្រើនទៀត ដែលជាជនរងគ្រោះដោយអំពីប្រល័យពូជសាសន៍ និងការកាប់សម្លាប់ទ្រង់ទ្រាយធំ

៤) ជំរុញឲ្យមានការចងចាំ តាមរយៈការបង្រៀន ការពិភាក្សា ការចែករំលែកសាច់រឿងរបស់អ្នករស់រានមានជីវិត ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីចូលរួមទប់ស្កាត់ កុំឲ្យរបបខ្មែរក្រហមឬការកាប់សម្លាប់កើតមាននៅលើទឹកដីកម្ពុជា និងនៅក្នុងពិភពលោក។

លោកលោកស្រីសាស្ត្រាចារ្យនឹងទទួលបានចំណេះដឹងបន្ថែម ហើយចូលរួមពិភាក្សាយ៉ាងផុសផុល ដោយសារលោកលោកស្រីសាស្ត្រាចារ្យ មានបទពិសោធន៍បង្រៀនជាច្រើនឆ្នាំ ហើយធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមផ្ទាល់ ឬមានឪពុកម្តាយធ្លាប់ឆ្លងកាត់ និងទទួលរងគ្រោះក្រោមរបបខ្មែរក្រហម។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំយុវជន និងកីឡា នឹងនៅតែផ្តល់ការគាំទ្រផ្នែកឯកសារ និងបច្ចេកទេស

ប្រសិនបើលោកលោកស្រីសាស្ត្រាចារ្យ ត្រូវការនៅពេលបង្រៀន។

កម្មវិធីនេះគឺជាផ្នែកមួយនៃគម្រោងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលមានការសហការណ៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំយុវជន និងកីឡា។ កិច្ចការសំខាន់ៗជាច្រើនទៀតរួមមាន ៖

- ការបណ្តុះបណ្តាលលោកគ្រូអ្នកគ្រូថ្នាក់មូលដ្ឋានសម្រាប់មុខវិជ្ជាប្រវត្តិសាស្ត្រ សីលធម៌ពលរដ្ឋ ខេមរសិក្សា និងភូមិវិទ្យា និងតាមគរុកោសល្យភូមិភាគទាំង៦ ដែលរហូតមកដល់ពេលនេះគឺមានចំនួនប្រមាណជាង ៣០០០នាក់ មកពីខេត្តក្រុងក្នុងប្រទេសកម្ពុជា។
- ការបណ្តុះបណ្តាលគរុសិស្សនិស្សិត ប្រមាណជាង ២០០នាក់ ជារៀងរាល់ឆ្នាំ
- ការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រភូមិ
- ការបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារនៅតាមភូមិភាគ ដែលមានមូលដ្ឋាននៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦។ បច្ចុប្បន្ន គឺមានមជ្ឈមណ្ឌលឯកសារភូមិភាគបូព៌ា ខេត្តព្រៃវែង។
- វេទិកាអប់រំសាធារណៈ និងវេទិកាតាមថ្នាក់រៀន ដែលក្រុមការងារបានទៅដល់វិទ្យាល័យ៣៨រួចមកហើយ។
- ការដាក់តម្លើងពាក្យស្លោកទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅតាមវិទ្យាល័យនានា
- ការបន្ថែមព័ត៌មានអំពីព្រឹត្តិការណ៍ថ្មីៗ ទាក់ទងនឹងប្រវត្តិមេដឹកនាំខ្មែរក្រហម និងដំណើរវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ទៅក្នុងសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» និងការបោះពុម្ពសៀវភៅនេះឡើងវិញដើម្បីជួយសម្រួលដល់ការបង្រៀន និងរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩។

*សូ ហុរីណា*



*លោកគ្រូ-អ្នកគ្រូ និងសាស្ត្រាចារ្យចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រសកលលោក ពីថ្ងៃទី១ ដល់ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ នៅវិចិត្រសាលសហសម័យវិទ្យាស្ថានស្ទីករីត*

*(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ឡុក ប៊ុន យុទ្ធជន រៀនបកប្រែភាសាចិននៅសហករណ៍ស្ទឹងហាវ
## ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខD0៧១៣៤

ខ្ញុំឈ្មោះ ឡុក ប៊ុន អាយុ១៩ឆ្នាំ (ឆ្នាំ១៩៧៨) កើតនៅភូមិអង្គរជ័យទី២ ឃុំស្រែជា ស្រុកកំពង់ត្រាច តំបន់៣៥ ភូមិភាគនិរតី ខេត្តកំពត។ ខ្ញុំមានឪពុកឈ្មោះ ផាំង ចុង និង មានម្តាយឈ្មោះ លឹម ហ៊ុយ។ ខ្ញុំរស់នៅជាមួយជីដូនរបស់ខ្ញុំតាំងពីកុមារភាពមក ដោយគាត់មានមុខរបរជាអ្នកដាំម្រេច។ មុនឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ខ្ញុំមានតួនាទីជាគ្រូពេទ្យដើរព្យាបាលអ្នកជំងឺនៅតាមភូមិ។ នៅដើមឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំបានវិលត្រឡប់មកផ្ទះវិញ និងបានផ្តល់ដំបូន្មានមកកាន់ខ្ញុំថា «សូមកូនឯងកុំព្យាយាមធ្វើការខ្លាំងពេក ព្រោះពេលធ្លាក់ខ្លួនឈឺគ្មាននរណាមើលថែទេ»។ ក្រោយមក ឪពុកម្តាយខ្ញុំ បានរៀបចំបញ្ជូនខ្ញុំឲ្យទៅរស់នៅស្រុកយួនជាមួយអ្នកជិតខាងម្នាក់ឈ្មោះ ខ្ទឹង ប៉ុន្តែអង្គការមិនបានអនុញ្ញាតឲ្យខ្ញុំចេញទៅទីនោះទេ។ ខ្ញុំ និង ខ្ទឹង ក៏បានបន្តធ្វើការដាំដំឡូងនៅសហករណ៍ភូមិអង្គរជ័យទី២ជាមួយគ្នាតទៅទៀត។ នៅក្នុងអំឡុងពេលនោះ ខ្ទឹង បានណែនាំខ្ញុំថា «កុំសូវប្រឹងប្រែងធ្វើការខ្លាំងពេក ព្រោះរាល់ថ្ងៃនេះរបបអាហារដែលយើងទទួលបានមានការខ្វះខាត»។ ខ្ញុំក៏បានធ្វើតាមការណែនាំរបស់ខ្ទឹង រហូតមក។ ក្នុងខែធ្នូ ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងខ្ញុំ និង ខ្ទឹង ឲ្យទៅធ្វើការនៅកងចល័តលើកទំនប់នៅឃុំស្រែជា ស្រុកអង្គរជ័យ។ នាពេលនោះ ខ្ទឹង បានប្រាប់ខ្ញុំអំពីខ្សែបណ្តាញអ្នកខ្ជិលធ្វើការ នៅក្នុងកងចល័តជាច្រើនហូរហែ។ បួនប្រាំថ្ងៃក្រោយមក ខ្ទឹង បានណែនាំខ្ញុំឲ្យទៅជួបមនុស្សម្នាក់ឈ្មោះ ផន (ប្រធានក្រុមបះបោរឲ្យប្រជាជនខ្ជិលធ្វើការ)។ ពេលនោះ ផន បានណែនាំខ្ញុំឲ្យធ្វើការជាមួយបុរសម្នាក់ទៀតឈ្មោះ ធឿន។ ផន បានប្រាប់ខ្ញុំថា «គាត់មានខ្សែបណ្តាញទាក់ទងជាមួយបក្សពលករវៀតណាម ហើយថ្ងៃណាមួយគាត់នឹងនាំអ្នកនៅក្នុងក្រុមទាំងអស់ រត់ទៅនៅប្រទេសវៀតណាម»។ ផន និយាយបន្ថែមទៀតថា «នៅប្រទេសកម្ពុជាពិតជាពិបាករស់នៅខ្លាំងណាស់ ព្រោះពុំមានអាហារហូបចុកគ្រប់គ្រាន់ ហើយថែមទាំងត្រូវបានអង្គការប្រើឲ្យធ្វើការគ្មានពេលឈប់សម្រាក និងបំបិទសិទ្ធិសេរីភាពសព្វគ្រប់បែបយ៉ាង»។ ក្រោយមក ផន បានចាត់តាំងខ្ញុំ និងសមាជិកក្រុមផ្សេងទៀត ឲ្យធ្វើសកម្មភាពនានាដើម្បីបំផ្លាញអង្គការ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ផន បានចាត់តាំងខ្ញុំឲ្យទៅប្រាប់ម៉ែន ដែលជាជាងឈើនៅឃុំស្រែជា ក្នុងគោលបំណងឲ្យម៉ែន ទៅទាក់ទងអ្នករស់នៅភ្នំវល្លិ៍ ដែលមានចម្ងាយ៥គីឡូម៉ែត្រពីឃុំស្រែជា ដើម្បីចូលមកលួចដំឡូងពីឃុំនេះ។ បីថ្ងៃក្រោយមក មានប្រជាជនដែលរស់នៅភ្នំវល្លិ៍ចំនួន៣នាក់ បានចូលមកលួចដំឡូងនាពេលយប់។ មួយខែក្រោយមក ផន បានចាត់តាំងខ្ញុំឲ្យទៅលើកទំនប់ និងបានណែនាំខ្ញុំថា «ត្រូវធ្វើសកម្មភាពបំផ្លាញដងចប បង្គី ឲ្យរហែកបែកបាក់កុំឲ្យប្រើប្រាស់បាន»។ ប្រសិនបើមានបញ្ហាអ្វីកើតឡើង ផន គឺជាអ្នកដោះស្រាយ។ នៅខែកក្កដា ឆ្នាំ១៩៧៦ ផន បានបញ្ជូនខ្ញុំឲ្យមកស្ទូងស្រូវនៅសហករណ៍វិញ។ ផន ក៏បានណែនាំខ្ញុំ និង ធឿន ឲ្យធ្វើសកម្មភាពបំផ្លាញរនាស់ នង្គ័លរបស់សហករណ៍។ នៅខែតុលា ក្នុងឆ្នាំដដែល អង្គការបានបែងចែកឲ្យប្រជាជនម្នាក់ៗដាំដំឡូងមីឲ្យបានពីររងក្នុងមួយថ្ងៃ ដោយមួយរងៗមានបណ្តោយ២០ម៉ែត្រ។ អំឡុងពេលនោះ ដែរអង្គការក៏បានចាប់ខ្លួន សូ និង កង ដែលជាអ្នកធ្វើការក្នុងសហករណ៍ជាមួយខ្ញុំ។ ផន បានប្រាប់ខ្ញុំ និង ធឿន ឲ្យប្រុងប្រយ័ត្នក្នុងការធ្វើសកម្មភាពផ្សេងៗ និងបានបញ្ឈប់សកម្មភាពរបស់ខ្ញុំមួយរយៈ។

នៅខែមិថុនា ឆ្នាំ១៩៧៧ ផន បានចាត់តាំងខ្ញុំឲ្យទៅប្រាប់ សារួត នៅសហករណ៍អន្លង់ជ័យទី២ ដើម្បីពិនិត្យមើលផ្លូវទៅព្រំដែនយួន ថាតើមានប្រជាជនធ្វើការតាមផ្លូវដែរឬទេ។ បន្ទាប់មក សារួត បានត្រឡប់មករាយការណ៍ប្រាប់ ផន វិញថាមិនអាចរត់ទៅស្រុកយួនពេលនេះបានទេ ព្រោះមានប្រជាជនធ្វើការនៅតាមផ្លូវច្រើនណាស់។ នៅខែតុលា ក្នុងឆ្នាំដដែល ផន បានចាត់តាំង សារួត និង ធឿន ឲ្យទៅមើលផ្លូវម្តងទៀត។ នាពេលនោះ សារួត និង ធឿន ក៏បានទៅដល់ព្រំដែនយួន ប៉ុន្តែគ្មានប្រជាជននៅតាមផ្លូវដូចមុនទេ។ មួយខែក្រោយមក អ្នកទាំងពីរត្រូវបាន ផន ចាត់តាំងឲ្យទៅមើលផ្លូវម្តងទៀត ដោយគាត់បានផ្តាំថា ប្រសិនបើគ្មានអ្នកយាមតាមព្រំដែនទេ ធឿន ត្រូវចាកចេញទៅស្រុកយួនមុន ចំណែកឯ សារួត ត្រូវត្រឡប់មកវិញសិន។ អ្នកទាំងពីរបានធ្វើដំណើរទៅដល់ព្រំដែនយួន ក៏បានជួបប្រទះយោធាខ្មែរក្រហមដែលយាមតាមព្រំដែនជាច្រើននាក់។ ពេលនោះ យោធាខ្មែរក្រហមបានឃាត់ សារួត និង ធឿន ឲ្យឈប់ដើម្បីសាកសួរ ប៉ុន្តែអ្នកទាំងពីរនៅតែបន្តព្យាយាមរត់ចូលទៅក្នុងទឹកដីយួន ទើបត្រូវបានយោធាខ្មែរក្រហមបាញ់ស្លាប់ទាំងពីរនាក់។ ក្រោយមក អង្គការបានដកកងចល័តគ្រប់ឃុំ ក្នុងស្រុកកំពង់ត្រាចឲ្យទៅលើកទំនប់នៅកោះស្លា ប៉ុន្តែ ផន មិនបានទៅជាមួយពួកខ្ញុំទេ។ នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានត្រឡប់មកដឹកបាយណ៍នៅស្រុកកំពង់ត្រាចវិញ។ ពេលនោះ ខ្ញុំបានជួប នឹង ខ្ចីង។ ខ្ចីង បានប្រាប់ខ្ញុំថា «ផន ត្រូវបានអង្គការចាប់ខ្លួនតាំងពីពាក់កណ្តាលខែមករា ឆ្នាំ១៩៧៨ មកម្ល៉េះ»។

នៅខែមីនា ឆ្នាំ១៩៧៨ អង្គការបានចាត់ខ្ញុំឲ្យទៅរៀនបកប្រែភាសាចិន នៅសហករណ៍ស្ទឹងហាវ ខេត្តកំពង់សោម។ ខ្ញុំបាននៅក្នុងក្រុមបកប្រែភាសាចិន ដែលមាន ភួង ជាប្រធាន។ បន្ទាប់ពីស្នាក់នៅទីនោះបានប្រាំថ្ងៃ ភួង បានសួរខ្ញុំអំពីរបបអាហារថា «តើខ្ញុំទទួលបានរបបអាហារហូបចុកគ្រប់គ្រាន់ដែរឬទេ»? ពេលនោះខ្ញុំបានឆ្លើយប្រាប់ទៅគាត់វិញថា «ខ្ញុំទទួលរបបអាហារហូបមិនឆ្អែតទេ»។ នៅពេលដែល ភួង ឮដូច្នេះ គាត់ក៏បានប្រាប់ខ្ញុំឲ្យទៅលួចគាស់ពូជសាគូបារាំងយកទៅដុតហូប។ ក្រោយមក ខ្ញុំក៏បានអនុវត្តផែនការលួចគាស់ពូជសាគូបារាំងដុតហូបបាន៤ទៅ៥ដង ហើយក៏ត្រូវបានឈ្មោះ គង់ ដែលជាសមាជិកក្រុម រៀនបកប្រែភាសាចិន ប្រទះឃើញខ្ញុំកំពុងដុតសាគូហូប។ គង់ បានណែនាំខ្ញុំឲ្យឈប់ធ្វើសកម្មភាពបែបនេះតទៅទៀត ហើយខ្ញុំក៏បានយករឿងរ៉ាវទាំងនេះទៅប្រាប់ ភួង ឲ្យបានដឹងដែរ។ ភួង បានប្រាប់ខ្ញុំឲ្យលួចសាគូដុតហូបតទៅទៀត ប៉ុន្តែកុំឲ្យអ្នកណាឃើញឲ្យសោះ។ ខ្ញុំក៏បានទៅលួចគាស់សាគូយកមកដុតហូបដូចពេលមុនៗ ហើយ គង់ ក៏មកទាន់ខ្ញុំកំពុងដុតសាគូហូបម្តងទៀត។

រហូតដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ អង្គការបានបើកសន្និបាតរៀនសូត្រនៅកន្លែងធ្វើការរបស់ខ្ញុំ។ នាពេលនោះ គង់ ក៏បានលើកឡើងអំពីហេតុការណ៍ដែលធ្លាប់បានកើតឡើង ចំពោះបញ្ហាមានអ្នកលួចសាគូហូប ប៉ុន្តែគាត់មិនបានបញ្ចេញឈ្មោះរបស់ខ្ញុំទេ។ ក្រោយមក នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៨ អង្គការបានបញ្ជូនខ្ញុំឲ្យទៅធ្វើការខាងនីរសាក្រុងភ្នំពេញ។ មួយសប្តាហ៍ក្រោយមក អង្គការក៏បានស៊ើបដឹងអំពីសកម្មភាពក្បត់របស់ខ្ញុំកន្លងមក ហើយខ្ញុំក៏ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៨។

**ផាត ចាន់សុនិតា**

***កំណត់ចំណាំ៖*** *រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានឡើយថា ចម្លើយរបស់អ្នកទោស ឡុក ប៊ុន នេះពិតប្រាកដយ៉ាងណានោះទេ។*

# រឿងរ៉ាវរបស់ប្រជាជនចេញពីសហគមន៍អន្លង់វែង

(តពីលេខមុន)

*៨) រស់ យ៉ាន*

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមានអាយុប្រហែល ៣០ឆ្នាំ។ កាលនោះអង្គការបានចាត់តាំងខ្ញុំឲ្យធ្វើជាអ្នកដាំបាយ និងកិនស្រូវ។ ចំណែកឯប្ដីរបស់ខ្ញុំគឺជាជាងកាត់ដេរសម្លៀកបំពាក់សម្រាប់យោធា។ ប្ដីរបស់ខ្ញុំត្រូវកាត់ដេរសម្លៀកបំពាក់ជារៀងរាល់ថ្ងៃដោយមិនមានពេលឈប់សម្រាកឡើយ។ ពេលនោះ ខ្ញុំមានកូនចំនួន២នាក់ រស់នៅក្នុងស្រុកកំណើតនៅស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ នៅសម័យនោះ អង្គការចាត់តាំងប្រជាជនឲ្យហូប និងធ្វើការរួមគ្នា និងបំបែកមិនឲ្យនៅជុំក្រុមគ្រួសារឡើយ។ ចំណែករបបអាហារមានការខ្វះខាតយ៉ាងខ្លាំង បណ្ដាលឲ្យប្រជាជនស្លាប់អស់ជាច្រើននាក់ ជាពិសេសប្រជាជនថ្មី ឬ ប្រជាជន ១៧ មេសា ដែលជម្លៀសមកពីទីក្រុងភ្នំពេញ។ កូនរបស់ខ្ញុំម្នាក់បានស្លាប់ដោយសារមិនមានអាហារហូបគ្រប់គ្រាន់។

ប្រជាជនថ្មី ត្រូវបានអង្គការដាក់ឲ្យរស់នៅដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់។ អង្គការបានចែកអង្ករ១កំប៉ុងសម្រាប់មនុស្ស១០នាក់។ រាល់ការធ្វើបាប ការជិះជាន់ ធ្វើទុក្ខបុកម្នេញទាំងឡាយ អង្គការបានហាមប្រាមមិនឲ្យប្រជាជននិយាយឡើយ ប្រសិនបើនរណាម្នាក់ហ៊ាននិយាយនឹងមានទោសមិនខាន។ ដោយសារការរស់នៅជាសមូហភាព ដូច្នេះរាល់មាសប្រាក់ ទ្រព្យសម្បត្តិមានតម្លៃទាំងអស់ត្រូវបានអង្គការប្រមូលដាក់ជាទ្រព្យសម្បត្តិរួម។ ទ្រព្យសម្បត្តិរបស់ខ្ញុំត្រូវបានអង្គការប្រមូលយកទាំងអស់ ប៉ុន្តែទោះបីយ៉ាងណាខ្ញុំបានលាក់ទុកខ្លះដោយកប់នៅក្នុងដី។ សូម្បីតែដំណាំនៅក្នុងផ្ទះ ឬរបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ក៏ត្រូវបានអង្គការប្រមូលដាក់ជាកម្មសិទ្ធិរួមដែរ។ ចំណែកពេលវេលាធ្វើការងារ ប្រជាជនទាំងអស់ត្រូវធ្វើការពីព្រឹករហូតដល់ព្រលប់ ដោយសម្រាកតែពេលហូបអាហារតែប៉ុណ្ណោះ។ ក្មេងៗនៅសម័យនោះមួយចំនួនក៏ទទួលបានការរៀនសូត្រដែរ ការរៀនសូត្រនេះ គឺគ្រូបង្រៀនឲ្យក្មេងៗស្មោះត្រង់ និងបម្រើអង្គការតែប៉ុណ្ណោះ។ រីឯក្មេងមួយចំនួនទៀតពុំបានរៀនសូត្រទេដោយសារឈឺ និងគ្មានកម្លាំងកំហែង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឪពុកម្ដាយគ្មានសិទ្ធិវាយធ្វើបាប ឬអប់រំណែនាំកូនរបស់ខ្លួនឡើយ ព្រោះក្មេងៗ គឺជាកូនរបស់អង្គការ។ នៅសម័យនោះមានការខ្វះខាតអាហារយ៉ាងខ្លាំង ប៉ុន្តែប្រសិនបើនរណាម្នាក់ហ៊ានលួចអាហារ ឬដំណាំ អ្នកនោះនឹងត្រូវអង្គការយកទៅកសាងមិនខាន។ អ្នកដែលប្រព្រឹត្តខុសនឹងវិន័យ នឹងត្រូវអង្គការចាប់យកទៅព្រមាននៅមុខមហាជន និងគម្រាមកុំឲ្យអ្នកដទៃអនុវត្តតាម។

នៅក្នុងរបបខ្មែរក្រហម ការរៀបការត្រូវធ្វើឡើងពី២០ ទៅ៤០គូ ឬច្រើនជាងនេះ ហើយគូស្វាមីភរិយាថ្មីត្រូវធ្វើការប្ដេជ្ញាស្មោះស្ម័គ្របម្រើតែអង្គការប៉ុណ្ណោះ។ បន្ទាប់ពីប្ដីប្រពន្ធទាំងនោះឡើងចាប់អារម្មណ៍រួច អង្គការបានរៀបចំឲ្យហូបបាយជុំគ្នា រួចហើយឲ្យត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ។ ពិធីរៀបការក្នុងសម័យនោះ ត្រូវបានប្រជាជនហៅថា «ការចាប់អារម្មណ៍»។ ទោះបីយ៉ាងណា ប្រសិនបើកូនកំលោះ និងកូនក្រមុំស្រឡាញ់គ្នា គឺអាចស្នើសុំរៀបការជាមួយគ្នាបាន ដោយត្រូវជម្រាបទៅឪពុកម្ដាយទាំងសងខាង និងដាក់សំណើទៅអង្គភាពរៀងខ្លួន។ ប៉ុន្តែប្រសិនបើប្ដីប្រពន្ធថ្មីណាដែលអង្គការផ្សំផ្គុំហើយ ប៉ុន្តែមិនព្រមរួមរស់ជាមួយគ្នា នោះអង្គការនឹងយកទៅអប់រំ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ប្ដីប្រពន្ធខ្លះក៏បានលែងលះគ្នា ខ្លះទៀតបានរស់នៅជាមួយគ្នារហូតសព្វថ្ងៃ។

នៅពេលយប់ក្រុមគ្រួសារដែលទើបរៀបការរួចអាចជជែកគ្នាបាន ប៉ុន្តែហាមដាច់ខាតមិនឲ្យនិយាយអ្វីផ្ដេសផ្ដាស់

ទាក់ទងនឹងអង្គការឡើយ ប្រសិនបើឈ្លបលបស្តាប់ឮថា និយាយអាក្រក់ទាក់ទងនឹងអង្គការអ្នកនោះនឹងមានទោសមិនខាន។ ឈ្លបក្នុងសម័យនោះភាគច្រើនគឺជាក្មេងៗដែលជាកូនកសិករក្រីក្រ។ ចំពោះការព្យាបាលក្នុងសម័យនោះ គឺមានតែថ្នាំម្យ៉ាងដែលប្រជាជនទូទៅហៅថា «ថ្នាំអាចម៍ទន្សាយ»។ ទោះបីប្រជាជនមានជំងឺអ្វីក៏ដោយ ក៏ខ្មែរក្រហមឲ្យលេបថ្នាំនេះដែរ។ នៅក្នុងសម័យនោះ អង្គការមិនអនុញ្ញាតឲ្យមានព្រះសង្ឃ ការប្រតិបត្តិសាសនា និងមិនឲ្យមានពិធីបុណ្យទានឡើយ។ អង្គការវាយបំផ្លាញព្រះពុទ្ធរូប និងយកព្រះវិហារធ្វើជាកន្លែងឃុំឃាំង ផ្ទុកសម្ភារ គ្រាប់ និងអាវុធ។ ព្រះសង្ឃត្រូវបានអង្គការចាប់ផ្សឹក រួចចាត់តាំងឲ្យទៅធ្វើស្រែចម្ការ និងរស់នៅជាមួយគ្រួសាររៀងៗខ្លួន។

អង្គការ បានបែងចែកការងារឲ្យប្រជាជនធ្វើទៅតាមវ័យ។ កុមារត្រូវបានអង្គការចាត់ឲ្យទៅឃ្វាលគោ កាប់ដើមទន្ទ្រានខែត្រចិញ្ច្រាំធ្វើជី។ ប្រុសៗដែលពេញកម្លាំងត្រូវបានអង្គការចាត់តាំងឲ្យទៅលើកទំនប់ និងជីកប្រឡាយ។ ចំណែកយាយៗដែលមិនអាចធ្វើការងារធ្ងន់បាន ត្រូវនៅផ្ទះមើលចៅតូចៗ ហើយតាៗត្រូវទៅដេកយាមចម្ការ។ ប្តីប្រពន្ធពេលនោះអាចជួបគ្នាបាន ប៉ុន្តែត្រូវស្នើសុំការអនុញ្ញាតពីអង្គភាពជាមុនសិន។ រាល់ផលដំណាំដែលប្រជាជនបានដាំនៅតាមផ្ទះមិនអាចបេះយកមកហូបបានទេ បើហ៊ានបេះ អង្គការនឹងចោទថាជាចោរមិនខាន។

នៅពេលដែលកងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជា ដែលមានជំនួយពីកងទ័ពវៀតណាម បានវាយចូលប្រទេសកម្ពុជា នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អង្គការបានប្រមូលអ្នកទោសឲ្យជីករណ្តៅរួចហើយវាយអ្នកទាំងនោះទម្លាក់ចូលក្នុងរណ្តៅនោះតែម្តង។ នៅក្នុងស្ថានភាពច្របូកច្របល់នោះ ប្រជាជនមូលដ្ឋានបានរស់នៅក្នុងភូមិស្រុកដដែល រីឯប្រជាជនថ្មីក៏បានត្រឡប់ទៅរស់នៅស្រុកកំណើតរៀងៗខ្លួនវិញ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំមានសេរីភាពឡើងវិញ មានផ្ទះសម្បែង និងមានជីវភាពសមរម្យ។ ចំណែកវត្តអារាម ស្ពានថ្នល់ មន្ទីរពេទ្យ សាលារៀន ក៏មានសម្រាប់សិស្សានុសិស្សបានរៀនសូត្រដែរ។

សព្វថ្ងៃខ្ញុំមានអាយុ៧១ឆ្នាំ រស់នៅឃុំលំទង ស្រុកអន្លង់វែងខេត្តឧត្តរមានជ័យ ខ្ញុំរស់នៅបានសុខយ៉ាងណាក្តី ក៏អារម្មណ៍របស់ខ្ញុំនៅតែដក់ជាប់នូវរឿងរ៉ាវឈឺចាប់ ភាពអត់ឃ្លាន និងធ្វើការងារធ្ងន់ធ្ងរពីរបបខ្មែរក្រហមដែរ។

៩) ហ៊ួយ ណាក



ក្រុមនិស្សិតស្ម័គ្រចិត្តចុះសម្ភាសន៍ប្រជាជនក្នុងសហគមន៍អន្លង់វែង (រូបថត៖ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅមុនរបបខ្មែរក្រហមខ្ញុំរស់នៅក្នុងគ្រួសារកសិករមួយដែលមានជីវភាពសមរម្យ នៅក្នុងភូមិពាម ឃុំព្រែកក្របៅ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ខ្ញុំមានវ័យ១៥ឆ្នាំ នៅពេលយោធាខ្មែរក្រហមបានទទួលជ័យជម្នះលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ប្រហែលជាពីរទៅបីម៉ោងក្រោយរំដោះបានទីក្រុងភ្នំពេញ យោធាខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅរស់នៅតាមតំបន់ជនបទដោយយកលេសថា ខ្លាចកងទ័ពអាមេរិកមកទម្លាក់គ្រាប់។ ប្រជាជនដែលរស់នៅក្នុងទីក្រុងទាំងអស់បានបង្ខំចិត្តចាកចេញពីផ្ទះសម្បែងរបស់ខ្លួនដោយបានរៀបចំសម្ភារ និង

អាហារបន្តិចបន្តួចទៅតាមខ្លួន ហើយបានធ្វើដំណើរដោយថ្មើរជើងទៅតាមទិសដៅរៀងៗខ្លួន។ នៅពេលនោះ អ្នកទីក្រុងដែលមានបងប្អូនរស់នៅតាមទីជនបទមានភាពងាយស្រួលក្នុងការពឹងពាក់ស្នាក់អាស្រ័យជាមួយ ប៉ុន្តែសម្រាប់ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញ ហើយគ្មានបងប្អូនរស់នៅតាមទីជនបទវិញ គឺពិតជាជួបការលំបាកយ៉ាងខ្លាំងក្នុងការស្វែងរកកន្លែងសម្រាប់ស្នាក់នៅ។

ខ្មែរក្រហមបានប្រមូលទ្រព្យសម្បត្តិផ្ទាល់ខ្លួន ពីប្រជាជនដែលជម្លៀសថ្មីទាំងអស់យកទៅដាក់ជាទ្រព្យសម្បត្តិរួម និងបែងចែកឲ្យប្រជាជនថ្មីរស់នៅក្នុងសហករណ៍។ ភូមិនីមួយៗមានសហករណ៍ពីរទៅបីកន្លែង អាស្រ័យទៅតាមចំនួនប្រជាជនដែលរស់នៅក្នុងភូមិនោះ។ នៅក្នុងផ្ទះរបស់ប្រជាជនមិនមានរបស់របរអ្វីសំខាន់ឡើយ គឺមានតែកំសៀវទឹកចាស់មួយតែប៉ុណ្ណោះ។ ខ្ញុំនិងប្រជាជនដទៃទៀត ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យដាំដំណាំ លើកទំនប់ លើកភ្លឺស្រែនិងជីកប្រឡាយ។ ប្រជាជនម្នាក់ៗត្រូវជីកដីឲ្យបាន៣ម៉ែត្រគូបក្នុងមួយថ្ងៃ ទើបអាចឈប់សម្រាកបាន។ ដោយសារតែការភ័យខ្លាច ខ្ញុំបានខិតខំតស៊ូប្រឹងប្រែងធ្វើការងាររហូតសម្រេចទៅតាមផែនការរបស់អង្គការ។ ចំណែករបបអាហារដែលអង្គការចែកឲ្យប្រជាជន គឺមានតែបបររាវៗដែលស្ទើរតែគ្មានគ្រាប់អង្ករលាយជាមួយបណ្តូលចេក ដូចជាបបរសម្រាប់សត្វជ្រូក។

រៀងរាល់ថ្ងៃ ខ្ញុំខិតខំប្រឹងប្រែងធ្វើការងារយ៉ាងទៀងទាត់ ព្រោះខ្ញុំមានប្រវត្តិជាអ្នកស្រែចម្ការ ប៉ុន្តែអ្នកដែលធ្លាប់រស់នៅក្នុងទីក្រុង ពិតជាជួបការលំបាកខ្លាំងណាស់ ពីព្រោះអ្នកទាំងនោះពុំធ្លាប់នឿយហត់ពីមុនមក។ អ្នកខ្លះដែលមិនអាចទ្រាំនឹងស្ថានភាពលំបាកបែបនេះបានក៏ធ្លាក់ខ្លួនឈឺ។ អ្នកដែលមានជំងឺនៅសម័យនោះ មិនមានគ្រូពេទ្យមើលថែទាំ និងមានថ្នាំលេបគ្រប់គ្រាន់ឡើយ គឺមានតែថ្នាំមួយប្រភេទដែលប្រជាជនហៅថា «ថ្នាំអាចម៍ទន្សាយ» តែប៉ុណ្ណោះ ហើយទាល់តែអ្នកជំងឺទើបមានសិទ្ធិទៅសុំថ្នាំនេះលេបបាន។

ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងធ្វើការ ខ្ញុំឃើញឈ្លបខ្មែរក្រហមបររទេះសេះមកដឹកប្រជាជនចេញទៅបាត់ៗ ប៉ុន្តែប្រជាជនដែលឡើងជិះរទេះសេះនោះ មិនបានត្រឡប់មកភូមិវិញទេ។ ក្រោយពីបានឃើញហេតុការណ៍នេះ ខ្ញុំភ័យខ្លាចយ៉ាងខ្លាំង និងតែងតែលួចគិតក្នុងចិត្តថា ថ្ងៃណាមួយខ្ញុំនឹងត្រូវឈ្លបខ្មែរក្រហមយកទៅដែរមិនខាន។ នៅឆ្នាំ១៩៧៨ ខ្ញុំបានឮថាមានការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលគាំទ្រពីកងទ័ពវៀតណាម ធ្វើឲ្យខ្ញុំរីករាយយ៉ាងខ្លាំង។ រយៈពេលពីរខែក្រោយមក កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំដោះប្រជាជនចេញពីរបបខ្មែរក្រហម ពេលនោះខ្ញុំក៏បានវិលត្រឡប់មកស្រុកកំណើតដើម្បីជួបជុំគ្រួសារ ប៉ុន្តែមិនបានឃើញបងប្អូនវិលត្រឡប់មកវិញឡើយ។ អស់រយៈពេលជាច្រើនឆ្នាំក្រោយមក ក៏ខ្ញុំមិនបានទទួលដំណឹងពីបងប្អូនរបស់ខ្ញុំដែរ ដូច្នេះខ្ញុំនិងឪពុកម្តាយក៏សម្រេចចិត្តមករស់នៅភូមិគោកសំព័រ ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតមកដល់សព្វថ្ងៃ។

១០) ព្រាប សាខន



បុរសម្នាក់នៅក្នុងសហគមន៍អន្លង់វែងកំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមនិស្សិតស្ម័គ្រចិត្ត (រូបថតៈ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឪពុកម្តាយខ្ញុំជាកសិករដែលមានជីវភាពមធ្យម នៅភូមិតាសេក ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង នៅមុន

ពេលប្រទេសធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិល។ ខ្ញុំគឺជាកូនស្រីទី៣មានបងប្អូនបង្កើតចំនួន៥នាក់ (ប្រុសបីនាក់ និងស្រីពីរនាក់) តាំងពីខ្ញុំធំដឹងក្តី ខ្ញុំមិនដែលបានរៀនសូត្រឡើយ។

ខ្ញុំបានជួបនូវព្រឹត្តិការណ៍ទម្លាក់គ្រាប់បែកជាច្រើនលើកនៅស្រុកកំណើត។ ពេលខ្លះគ្រាប់បែកបានធ្លាក់មកនៅពេលដែលខ្ញុំកំពុងធ្វើស្រែ។ នៅថ្ងៃមួយពេលខ្ញុំកំពុងឃ្វាលក្របី ខ្ញុំបានឃើញយន្តហោះទម្លាក់គ្រាប់បែក និងមានផ្សែងយ៉ាងខ្មួរខ្មាញ់។ ការទម្លាក់គ្រាប់នោះគឺសំដៅទៅលើជម្រករបស់កងទ័ពវៀតកុង (វៀតណាមខាងជើង) ភូមិរបស់ខ្ញុំពេលខ្លះក៏ធ្លាក់ចំដែរ។

ពេលខ្មែរក្រហមវាយដណ្តើមបានជ័យជម្នះពីកងទ័ព លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុ ២៣ឆ្នាំ។ ពេលនោះប្រជាជនកម្ពុជាទូទាំងប្រទេសបានគិតថាសង្គ្រាមបានបញ្ចប់ ដូច្នេះនឹងមានសន្តិភាពមិនខាន។ ប៉ុន្តែប្រហែលជារយៈពេល៣ម៉ោងក្រោយរំដោះ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីផ្ទះសម្បែង ដោយយកលេសថាខ្លាចកងទ័ពអាមេរិកមកទម្លាក់គ្រាប់បែក។ ប្រជាជនទាំងនោះយកបានតែសម្ភារ និងស្បៀងអាហារបន្តិចបន្តួចតែប៉ុណ្ណោះនៅតាមខ្លួន រួចហើយបានធ្វើដំណើរដោយថ្មើរជើង និងគ្មានទិសដៅច្បាស់លាស់។ នៅពេលទៅដល់ភូមិ ខ្មែរក្រហមបានប្រមូលយកសម្ភារ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ប្រ-ជាជនថ្មីនោះទៅដាក់ជាសម្បត្តិរួមរបស់សហករណ៍។

នៅឆ្នាំ១៩៧៦ ក្រុមគ្រួសារខ្ញុំ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅភូមិអំពិល ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង។ នៅពេលនោះ ខ្មែរក្រហមបានរៀបចំឲ្យមានសហករណ៍ ២ឬ៣កន្លែង នៅក្នុងភូមិនីមួយៗ ដោយអាស្រ័យទៅតាមចំនួនប្រជាជននៅក្នុងភូមិនោះ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យលើកភ្លឺស្រែ ជីកប្រឡាយ លើកធ្វើប្រព័ន្ធធារាសាស្ត្រស្តុកទឹកស្រោចដំណាំ។ ខ្ញុំចាប់ផ្តើមចេញទៅធ្វើការនៅម៉ោង៧ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ និងចាប់ផ្តើមធ្វើការបន្តចាប់ពីម៉ោង១រសៀល រហូតដល់ម៉ោង៥។ ពេលនោះដំណាំដែលខ្ញុំដាំក្នុងបរិវេណផ្ទះ ក៏មិនអាចបេះហូបខ្លួនឯងបានដែរ។ ប្រសិនបើខ្ញុំហ៊ានបេះ ខ្ញុំនឹងមានទោសមិនខាន។ បងប្រុសរបស់ខ្ញុំម្នាក់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ដោយសារគាត់គឺជាអតីតទាហាន លន់ នល់។ ទោះជាយ៉ាងណា ខ្មែរក្រហមមិនបានសង្ស័យលើក្រុមគ្រួសាររបស់ខ្ញុំឡើយ។ ខ្ញុំធ្លាប់តែឮពាក្យថា «អង្គការ» ប៉ុន្តែខ្ញុំមិនបានដឹងថាអង្គការជានរណាពិតប្រាកដឡើយ។

នៅក្នុងឆ្នាំ១៩៧៦ ដដែល ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការជាមួយបុរសម្នាក់។ ពេលនោះខ្ញុំបានប្រកែក និងប្រាប់ខ្មែរក្រហមថា បុរសដែលខ្ញុំត្រូវរៀបការជាមួយនោះ គឺជាបងប្អូនរបស់ខ្ញុំដែលរស់នៅភូមិព្រៃកន្ទោត។ មិនយូរប៉ុន្មានខ្ញុំនិងក្រុមគ្រួសារត្រូវបានជម្លៀសបន្តទៅនៅឃុំសំបួរ ស្រុករមាសហែក ខេត្តស្វាយរៀង។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការងារនៅក្នុងកងចល័ត និងត្រូវរស់នៅឆ្ងាយពីឪពុកម្តាយ។

នៅឆ្នាំ១៩៧៨ ម្តាយរបស់ខ្ញុំបានស្លាប់ដោយសារជំងឺ និងមិនមានថ្នាំសម្រាប់ព្យាបាល។ ក្រោយម្តាយខ្ញុំស្លាប់ ខ្ញុំបានប្រកែកមិនទៅធ្វើការងាររយៈពេល៧ថ្ងៃ។ នៅក្នុងសម័យកាលនោះ ប្រសិនបើនរណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ជាថ្នាក់លើ អ្នកនោះនឹងត្រូវចោទថាជាក្បាល់ការរបស់យួន ហើយអាចមានទោសប្រហារជីវិតមិនខាន។ ប៉ុន្តែសំណាងល្អខ្ញុំមិនបានជាប់ទោស។

បន្ទាប់ពីកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលគាំទ្រដោយកងទ័ពវៀតណាមបានទទួលជ័យជម្នះលើខ្មែរក្រហម នៅឆ្នាំ១៩៧៩ ខ្ញុំក៏បានវិលត្រឡប់មកភូមិតាសេក ឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀងវិញ។ ប៉ុន្តែខ្ញុំមិនបានជួបជុំបងប្អូនរបស់ខ្ញុំទេ។ ក្រោយមកនៅឆ្នាំ១៩៨០ ខ្ញុំបានរៀបការជាមួយបុរសម្នាក់តាមការរៀបចំផ្សំផ្គុំពីបងប្អូន។ មកដល់ឆ្នាំ២០១៦ ខ្ញុំជាមួយនឹងកូនប្រុសបានផ្លាស់មករស់នៅអន្លង់វែង រហូតដល់សព្វថ្ងៃ។

*សម្ភាសន៍ដោយនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង*

*រៀបរៀងអត្ថបទដោយ៖ សោម ប៊ុនថន*

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង សុង ថាណៃ តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truththanay.s@dccam.org។












# ប្រជាជនដែលមិនព្រមចាកចេញពីទីក្រុងភ្នំពេញ គឺជាខ្មាំង

ព្រឹកព្រលឹមស្រាងៗ យោធាខ្មែរក្រហមជាមួយនឹងសម្លៀកបំពាក់ពណ៌ខ្មៅ ថែមទាំងមាន កាន់កាំភ្លើងនៅជាប់នឹងដៃបានបើកទ្វាចូលមកក្នុងសណ្ឋាគារដែលខ្ញុំកំពុងតែធ្វើការនៅក្នុងទីក្រុងភ្នំពេញ ហើយបានប្រាប់ឲ្យខ្ញុំចាកចេញពីទីក្រុងភ្នំពេញត្រឡប់ទៅកាន់ស្រុកកំណើតវិញៗ ចំណែកឯជនបរទេសដែលស្នាក់នៅក្នុងសណ្ឋាគារត្រូវបានយោធាខ្មែរក្រហមតម្រូវឲ្យទៅជួបជុំគ្នានៅក្នុងស្ថានទូតស្ថិតនៅក្បែរវត្តភ្នំៗ ប្រសិនបើនរណាមិនព្រមចាកចេញពីទីក្រុងទេ អ្នកនោះគឺជាខ្មាំងរបស់បដិវត្តន៍ និងត្រូវសម្លាប់ៗ

ខ្ញុំ បានផ្លាស់មករស់នៅទីក្រុងភ្នំពេញ បន្ទាប់ពីការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចនរោត្តម សីហនុ និងការឡើងកាន់កាប់អំណាចរបស់ លន់ នល់ នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧០ៗ មកដល់ទីក្រុងភ្នំពេញដំបូង ខ្ញុំបានស្នាក់នៅក្នុងផ្ទះវីឡា១នៅម្ដុំបឹងកេងកងដែលម្ដាយឪពុករបស់ខ្ញុំបានទិញទុកយូរណាស់មកហើយៗ ខ្ញុំ ក៏បានចាប់ផ្ដើមធ្វើការងារគឺជាអ្នកទទួលភ្ញៀវនៅក្នុងសណ្ឋាគារឈ្មោះ ខេមរា ស្ថិតនៅខាងលិចផ្សារធំថ្មីៗ ខ្ញុំបានធ្វើការចាប់ពីម៉ោង ២រសៀល ដល់ម៉ោង៩យប់ ជារៀងរាល់ថ្ងៃ និងតែងតែត្រឡប់មកសម្រាកនៅផ្ទះនៅពេលយប់ៗ ចំណែកឯប្រពន្ធរបស់ខ្ញុំនៅចាំផ្ទះ និងមើលថែរក្សាកូនៗៗ រយៈពេលប្រហែល១០ថ្ងៃមុនពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ នៅក្នុងទីក្រុងភ្នំពេញគឺឮស្នូរគ្រាប់ផ្លោងលាន់រំពងជាងសព្វដងដោយសារមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហមៗ ប្រជាជនមិនហ៊ានចាកចេញពីផ្ទះឡើយៗ នៅក្នុងសណ្ឋាគារមានភ្ញៀវបរទេសស្នាក់នៅប្រហែល៣០បន្ទប់ ដែលភាគច្រើនគឺជាអ្នកការសែត និងមន្ត្រីទូតៗ ថ្ងៃមួយ ការប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហមនិងទាហាន លន់ នល់ បានផ្ទុះឡើងយ៉ាងខ្លាំង សមាជិកគ្រួសាររបស់ខ្ញុំបានរត់ចូលទៅក្នុងលេណដ្ឋានដែលយើងបានធ្វើបម្រុងទុករួចជាស្រេចៗ ការប្រយុទ្ធគ្នាពីមួយថ្ងៃទៅមួយថ្ងៃកាន់តែខ្លាំងទៅៗ ខ្ញុំក៏សម្រេចចិត្តយកប្រពន្ធ កូន២នាក់ និងប្អូនប្រុស២នាក់របស់ខ្ញុំ ទៅស្នាក់នៅក្នុងសណ្ឋាគារជាមួយគ្នាអស់រយៈពេលប្រហែល៤យប់មុននឹងខ្មែរក្រហមបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញៗ រំឭកដល់ថ្ងៃដែលខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្ញុំក៏នឹកឃើញដល់រដូវចូលឆ្នាំខ្មែរនាពេលនោះដែរៗ នៅខាងមុខផ្ទះនីមួយៗ មានការដាក់សែនទទួលទេវតាឆ្នាំថ្មីទៅតាមប្រពៃណីខ្មែរដូចជា ការដាក់តាំងលម្អផ្កាភ្ញី សែនផ្លែឈើ ទឹកក្រូចជាដើម ប៉ុន្តែពិធីបុណ្យចូលឆ្នាំខ្មែរនាពេលនោះ ហាក់បីដូចជាមានសភាពស្ងាត់ជ្រងំៗ

នាព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញកំពុងតែស្ថិតនៅក្នុងសភាពចលាចលយ៉ាងខ្លាំងៗ យោធាខ្មែរក្រហម២នាក់មានអាយុប្រហែល១៥ឆ្នាំ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅនិងនៅក្នុងដៃមានកាន់កាំភ្លើងវែងប្រភេទអាកាបានចូលមកក្នុងសណ្ឋាគារខេមរា ហើយបានប្រាប់ឲ្យពួកយើងចាកចេញពីទីក្រុងភ្នំពេញទៅកាន់ស្រុកកំណើតរៀងៗខ្លួន ចំណែកឯជនបរទេស យោធាខ្មែរក្រហម បានប្រាប់ឲ្យធ្វើដំណើរទៅកាន់ស្ថានទូតស្ថិតនៅក្បែរវត្តភ្នំៗ ប្រពន្ធរបស់ខ្ញុំបានរៀបចំដាំបាយ និងធ្វើម្ហូប ចំណែកខ្ញុំនឹងប្អូនប្រុស បានរៀបចំខោអាវ ចានឆ្នាំង និងវេចខ្ចប់អង្ករខ្លះយកទៅជាមួយៗ ម៉ោងប្រហែល៩ព្រឹក ខ្ញុំក្រឡេកមើលទៅខាងក្រៅសណ្ឋាគារឃើញមានប្រជាជនកំពុងតែធ្វើដំណើរចាកចេញពីផ្ទះរបស់ខ្លួននៅតាមផ្លូវថ្នល់យ៉ាងច្រើនកុះករៗ អ្នកខ្លះរែកអីវ៉ាន់ អ្នកខ្លះពកូន អ្នកខ្លះបើកឡាន ដោយមិនដឹងថាអ្នកទាំងអស់នោះធ្វើដំណើរទៅទីណាឡើយៗ ដោយសារតែឃើញប្រជាជនចាកចេញយ៉ាងដូចច្នេះ ខ្ញុំក៏សម្រេចចិត្តចាកចេញជាមួយប្រពន្ធ កូន២នាក់ និងប្អូនប្រុស២នាក់ ព្រមទាំងមានកង់មួយ

សម្រាប់ដឹកសម្ភារៗ កូនស្រីរបស់ខ្ញុំ បានដើរខ្លះនិងជិះលើកង់ខ្លះ ចំណែកឯប្រពន្ធរបស់ខ្ញុំពកូនតូចអាយុ ១៣ខែនៅក្នុងដៃដើរតាមពីខាងក្រោយកង់ៗ នៅពេលយើងធ្វើដំណើរមកដល់ម្តុំបឹងកេងកងក្បែរផ្ទះរបស់យើង យើងក៏ចង់ឆ្លៀតចូលផ្ទះដើម្បីវេចខ្ចប់អង្ករ និងម្ហូបអាហារខ្លះៗយកទៅជាមួយបន្ថែមដែរ ប៉ុន្តែយោធាខ្មែរក្រហមបានហាមដាច់ខាតមិនឲ្យយើងចូលទៅក្នុងផ្ទះឡើយៗ យើងបានចំណាយពេលពេញ ១ថ្ងៃ ដើម្បីធ្វើដំណើរពីសណ្ឋាគារក្បែរផ្សារធំថ្មីមកដល់ផ្លូវបំបែកភ្លើងស្តុបបូកគោ ហើយយើងក៏ឈប់សម្រាកនៅលើចិញ្ចើមផ្លូវនៅទីនោះ១យប់ៗ លុះព្រឹកឡើង យើងបន្តដំណើរសំដៅទៅទិសបូព៌ាដោយដើរឆ្លងកាត់ស្ពានព្រះមុនីវង្សចាស់រហូតមកដល់វត្តនិរោធម៉ោងប្រហែល៩យប់ រួចយើងក៏ឈប់សម្រាកនៅលើខឿនវត្តនោះ១យប់ទៀតៗ នៅព្រឹកបន្ទាប់យើងបានចាប់ផ្តើមធ្វើដំណើរបន្តទៀតរហូតដល់វត្តក្តីតាកុយ និងឈប់សម្រាកនៅទីនោះប្រហែលចំនួន៣យប់ៗ ដោយសារតែអស់អង្ករហូប ប្អូនប្រុស២នាក់របស់ខ្ញុំ បានយកសំបកកង់ឡានចំនួន២ ប្រើប្រាស់ធ្វើជាឧបករណ៍ហែលឆ្លងទន្លេត្រឡប់ទៅផ្ទះរបស់យើងនៅម្តុំបឹងកេងកងវិញ ដើម្បីទៅយកអង្ករ និងសម្ភារប្រើប្រាស់ៗ ប្អូនខ្ញុំបានត្រឡប់មកវិញជាមួយនឹងអង្ករកន្លះបាវ ចាន ឆ្នាំង ខោអាវ និងអំបិលៗ អំឡុងពេលស្នាក់នៅក្នុងវត្តក្តីតាកុយ ខ្ញុំក៏បានជួបនឹងពូថ្លៃរបស់ខ្ញុំឈ្មោះ គុណ ហើយគាត់បានហៅខ្ញុំឲ្យធ្វើដំណើរត្រឡប់មកភូមិកំណើតរបស់ប្រពន្ធខ្ញុំនៅក្នុងស្រុកអង្គរជ័យ ខេត្តកំពតជាមួយគាត់វិញៗ ខ្ញុំបានប្រាប់ប្អូនប្រុសទាំង២នាក់របស់ខ្ញុំ ឲ្យត្រឡប់មក


ណុប រឿន ហៅ ប៉ាវ ឈរច្រត់ចង្កេះនៅជួរខាងក្រោយរាប់ពីស្តាំដៃ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្រុកកំណើតដែលស្ថិតនៅក្នុងភូមិពានា ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដើម្បីនាំយកដំណឹងទៅប្រាប់ម្តាយឪពុករបស់ខ្ញុំដែលកំពុងរស់នៅទីនោះ។ នៅពេលព្រះអាទិត្យរះឡើង យើងបានលាគ្នា ហើយខ្ញុំ ប្រពន្ធ និងកូន បានចាកចេញពីវត្តក្តីតាកុយយ៉ាងប្រញាប់ប្រញាល់តាមយោធាខ្មែរក្រហមបានប្រាប់ឲ្យធ្វើដំណើរទៅតាមភូមិកោះក្របី រួចបន្តជិះទូកឆ្លងទន្លេទៅក្រុងតាខ្មៅ ដែលម្ចាស់ទូកបានយកថ្លៃចម្លងទូកក្នុង១នាក់អង្ករ២កំប៉ុង។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើងមកដល់ឃុំគូស ដោយចំណាយអស់រយៈពេល ៥ យប់និង៦ថ្ងៃ ហើយក៏បានសុំផ្ទះរបស់សាច់ញាតិខាងប្រពន្ធខ្ញុំស្នាក់នៅចំនួន១យប់។ លុះស្អែកឡើង សាច់ញាតិខាងប្រពន្ធខ្ញុំបានសុំឡានរបស់យោធាខ្មែរក្រហម ដើម្បីឲ្យក្រុមគ្រួសារខ្ញុំជិះមកស្រុកកំណើតវិញ។ នៅក្នុងឡាននោះ មានដឹកយោធាខ្មែរក្រហមចំនួន១២នាក់ ដែលម្នាក់ៗស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ អង្គុយយ៉ាងស្ងៀមស្ងាត់ និងមិននិយាយស្តីអ្វីឡើយ ថែមទាំងមានកាន់កាំភ្លើងគ្រប់ដៃទៀតផង។

មកដល់ស្រុកកំណើតដំបូង ខ្ញុំឃើញម្តាយឪពុកក្មេកខ្ញុំកំពុងតែអង្គុយទន្ទឹងចាំផ្លូវយើងនៅផ្ទះ ហើយគាត់ត្រេកអរខ្លាំងណាស់នៅពេលឃើញពួកខ្ញុំទៅដល់។ ខ្ញុំឃើញប្រជាជនប្លែកមុខជាច្រើនបានមករស់នៅក្នុងភូមិ និងមានការរៀបចំឲ្យមានប្រធានភូមិថ្មីឈ្មោះ តាប៊ិននិងអនុប្រធានភូមិឈ្មោះព្រឹងធ្វើជាអ្នកគ្រប់គ្រងនៅក្នុងភូមិខ្ញុំ។ គ្រួសារនីមួយៗរស់នៅជួប



ប្រជាជនកម្ពុជា ជម្លៀសចេញពីទីក្រុងភ្នំពេញថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជុំគ្នាជាធម្មតា ប៉ុន្តែយើងត្រូវទៅធ្វើការតាមដែលខ្មែរក្រហមបានចាត់ចែងឲ្យយើងធ្វើ។ ខ្មែរក្រហម បានចែកអង្ករឲ្យយើងជាប្រចាំថ្ងៃបន្ទាប់ពីយើងត្រឡប់មកពីធ្វើការងារវិញ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានតម្រូវឲ្យខ្ញុំចេញទៅធ្វើការនៅក្នុងកងចល័ត ចំណែកឯប្រពន្ធខ្ញុំទៅធ្វើការនៅក្នុងកងនារីធ្វើជាអ្នកធាក់រហាត់ទឹកដើម្បីបញ្ចូលទឹកទៅក្នុងស្រែប្រាំង។ កូនច្បងរបស់ខ្ញុំ បានទៅរស់នៅក្នុងកងកុមារ និងកូនប្អូនបន្ទាប់ទៀត ផ្ញើទុកជាមួយយាយៗមើលថែរក្សា។ មួយឆ្នាំក្រោយមក ខ្មែរក្រហម កាន់តែរឹតបន្តឹងឡើងៗ ដោយបានរៀបចំឲ្យប្រជាជនទាំងអស់រស់នៅរួមៗ។ មេភូមិចាស់ត្រូវបានខ្មែរក្រហមចាប់ដាក់គុក ព្រោះគាត់ព្យាយាមលាក់បាំងប្រវត្តិរូបរបស់ប្រជាជនថ្មី ហើយបន្ទាប់មកបានផ្លាស់មេភូមិថ្មីមកគ្រប់គ្រងវិញម្តងៗ។ ខ្មែរក្រហម បានចាប់ផ្តើមយកប្រជាជនទៅរៀនសូត្រជាប្រចាំថ្ងៃនិងមិនដែលឃើញដោះលែងឲ្យត្រឡប់មកផ្ទះវិញទេ។ ខ្ញុំត្រូវបានខ្មែរក្រហមឲ្យទៅធ្វើការងារលើកទំនប់និងជីកប្រឡាយនៅភូមិផ្សេងឆ្ងាយពីប្រពន្ធរបស់ខ្ញុំ។ យើងជួបគ្នា១ដងក្នុងមួយសប្តាហ៍។ ថ្ងៃមួយ នាវេលាទៀបភ្លឺម៉ោងប្រហែល២រំលងអធ្រាត្រ កងឈ្លប៣នាក់ និងមេកង១នាក់បានមកឈរស្រែកហៅខ្ញុំនៅពីខាងមុខខ្ទមដែលខ្ញុំកំពុងតែដេកលង់លក់ ហើយបានសួរថាតើខ្ញុំឈ្មោះអ្វី និងក្រុមគ្រួសាររបស់ខ្ញុំកំពុងរស់នៅឯណា។ ខ្ញុំពិតជាភិតភ័យយ៉ាងខ្លាំងព្រោះក្នុងចិត្តគិតថា ខ្ញុំនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់នៅយប់នោះហើយ។ រំពេចនោះ ខ្ញុំបានបន់ស្រន់នៅក្នុងចិត្ត នឹកដល់វត្ថុស័ក្តិសិទ្ធទាំងឡាយ និងគុណម្តាយឪពុករបស់ខ្ញុំ និងបានឆ្លើយតបទៅកាន់កងឈ្លបវិញទាំងញ័រមាត់។ ប៉ុន្តែមួយសន្ទុះក្រោយមក កងឈ្លបប្រាប់ខ្ញុំថា ច្រឡំមនុស្ស។ ខ្ញុំដេកមិនលក់ទាល់តែសោះនៅយប់នោះ ព្រោះខ្ញុំដឹងខ្លួនថាខ្ញុំមានកំហុសដោយសារខ្ញុំតែងតែលួចដំឡូងហូបជាប្រចាំថ្ងៃ។ នៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានធ្លាក់ខ្លួនឈឺដោយជំងឺហើម អស់កម្លាំងល្ហិតល្ហៃ ពាករូស និងដើរមិនរួច។ កន្លងហួសប្រហែលជា៣ថ្ងៃ កងទ័ពវៀតណាមបានចូលមកដល់ ប៉ុន្តែប្រជាជនបានចាញ់បោកការឃោសនារបស់ខ្មែរក្រហម និងនាំគ្នារត់តាមខ្មែរក្រហមចូលទៅក្នុងព្រៃនិងឡើងភ្នំ។ ខ្ញុំនិងគ្រួសារបានរត់តាមខ្មែរក្រហមរហូតដល់ទំនប់តាដេវ ក៏បានជួបនឹងកងទ័ពវៀតណាម ដោយបានប្រាប់ខ្ញុំនិងគ្រួសារឲ្យត្រឡប់មករស់នៅស្រុកកំណើតវិញ។ ដោយសារតែអស់កម្លាំង និងធ្វើដំណើរដោយថ្មើរជើង ខ្ញុំនិងក្រុមគ្រួសារត្រូវចំណាយពេលអស់ជាច្រើនថ្ងៃទម្រាំធ្វើដំណើរមកដល់ស្រុកកំណើត។ យើងដើរបណ្តើរឈប់សម្រាកតាមផ្លូវបណ្តើរ ជួនពេលខ្លះ យើងបានប្រទះឃើញសាកសពនៅតាមផ្លូវគ្រប់ទីកន្លែង។

មកដល់ផ្ទះវិញ យើងបាននាំគ្នាជួសជុលខ្ទមដែលបានធ្លុះធ្លាយ និងស្វែងរកស្រូវដែលនៅសេសសល់ដើម្បីហូប។ ដោយសារតែភាពខ្វះខាត ប្រពន្ធរបស់ខ្ញុំ បានធ្វើដំណើរទៅប្រទេសវៀតណាមជាមួយប្រជាជនផ្សេងទៀត ដើម្បីយកមាសប្រាក់ដែលនៅសេសសល់ពីការលាក់ទុកពីខ្មែរក្រហមទៅដូរយកអង្ករ និងសម្ភារប្រើប្រាស់ផ្សេងៗ។ ពិតជាគួរឲ្យអាសូរណាស់ ព្រោះសមាជិកគ្រួសាររបស់ខ្ញុំម្នាក់ៗ មានរាងស្គមកំព្រឹងៗ នៅសល់តែក្បាលជង្គង់ និងគ្រាប់ភ្នែកធំៗ និងជារឿយៗ យើងក៏បាននិយាយប្រាប់គ្នាអំពីហេតុការណ៍ដែលយើងបានជួបប្រទះនៅក្នុងរបបខ្មែរក្រហមដែរ។

ឈ្មោះរបស់ខ្ញុំគឺ ណុប រឿន ហៅ ប៉ាវ ចំណែកប្រពន្ធរបស់ខ្ញុំឈ្មោះ ណុប សំអ៊ិត។ ខ្ញុំ មានអាយុ៨០ឆ្នាំ និងប្រពន្ធរបស់ខ្ញុំមានអាយុ៧១ឆ្នាំ។ យើងទាំងពីរមានកូនចំនួន៨នាក់ ស្រីចំនួន៤នាក់និងប្រុសចំនួន៤នាក់។ នៅក្នុងរបបខ្មែរក្រហម កូនស្រីចំនួន២នាក់របស់ខ្ញុំ បានស្លាប់ព្រោះដោយសារតែអត់ឃ្លាន និងឈឺ។ កូនស្រីច្បងរបស់ខ្ញុំ បានរត់ពួននៅក្នុងព្រៃដោយការគេចវេះមិនព្រមទៅធ្វើការងារជាមួយនឹងក្មេងដ៏ទៃទៀត ហើយក៏គ្មានអាហារហូបរហូតដល់ដាច់ពោះស្លាប់។ ចំណែកកូនស្រីម្នាក់ទៀត បានស្លាប់ដោយសារជំងឺ ព្រោះពេលនោះគ្រូពេទ្យបានឲ្យតែថ្នាំខ្មែរផ្សំអំពីឫសឈើ ដើម្បីយកមកត្រាំក្នុងទឹកដូងផឹកតែប៉ុណ្ណោះ។

*អ៊ុន សុដាវី*

# ចម្រៀងបដិវត្តន៍ បានជួយជីវិតខ្ញុំ

ខ្ញុំច្រៀងរហូត ច្រៀងគ្រប់ពេលវេលា ខ្ញុំច្រៀងបណ្ដើរ វែកដីបណ្ដើរ ច្រៀងពេលដែលខ្ញុំ កំពុងតែធ្វើការងារនៅតាមវាលស្រែ និងលើកទំនប់ ច្រៀងនៅពេលបិទការដ្ឋាន ច្រៀងនៅពេល ដែលខ្ញុំកំពុងតែដើរនៅតាមផ្លូវ និងច្រៀងនៅតាមផ្ទះ ដើម្បីបំភ្លេចភាពនឿយហត់ និងទុក្ខកង្វល់នៅក្នុងចិត្ត ប៉ុន្តែនាពេលនោះ ខ្ញុំមិនបានដឹងទាល់តែសោះថាតើចម្រៀងបដិវត្តន៍និពន្ធឡើងដើម្បីអ្វីនោះទេ។ ខ្ញុំដឹងត្រឹមថា ចម្រៀងបដិវត្តន៍បានធ្វើឲ្យអារម្មណ៍ខ្ញុំសប្បាយរីករាយនិងមានកម្លាំងក្នុងការធ្វើការងារ។


សួង សុខលាង អាយុ៥៩ឆ្នាំ នៅ ខេត្តកំពង់ចាម កំពុងអង្គុយរៀបរាប់អំពីបទពិសោធន៍នៅក្នុងរបបខ្មែរក្រហម
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ចម្រៀងអង្គការ**

យើងខ្ញុំកុមារ ស្រឡាញ់អង្គការឥតមានព្រំដែន
ដោយសារអង្គការ យើងខ្ញុំរស់រាន ជីវិតថ្កើងថ្កាន
រីករាយអស្ចារ្យ។
មុនបដិវត្តន៍ កុមារក្រខ្សត់ រងទុក្ខវេទនា
រស់ដូចសត្វធាតុ កំព្រាខ្វោចផ្សា អាក្បត់មហា
គ្មានទីកនាដល់។
ស្បែកដណ្ដប់ឆ្អឹង ស្គមស្គាំងកំព្រឹង
មហាសែនកង្វល់ យប់ដេកនឹកនា
ថ្ងៃឡើងខ្វាយខ្វល់ កាយកាកសំណល់
ដើរសុំទានគេ។
ឥឡូវយើងខ្ញុំ អង្គការឧត្ដម ឧបត្ថម្ភគ្រប់គ្នា
បំប៉នសុខភាព កម្លាំងក្លាំងខ្លា ឲ្យក្លាយទៅជា
សមូហភាព។
ពួកយើងគឺជាកុមាររបស់អង្គការ។
ពួកយើងគ្មានខ្វាចអ្វីទាំងអស់។ ពួកយើងគឺជាអនាគត។
យើងរៀនប្រយុទ្ធ។
ហើយនេះជាកាំភ្លើង។ កាំភ្លើងស្រួលបាញ់។
កូនក្មេងក៏អាចបាញ់បានដែរ។

ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេលជាង៤០ឆ្នាំ ប៉ុន្តែចម្រៀងបដិវត្តន៍ នៅតែវិលវល់ក្នុងអារម្មណ៍និងការចងចាំរបស់ខ្ញុំជានិច្ច។ ខ្ញុំនៅតែអាចច្រៀងចម្រៀងទាំងអស់នោះ បានស្ទើរតែគ្រប់បទចម្រៀងដែលខ្ញុំបានធ្លាប់ឮ ព្រោះវាបានដិតដាមជាប់ក្នុងខួរក្បាលរបស់ខ្ញុំទៅហើយ។

ខ្មែរក្រហមមិនយកទោសនោះទេ នៅពេលដែលយើងច្រៀងចម្រៀងបដិវត្តន៍។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមថែមទាំងបានលើកទឹកចិត្តឲ្យយើងច្រៀងគ្រប់ពេល។ នៅពេលលើកទំនប់ម្ដងៗ ខ្មែរក្រហមបានបំពាក់ឧបករណ៍បំពងសំឡេងដាក់

ស្ទើរតែគ្រប់ទិសទី ហើយចាក់បទចម្រៀងបដិវត្តន៍ជាច្រើនបទផ្សេងៗគ្នា។ នៅពេលដែលខ្មែរក្រហមចាក់ចម្រៀងអំឡុងពេលកំពុងធ្វើការងារ វាបានជួយផ្ដល់កម្លាំង និងជួយជំរុញទឹកចិត្តឲ្យខ្ញុំខិតខំធ្វើការងារយ៉ាងញាប់ដៃញាប់ជើងទៅតាមចង្វាក់ភ្លេងនោះដែរ។ ប៉ុន្តែអត្ថន័យនៃបទចម្រៀង និងទង្វើដែលខ្មែរក្រហមបានធ្វើ វាហាក់បីដូចជាផ្ទុយស្រឡះពីគ្នា។ ប្អូនប្រុសរបស់ខ្ញុំម្នាក់គឺជាកុមារ ដែលត្រូវបានខ្មែរក្រហមតែងតែហៅឲ្យមកចូលរួម សម្ដែងសិល្បៈដូចជាការច្រៀងចម្រៀងអង្គការរាល់ពេលមានកម្មវិធីម្ដងៗ។ ជារឿយៗ ខ្ញុំតែងតែ ទៅទស្សនាការសម្ដែងនោះ។ នៅពេលសម្ដែងកុមារទាំងអស់ ច្រៀងបណ្ដើរ រាំបណ្ដើរនិងក្នុងដៃ មានកាន់កាំភ្លើងដែរ។ នាពេលនោះ ខ្ញុំមានអារម្មណ៍ថា កុមារគឺពិតជាអស្ចារ្យណាស់។

នៅពេលដែលខ្មែរក្រហមចូលមកដល់ភូមិស្រុករបស់ខ្ញុំដំបូង គឺខ្ញុំមានអាយុប្រហែល១៣ឆ្នាំ និងកំពុងតែរៀននៅក្នុងវិទ្យាល័យកំពង់ចាមក្នុងអំឡុងឆ្នាំ១៩៧៣។ នាព្រឹកថ្ងៃមួយមានបុរសពានាក់ ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បានដើរចូលមកក្នុងផ្ទះរបស់ខ្ញុំ ហើយនិយាយទៅកាន់ជីតារបស់ខ្ញុំថា ឲ្យចាកចេញពីផ្ទះមួយរយៈពេលសិនដើម្បីឲ្យអង្គការរៀបចំកែលម្អទីក្រុងកំពង់ចាមឡើងវិញ។ ជីតារបស់ខ្ញុំ ក៏បានសួរទៅកាន់បុរសពានាក់នោះថា តើយើងអាចយកអ្វីទៅតាមខ្លួនបានខ្លះ? ខ្ញុំបានក្រឡេកមើលនៅតាមផ្ទះប្រជាជនក្បែរខាងរបស់ខ្ញុំ ក៏ឃើញមានយោធាខ្មែរក្រហមដ៏ទៃទៀត ដើរចូលទៅតាមផ្ទះដែរ។ បន្ទាប់ពីទទួលបានដំណឹងនេះ យើងបានរៀបចំឥវ៉ាន់យ៉ាងប្រញាប់ ប្រញាល់និងយកសម្ភារៈតាមដែលយើងអាចយកទៅបាន ដូចជាការវេចខ្ចប់ស្បៀងអាហារជាដើម។ ខ្ញុំមានកូនកង់តូចមួយបណ្ដើរតាមផ្លូវ ដោយមានចងឥវ៉ាន់សំពេងសំពោងនៅពីខាងក្រោយ។ យើងតែងតែឈប់សម្រាកនៅតាមផ្លូវជាបណ្ដើរៗនៅពេលដែលយើងហត់។ ជីដូនខាងឪពុករបស់ខ្ញុំដែល ពេលនោះគាត់មានអាយុ៧០ឆ្នាំគឺពិបាកធ្វើដំណើរតាមផ្លូវយ៉ាងខ្លាំង។ យើងតែងតែផ្លាស់ប្ដូរគ្នា ដើម្បីគ្រៀកគាត់នៅតាមផ្លូវដើម្បីធ្វើដំណើរទៅមុខព្រមៗគ្នា។ យើងដើរបណ្ដើរគេចគ្រាប់កាំភ្លើងបណ្ដើរ។ នៅតាមដងផ្លូវ មានសុទ្ធតែដានជើង ដែលជាន់ស្មៅឡើងខ្ទេចខ្ទីរាបស្មើដេកដួលកប់ទៅនឹងដី ថែមទាំងសុទ្ធសឹងជាភក់ជ្រាំ។

ដំបូង យើងចាកចេញពីផ្ទះដើរសំដៅទៅភូមិតាមៀង និងបន្តដំណើរឆ្ពោះទៅស្រុកពាមជីកងតាមដែលយោធាខ្មែរក្រហមកៀរ។ ជួនពេលខ្លះ យើងកំពុងតែដាំបាយមិនទាន់ឆ្អិនផង ក៏ត្រូវលើកឆ្នាំងបាយទៅជាមួយដើម្បីបន្តទៅមុខភ្លាមៗ។ យើងចេះតែដើរទៅមុខរហូតយប់នៅកន្លែងណាគឺឈប់សម្រាកនៅកន្លែងនោះ។ ផ្ទះនៅតាមដងផ្លូវ គឺគ្មានមនុស្សរស់នៅទេ។ អ្នកទាំងនោះប្រហែល ជាត្រូវខ្មែរក្រហមកៀរឲ្យចេញពីផ្ទះដូចជាយើងដែរ។ ខ្ញុំនិងក្រុមគ្រួសារបានបញ្ចប់ដំណើរត្រឹមភូមិ ស្ពឺ ឃុំស្ពឺ ស្រុកចម្ការលើ ជាកន្លែងដែលសាច់ញាតិរបស់ខ្ញុំរស់នៅទីនោះ។ ខ្ញុំបានស្នាក់នៅទីនោះ ជាមួយសាច់ញាតិរបស់ខ្ញុំនៅទីនោះ។ យើងដើររើសកួរស្រូវនៅតាមវាលស្រែដើម្បីយកមកបុកធ្វើអង្ករ ហើយស្វែងរកម្ហូបអាហារនៅក្បែរៗភូមិយកមកបរិភោគជាប្រចាំថ្ងៃ។ នៅក្នុងឆ្នាំ១៩៧៣ ប្រជាជនទាំងអស់មិនទាន់រស់នៅជាសហករណ៍នោះទេ។ យើងបានការដោះដូរ ឬលក់ដូរដោយ ចាយមាសឬប្រាក់ ប៉ុន្តែគ្មានការចាយលុយនោះទេ។

នៅឆ្នាំ១៩៧៤ ខ្ញុំបានចាកចេញទៅរស់នៅក្នុងសហករណ៍ស្ថិតក្នុងភូមិក្រចៅ។ ខ្មែរក្រហមបានអនុញ្ញាតិឲ្យយើងដាំដុះនៅតាមផ្ទះ និងធ្វើការក្នុងសហករណ៍ដែរ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ឲ្យធ្វើជាកុមារត្រៀម ដោយយកខ្ញុំទៅរស់នៅក្នុងការរដ្ឋាន ដាច់ដោយឡែកពីក្រុមគ្រួសាររបស់ខ្ញុំ។ ជីដូនរបស់ខ្ញុំនិងចាស់ៗដទៃទៀត ត្រូវបានខ្មែរក្រហមឲ្យទៅជម្រះស្មៅនៅក្នុងភូមិ និងមើលថែរក្សាក្មេងៗដែលម្ដាយឪពុកបានចាកចេញទៅធ្វើការងារអស់។ នៅពេលដែលខ្ញុំរស់នៅក្នុងកងកុមារត្រៀម ខ្មែរក្រហមបានឲ្យខ្ញុំទៅលើកភ្លឺស្រែ។ ក្រោយមក នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានយកខ្ញុំទៅរស់នៅតាមកងចល័តវិញ និងចាត់តាំងឲ្យទៅលើកទំនប់២០កុម្ភៈ។ ខ្ញុំបាន

ធ្វើការងារនៅក្នុងកង ចល័តរហូតដល់ឆ្នាំ១៩៧៩ ប៉ុន្តែខ្ញុំតែងតែផ្លាស់ប្តូរកន្លែងធ្វើការងារ ពីការដ្ឋាន១កន្លែង ទៅ១កន្លែងផ្សេងទៀតជាបន្តបន្ទាប់។ ខ្ញុំធ្លាប់បានទៅធ្វើការងារនៅក្នុងចម្ការកប្បាសដែរ។ ខ្ញុំគឺជាអ្នកបាញ់ថ្នាំសម្លាប់សត្វល្អិតដែលបំផ្លិចបំផ្លាញផ្លែកប្បាស ដោយស្ពាយធុងថ្នាំដើរបាញ់នៅក្នុងចម្ការស្ទើរជារៀងរាល់ថ្ងៃ។ ខ្ញុំឮខ្មែរក្រហមនិយាយថាកប្បាសដែលដាំបាននេះគឺនាំចេញទៅលក់ឲ្យចិន។ រីឯពូជកប្បាសដែលដាំនេះក៏នាំយកមកពីប្រទេសចិនដែរ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងធ្វើការងារមិន ដែលបានឈប់សម្រាកឡើយ គឺធ្វើការងារចប់ពីការដ្ឋាន១ប្តូរទៅការដ្ឋាន១ទៀត។

នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំបានស្នើសុំអង្គការមកធ្វើការងារនៅក្បែរផ្ទះ ដើម្បីមើលថែរក្សាឪពុករបស់ខ្ញុំដែលកំពុងតែធ្លាក់ខ្លួនឈឺធ្ងន់។ ឪពុករបស់ខ្ញុំមានជំងឺហើម ដែលពេលខ្លះខ្ញុំឃើញមានទឹកជ្រាបចេញតាមស្បែករបស់គាត់។ ជំងឺហើមនេះកើតឡើងដោយសារតែគាត់ខ្វះជីជាតិ និងកង្វះចំណីអាហារបរិភោគគ្រប់គ្រាន់។ ខ្ញុំ និងក្រុមគ្រួសារបានសម្រេចចិត្តមិនយកគាត់ទៅព្យាបាលនៅ មន្ទីរពេទ្យឡើយ ព្រោះយើងដឹងថាគាត់នឹងកាន់តែឆាប់ស្លាប់ប្រសិនបើគាត់ទៅព្យាបាលនៅក្នុងមន្ទីរពេទ្យ។ ខ្ញុំបានលួចយកមាសប្រាក់ទៅដូរយកថ្នាំសង្កូវខ្លះដើម្បីព្យាបាលឲ្យឪពុករបស់ខ្ញុំ។ យើងទាំងអស់គ្នាបានខិតខំថែទាំជំងឺគាត់ណាស់ ប៉ុន្តែចុងក្រោយគាត់នៅតែស្លាប់ចោលយើង។ បន្ទាប់ពីឪពុកខ្ញុំស្លាប់ ខ្ញុំបានស្នើសុំបន្ទះក្តារពីថ្នាក់លើដើម្បីធ្វើជាមឈូស ដោយមានអ្នកជិតខាងបានជួយគ្នារៀបចំធ្វើមឈូសនិងយកគាត់ទៅកប់នៅវាលស្រែ។ នឹកឃើញដល់ពេលនោះ ខ្ញុំពិតជាមានចិត្តក្លាហានណាស់ ព្រោះអំឡុងពេលដែលឪពុករបស់ខ្ញុំឈឺ ខ្ញុំបានលួចធ្វើដំណើរចាកចេញពីការដ្ឋាន ធ្វើការងារពេលយប់ដើម្បីត្រឡប់មកផ្ទះ ដោយបានដើរកាត់ព្រៃចម្ងាយប្រហែល៨គីឡូម៉ែត្រដែលមានសភាពស្ងាត់សូន្យឈឹង និងឮសូរតែសំឡេងឆ្កែចចកស្រែកយំ។ លុះព្រឹកឡើង ខ្ញុំក៏ត្រូវត្រឡប់មកការដ្ឋានធ្វើការងារឲ្យទាន់ពេលវេលាវិញ។

បន្ទាប់ពីឪពុករបស់ខ្ញុំស្លាប់ ខ្មែរក្រហមបានដកខ្ញុំឲ្យមកធ្វើការងារនៅក្នុងកងចល័តវិញ។ ពីមួយថ្ងៃទៅមួយថ្ងៃ ខ្មែរក្រហមបានយកប្រជាជនទៅបាត់កាន់តែច្រើន រីឯចំណីអាហារវិញគឺហូបតែបបរតែប៉ុណ្ណោះ ហើយខ្ញុំតែងតែលួចគាស់ដំឡូងហូបជានិច្ច។ ខ្ញុំបានធ្លាក់ខ្លួនឈឺខ្លាំងនៅពេលរដូវច្រូតកាត់។ ខ្ញុំមានជំងឺពករូស និងគ្រុនចាញ់ ហើយបានឈប់សម្រាកនៅផ្ទះជិត១ខែ។ ប៉ុន្តែនៅពេលនោះ ខ្ញុំពិតជាមានសំណាងល្អខ្លាំងណាស់ព្រោះប្រធានសហករណ៍របស់ខ្ញុំមានក្តីមេត្តាចំពោះខ្ញុំ ដោយបានយកថ្នាំល្អៗមកឲ្យខ្ញុំលេប រហូតដល់បានជាសះស្បើយ។ ក្រោយមក ខ្ញុំបានឮថាប្រធាន សហករណ៍នោះត្រូវបានខ្មែរក្រហមចោទប្រកាន់ថាគាត់សម្លាប់មនុស្ស និងបានយកគាត់ទៅសម្លាប់។

នៅក្នុងឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានចូលមករំដោះប្រជាជន ពីការគ្រប់គ្រងរបស់ខ្មែរក្រហម។ ក្រុមគ្រួសាររបស់ខ្ញុំ បានរត់គេចចេញពីខ្មែរក្រហមមកចូលនៅក្នុង ខ្សែត្រៀមដែលកងទ័ពកំពុងតែវាយប្រហារគ្នា។ ខ្ញុំឃើញមានយោធានិងប្រជាជនខ្លះដេកស្លាប់ខ្លះ ត្រូវរបួសដោយសារគ្រាប់កាំភ្លើង។ ភាពភ័យខ្លាចនៅក្នុងខ្លួនរបស់ខ្ញុំលែងមានទៀតហើយ គឺយើងខិតខំធ្វើយ៉ាងណាអាចរក្សាជីវិតរបស់ខ្លួនឲ្យបានសុខសប្បាយ។ ក្រោយមកកងទ័ពវៀតណាម បានចូលមកដល់ ខ្ញុំនិងក្រុមគ្រួសារ ក៏បានចាកចេញត្រឡប់មកស្រុកកំណើតវិញ។ នៅក្រោមពន្លឺព្រះច័ន្ទ យើងដើរបណ្តើរគេចចេញពីគ្រាប់កាំភ្លើងនិងយោធាខ្មែរក្រហមបណ្តើរ។ យើងដើររហូតទាំងយប់ ទាំងថ្ងៃអស់រយៈពេលប្រហែល១សប្តាហ៍ ទើបមកដល់ស្រុកកំណើត។

បន្ទាប់ពីរបបខ្មែរក្រហម សាច់ញាតិរបស់ខ្ញុំបានបាត់បង់ជីវិតអស់៤នាក់គឺឪពុករបស់ខ្ញុំ ជីដូន ជីតា និងបងថ្លៃ។ សាកសពរបស់គាត់ត្រូវបានកប់នៅក្បែរៗគ្នានៅពេលនោះ ប៉ុន្តែសព្វថ្ងៃនេះ ទីកន្លែងកប់សពរបស់គាត់ត្រូវបានប្រជាជនគាស់កកាយខូចខ្ទី និងប្រែក្លាយជាកន្លែងសម្រាប់ដាំ ដំណាំអស់ទៅហើយ។

អ្វីដែលល្អអាក្រក់គឺជាកម្មពៀរៗ ខ្ញុំមិនខឹងនឹងខ្មែរក្រហមដែលធ្វើបាននាំយកជីវិតក្រុមគ្រួសាររបស់ខ្ញុំនោះទេៗ រឿងរ៉ាវដែលធ្វើឲ្យខ្ញុំសប្បាយចិត្តជាងគេ គឺការជួយលើកទឹកចិត្តប្រជាជនថ្មីដែល គាត់តែងតែអស់សង្ឃឹមនៅក្នុងជីវិតរបស់គាត់ ព្រោះគាត់មិនចេះធ្វើការងារអ្វីនិងភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោលៗ

ខ្ញុំជឿថា បើយើងមិនអាចអភ័យទោសនិងអត់ឱនឲ្យគ្នាទៅវិញទៅមកបាននោះទេ វានឹងនៅតែជួបបញ្ហាដដែលៗៗ សេចក្ដីមេត្តាត្រូវតែមានក្នុងចិត្ត ដើម្បីបង្កើតនូវសេចក្ដីល្អៗ គំនុំទាំងឡាយនឹងរលាយបាត់ លុះត្រាតែយើងចេះអត់ឱនៗ ទាំងអស់នេះនឹងនាំឲ្យមានសន្តិភាពៗ

**ការយល់ឃើញចំពោះបទចម្រៀងបដិវត្តន៍នៅក្នុងរបបខ្មែរក្រហម**

១) ទេព បុណ្ណមី ភេទប្រុស សព្វថ្ងៃគឺជាគ្រូខ្មែរ


តួអង្គសម្ដែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» កំពុងតែច្រៀងចម្រៀងអង្គការ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


តួអង្គសម្ដែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» កំពុងតែច្រៀងចម្រៀងនៅវគ្គបញ្ចប់នៃការសម្ដែង (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)



គរុសិស្សចូលរួមទស្សនាការសម្ដែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តកំពង់ចាម (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជំនាញសិល្បៈនិងប្រវត្តិវិទ្យានៅសាលាគរុកោសល្យភូមិភាគកំពង់ចាម បានចែករំលែកបទពិសោធន៍របស់គាត់ថា៖

រំឭកដល់ចម្រៀងនៅក្នុងរបបខ្មែរក្រហម ខ្ញុំចូលចិត្តច្រៀងចម្រៀងអង្គការណាស់។ នៅពេលដែលបងប្រុសរបស់ខ្ញុំត្រឡប់មកពីធ្វើការនៅក្នុងកងកុមារវិញ គាត់តែងតែស្រែកច្រៀងចម្រៀងអង្គការនៅផ្ទះជានិច្ច ហើយខ្ញុំក៏ស្រែកច្រៀងតាមគាត់ដែរ។ យើងច្រៀងជាមួយគ្នាយ៉ាងសប្បាយរីករាយ។ ខ្ញុំតែងតែច្រៀងចម្រៀងនេះឲ្យឪពុកម្តាយរបស់ខ្ញុំស្តាប់បន្ទាប់ពីគាត់ត្រឡប់មកពីធ្វើការងារវិញ។ ខ្ញុំក៏ធ្លាប់បានស្ម័គ្រចិត្តឡើងច្រៀងបទចម្រៀងកុមារអង្គការ និងចម្រៀងផ្សេងទៀត នៅពេលដែលប្រមូលផលស្រូវក្នុងបរិវេណបោកស្រូវនៅក្នុងចំណោមក្រុមមនុស្សក្មេងចាស់ជាច្រើននាក់។ ខ្ញុំមិនដឹងថាតើចម្រៀងអង្គការមានអត្ថន័យយ៉ាងដូចម្តេចនោះទេនៅពេលនោះ។ រហូតបច្ចុប្បន្ននេះទើបខ្ញុំយល់ថាចម្រៀងអង្គការគឺជាចម្រៀងមនោគមន៍វិជ្ជាដែលធ្វើឲ្យកុមារលង់ស្ទុងអារម្មណ៍និងជឿជាក់ទៅតាមបទចម្រៀងនោះ ថែមទាំងហ៊ានលះបង់អ្វីៗគ្រប់យ៉ាងដើម្បីអង្គការ។

ខ្ញុំមានស្រុកកំណើតនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ឪពុករបស់ខ្ញុំគឺជាគ្រូបង្រៀន ហើយគាត់តែងតែផ្លាស់ប្តូរទីលំនៅជានិច្ច។ ដំបូងគ្រួសារខ្ញុំបានផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ និងបន្ទាប់មក យើងក៏ផ្លាស់ទៅរស់នៅស្រុកមោងឫស្សីខេត្តបាត់ដំបងវិញ។ នៅអំឡុងឆ្នាំ១៩៧៥ ខ្មែរក្រហម បានចូលមកគ្រប់គ្រងទឹកន្លែងដែលខ្ញុំរស់នៅ។ ឪពុកម្តាយរបស់ខ្ញុំ ត្រូវខ្មែរក្រហមបញ្ជូនទៅធ្វើការងារនៅតាមវាលស្រែ។ ចំណែកបងស្រីរបស់ខ្ញុំត្រូវបានខ្មែរក្រហម ប្រាប់ឲ្យចាកចេញពីផ្ទះទៅធ្វើការ និងរស់នៅក្នុងកងចល័តដោយមិនអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញទេ។ បងប្រុសរបស់ខ្ញុំម្នាក់ទៀត បានចូលរួមធ្វើការងារនៅក្នុងកងកុមារ។ នៅពេលនោះ ខ្ញុំមានអាយុប្រហែល ៤ឆ្នាំ។ នៅពេលដែលឪពុកម្តាយរបស់ខ្ញុំទៅធ្វើការងារនៅខាងក្រៅផ្ទះ ខ្ញុំនៅផ្ទះតែម្នាក់ឯង។ ខ្ញុំតែងតែអង្គុយទន្ទឹងចាំផ្លូវបង និងឪពុកម្តាយរបស់ខ្ញុំត្រឡប់ពីធ្វើការងារវិញជារៀងរាល់ល្ងាច។

(២) ថូ កន្និដ្ឋា ភេទស្រី គឺជាគរុសិស្សជំនាញភាសាអង់គ្លេស និងភាសាខ្មែរដែលកំពុងសិក្សា ឆ្នាំទី១នៅសាលាគរុកោសល្យភូមិភាគកំពង់ចាម បានចែករំលែកការយល់ឃើញរបស់គាត់ចំពោះបទចម្រៀងអង្គការថា៖

ល្ខោននិយាយរឿង «ទម្លាយភាពស្ងៀមស្ងាត់» បានលើកយកសាច់រឿងជាច្រើនដែលអាចឲ្យខ្ញុំដឹងនូវអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមច្រើនជាងមុន ជាពិសេសការស្វែងយល់ អំពីបទចម្រៀងអង្គការដែលបាននិពន្ធឡើងនៅអំឡុងពេលនោះ។ ចម្រៀងអង្គការ ហាក់បីដូចជា ធ្វើឲ្យកុមារសប្បាយរីករាយ ប៉ុន្តែចម្រៀងនោះក៏បានអប់រំឲ្យកុមារចងកំហឹងនិងមានចិត្តក្លាហាន ហ៊ានប្រើប្រាស់កាំភ្លើងតស៊ូបាញ់នឹងសត្រូវ។ ដូចតួរអង្គសត្វស្វាបានសម្តែង ដោយបានយកកាំភ្លើងមកតម្រង់បាញ់សត្រូវយ៉ាងក្លាហាន។

ខ្ញុំយល់ឃើញថា បទចម្រៀងនីមួយៗគឺល្អទៅតាមអត្ថ-ន័យនៃការអប់រំដែលអ្នកនិពន្ធបានចងក្រងឡើង។ ចំពោះការនិពន្ធបទចម្រៀងអង្គការនេះគឺមិនមែនជាចេតនាល្អសម្រាប់កុមារទេ ប៉ុន្តែផ្ទុយទៅវិញវាកាន់តែធ្វើឲ្យកុមារទទួលរងនូវឥទ្ធិពលអាក្រក់ទៅវិញ។

### ចម្រៀងអង្គការនៅក្នុងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»

ចម្រៀងអង្គការគឺជាចម្រៀង១បទដែលអ្នកនិពន្ធល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានដាក់បញ្ចូលនៅក្នុងឈុតទី៧ក្នុងចំណោមឈុតទាំង៨នៃល្ខោននេះ។ នៅក្នុងឈុតទី៧នៃល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់»បានរៀបរាប់អំពីស្ត្រីម្នាក់ ដែលធ្លាប់បានស្គាល់ក្មេងប្រុសម្នាក់នៅពេលដិះឡានជាមួយគ្នានៅក្នុងអង្គភាពយុវជនរបស់ខ្មែរក្រហម។ នាងសួរក្មេងប្រុសនោះថា តើនៅចងចាំគាត់ដែរឬទេ ហើយហេតុអ្វីបានជាក្មេងប្រុសនោះបាត់បង់ស្នាមញញឹមដ៏ស្រស់ស្អាតរបស់គាត់? បុរសនោះមិនចង់ស្គាល់នាងនោះទេ។ ដើម្បីជួយរំឭកដល់ការចងចាំរបស់បុរសម្នាក់នោះ នាងបាន

និយាយឡើងវិញនូវបទចម្រៀងនិងការចូលរួមក្នុងអង្គភាពយុវជនរបស់គាត់ទាំងពីរនាក់។

ក្រោយមក បុរសនោះបានទទួលស្គាល់ថា គាត់ពិតជាសប្បាយរីករាយណាស់នៅពេលនោះ។ ប៉ុន្តែឥឡូវនេះ គាត់ទទួលរងនូវការឈឺចាប់ពីសុបិនដ៏អាក្រក់របស់គាត់។ ដោយសារតែគាត់គឺជាអ្នករបាំ គាត់បានវាយក្មេងស្រីម្នាក់រហូតដល់ស្លាប់ព្រោះក្មេងស្រីនោះ បានហូបផ្លែឈើរបស់អង្គការ ថែមទាំងគាត់បានចាប់រំលោភក្មេងស្រីផ្សេងទៀត។ ស្ត្រីម្នាក់នោះប្រាប់បុរសនោះអំពីវិធីសាស្ត្រដែលគាត់បានបំភ្លេចសុបិនអាក្រក់របស់គាត់។ ស្ត្រីម្នាក់នោះ បានអញ្ជើញគាត់ឲ្យចូលរួមក្នុងដំណើរទស្សនកិច្ចទៅកាន់សារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលជាគុកសម្រាប់ឃុំឃាំង និងធ្វើទារុណកម្មអ្នកទោស ដែលបណ្តាលឲ្យមនុស្សស្លាប់ប្រមាណ ២០០០០នាក់ នៅក្នុងរបបខ្មែរក្រហម ដើម្បីឧទ្ទិសដល់ជនរងគ្រោះ ហើយកុំលាក់បាំងពីអំពើបាបរបស់ខ្លួន។ បុរសនោះហាក់បីដូចជាស្ទាក់ស្ទើរ។

### ប្រវត្តិល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» នៅក្នុងប្រទេសកម្ពុជា

ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» គឺជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហមតាមរយៈការស្រាវជ្រាវនិងការសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់នៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ ល្ខោននេះមាន ៨ឈុត ដែលឈុតនីមួយៗ បានឆ្លុះបញ្ចាំងរឿងរ៉ាវពិតផ្សេងៗដែលបានកើតឡើង នៅក្នុងរបបខ្មែរក្រហម រួមជាមួយបទចម្រៀងដែលបាននិពន្ធឡើងនៅក្នុងខ្មែរក្រហមទៀតផង។ អ្នកនិពន្ធជនជាតិហូឡង់២រូបគឺ អ្នកស្រី អាន់ម៉ារី ព្រីនស៍ និងអ្នកស្រី ណាន់ វ៉ាន់ ហ្វូត សហការជាមួយ អម្រឹតាសិល្បៈ ដោយមានការជ្រោមជ្រែងលើកិច្ចការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផលិតល្ខោននេះឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តដំណើរការផ្សះផ្សា និងចាប់ផ្តើមស្តារសង្គមកម្ពុជាដ៏ខ្ទេចខ្ទាំឡើងវិញ។

ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» បានចាក់បញ្ចាំងលើកទី១នៅក្នុងឆ្នាំ២០០៨ ដែលមាន៧ឈុត នៅក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានានៃប្រទេសកម្ពុជា។ រហូតមកដល់សព្វថ្ងៃ ប្រវត្តិនៃការកកើតល្ខោននិយាយនេះមានអាយុកាល១០ឆ្នាំគត់។ នៅក្នុងឆ្នាំ២០១៨ ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» ត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញដោយដាក់បញ្ចូលឈុតថ្មីមួយទៀត ដែលបន្ថែមលើខ្លឹមសារចាស់ទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហម ដែលជាតុលាការនាំយកមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៅ ក្នុងរបបខ្មែរក្រហម អំឡុងឆ្នាំ១៩៧៥ដល់១៩៧៩។

នៅក្នុងឆ្នាំ២០១៩នេះ ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» បានចាប់ផ្តើមដាក់ បញ្ចាំង សារជាថ្មីម្តងទៀតនៅក្នុងទីក្រុងភ្នំពេញ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តបាត់ដំបង។

គោលបំណងរបស់ល្ខោនទម្ងាយភាពស្ងៀមស្ងាត់ គឺដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់វ័យទទួល បានប្រយោជន៍ពីស្នាដៃនេះ តាមរយៈការប្រឈមចំពោះបញ្ហានានាទាក់ទងនឹងប្រវត្តិសាស្ត្រដ៏សោកសង្រេងដែលបានកើតមានឡើងជាមួយភាពច្នៃប្រឌិត និងសេចក្តីភ្ញាក់រព្ញក។ ល្ខោននិយាយនេះ គឺជាផ្នែកមួយជួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកវិធីសាស្ត្រសម្រាប់បំពេញដំណើរការនៃការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត ក៏ដូចជាវិធីសាស្ត្រដទៃទៀតក្នុងការបន្តដំណើរឆ្ពោះទៅមុខ។ ល្ខោននិយាយ «ទម្ងាយភាពស្ងៀមស្ងាត់» រួមចំណែកដល់ភាពចំបាច់ដ៏វិសេសវិសាលក្នុងការបញ្ចប់ភាពស្ងៀមស្ងាត់ ស្របពេលដែលល្ខោននេះក្លាយជាមធ្យោបាយក្នុងការលើកឡើងអំពីកិច្ចពិភាក្សាដើម្បីចាប់ផ្តើមការផ្សះផ្សា។

**អ៊ុន សុដារី**

# វាលវែង៖ អតីតតំបន់តស៊ូរបស់មេដឹកនាំខ្មែរក្រហម

នៅពេលដែលយើងធ្វើដំណើរទៅកាន់ទិសពាយ័ព្យក្នុងប្រទេសកម្ពុជា យើងនឹងឃើញមានភ្នំជាច្រើនតភ្ជាប់គ្នាយ៉ាងវែងអន្លាយ ដែលលាតសន្ធឹងនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ និងអមដោយទេសភាពបៃតងស្រស់បំព្រងៗ តំបន់នោះត្រូវបានដាក់ឈ្មោះឲ្យថា តំបន់វាលវែង បន្ទាប់ពីកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៦ៗ វាលវែង គឺជាឈ្មោះរបស់ស្រុកមួយនៅក្នុងខេត្តពោធិ៍សាត់ ដែលមានព្រំប្រទល់ជាប់ខេត្តកោះកុង និងស្រុកសំឡូតនៃខេត្តបាត់ដំបង ព្រមទាំងជាប់ព្រំប្រទល់ជាមួយខេត្តត្រាតនៃប្រទេសថៃៗ ថ្មីៗនេះ វាលវែង មានហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្រាលកៅស៊ូឆ្លងកាត់ ជួរភ្នំរាប់រយគីឡូម៉ែត្ររហូតដល់ព្រំដែនប្រទេសថៃ ខណៈពេលដែលផ្លូវថ្នល់មួយចំនួនទៀតកំពុងតែសាងសង់ភ្ជាប់ទៅស្រុក និងខេត្តផ្សេងៗនៅក្នុងប្រទេសកម្ពុជាៗ ដោយឡែក យើងក៏សង្កេតឃើញថាផ្លូវថ្នល់ទៅកាន់ភូមិនានាមួយចំនួន នៅក្នុងស្រុកវាលវែងកំពុងតែប្រឈមមុខក្នុងស្ថានភាពលំបាកនៅឡើយៗ ប្រជាជននៅតាមភូមិនីមួយៗ រស់នៅក្នុងផ្ទះតូចៗដាច់ឆ្ងាយពីគ្នា និងមានភាពស្ងាត់ជ្រងំ ដែលជារឿយៗនៅតាមផ្លូវយើងប្រទះឃើញមានរថយន្ត និងម៉ូតូបើកឆ្លងកាត់ម្តងម្កាលៗ ប្រជាជនភាគច្រើន ប្រកបមុខរបរធ្វើស្រែចម្ការ និងប្រជាជនមួយចំនួនទៀត ប្រកបរបរសិប្បកម្មដូចជាការកែច្នៃឈើធ្វើជាគ្រឿងសង្ហារឹមជាដើមៗ

សម្រស់ធម្មជាតិ និងភាពស្ងប់ស្ងាត់នៅស្រុកវាលវែងកំពុងតែបិទបាំងភាពអាថ៌កំបាំង និងប្រវត្តិសាស្ត្រដ៏សែន


អ៊ុំ ធុច កំពុងអង្គុយនៅខាងមុខផ្ទះ
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


ជ្រោះនៅស្រុកវាលវែង ខេត្តពោធិ៍សាត់
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

សោកសៅរបស់ខ្លួនៗ ប្រសិនបើយើងមើលដោយក្រសែភ្នែក យើងនឹងនឹកស្មានមិនដល់ថា តំបន់វាលវែងធ្លាប់បានជួបប្រទះនូវរឿងរ៉ាវដ៏សែនគ្រោតគ្រាតនៅក្នុងអំឡុងពេល និងបន្ទាប់ពីសង្គ្រាមដ៏យោរយៅនៅសម័យកាលមួយ ដែលដឹកនាំដោយក្រុមកុម្មុយនីស្តក្នុងរបបខ្មែរក្រហមៗ អស់រយៈពេលប្រហែល ៤ឆ្នាំ ក្រោមការគ្រប់គ្រងរបស់ក្រុមផ្តាច់ការខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យជីវិតរបស់ប្រជាជនហាក់បីដូចជាកំពុងរស់នៅក្នុងភពមួយងងឹតសូន្យឈឹង ដែលនៅដាច់សែនឆ្ងាយពីពិភពខាងក្រៅ និងជាលទ្ធផលនៃការដឹកនាំរបស់ក្រុមខ្មែរក្រហម ក៏បានបន្សល់ទុកនូវស្នាមរបួសដែលមិនអាចព្យាបាលបាន ជាមួយនឹងអនុស្សាវរីយ៍ដ៏សែនសង្វេគដល់ប្រជាជនកម្ពុជាជាង ៥លាននាក់ ដែលនៅរស់រានមានជីវិតបន្ទាប់ពីរបបដ៏សាហាវយោរយៅមួយនេះៗ ឆ្នាំ១៩៧៩ នៅពេលដែលកងកម្លាំងខ្មែរក្រហមចាប់ផ្តើមបែកខ្ញែក និងខ្សត់ខ្សោយ ដោយមិនអាចវាយទប់ទល់ជាមួយកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបាន មេដឹកនាំខ្មែរក្រហម កម្មាភិបាល និងកងទ័ពខ្មែរក្រហម នៅតាមតំបន់ផ្សេងៗបានរត់គេចខ្លួនទៅរស់នៅតាមបណ្តោយព្រំដែនខ្មែរ-ថៃៗ មេដឹកនាំខ្មែរក្រហមទាំងនោះ មិនបានទទួលស្គាល់ភាពបរាជ័យរបស់ខ្លួនឡើយ ហើយបានរត់គេចខ្លួនទៅរស់នៅតាមបណ្តោយជួរភ្នំក្រវាញ និងតំបន់វាលវែង ដើម្បីប្រមូលផ្តុំកម្លាំង និងរៀបចំយុទ្ធសាស្ត្រថ្មីដើម្បីផ្តួលរលំរដ្ឋាភិបាលវិញៗ នៅពេលដែលវៀតណាម បានដកកងទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ ខ្មែរក្រហមបានបញ្ជាឲ្យកងទ័ព ព្រមទាំងក្រុមគ្រួសាររបស់កងទ័ពរបស់ខ្លួនទៅរស់នៅតំបន់មួយចំនួននៅក្នុងស្រុកវាលវែងបន្ថែមទៀត ក្នុងគោលបំណងពង្រីកមូលដ្ឋានគ្រប់គ្រងៗ យើងប្រហែលធ្លាប់បានឮជារឿយៗអំពីហេតុការណ៍ ដែលបានកើតឡើងនៅតាមតំបន់កាន់កាប់របស់មេដឹកនាំខ្មែរក្រហម ដូចជា តំបន់ភ្នំវល្លិ៍ សំឡូត ម៉ាឡៃ ប៉ៃលិន អន្លង់វែង និងតំបន់ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែមានប្រជាជនតិចតួចនៅឡើយដែលបានដឹង និងនិយាយអំពីប្រវត្តិសាស្ត្ររបស់តំបន់វាលវែងនៅអំឡុងពេលនៃការគ្រប់គ្រងរបស់មេដឹកនាំខ្មែរក្រហមៗ រហូតដល់ឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលបានចាប់ផ្តើមប្រើប្រាស់គោលនយោបាយឈ្នះឈ្នះ ដើម្បីរួមបញ្ចូលខ្មែរក្រហមក្នុងសង្គមខ្មែរតែមួយវិញៗ ការចរចាគ្នាបានធ្វើឲ្យអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនបានរត់ចោលជួរមកចុះចូលជាមួយរាជរដ្ឋាភិបាល ហើយអតីតខ្មែរក្រហមទាំងនេះថែមទាំងត្រូវបានជ្រើសរើសឲ្យចូលធ្វើការក្នុងជួររាជរដ្ឋាភិបាលថែមទៀតផងៗ ទោះបីជាសង្គ្រាមបានបញ្ចប់នៅតំបន់វាលវែងហើយក៏ដោយ ក៏មិនសូវមានប្រជាជន ចំណូលថ្មីចូលមកតាំងទីលំនៅ និងរស់នៅក្នុងតំបន់នេះច្រើនដែរ បើប្រៀបធៀបទៅនឹងតំបន់ផ្តាច់ខ្លួនរបស់ខ្មែរក្រហមផ្សេងទៀត ដោយមូលហេតុជាច្រើនៗ ប្រជាជនដែលរស់នៅតំបន់វាលវែងភាគច្រើន គឺជាអតីតកម្មាភិបាល កងទ័ព និងគ្រួសាររបស់ខ្មែរក្រហមៗ

បុរសពិការម្នាក់ឈ្មោះ អ៊ុំ ធុច គឺជាអតីតយោធាខ្មែរក្រហម ដែលបានចូលមករស់នៅឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដំបូងបង្អស់ជាមួយអតីតយោធាខ្មែរក្រហមចំនួនសរុប៦០គ្រួសារ បានរៀបរាប់ពីបទពិសោធន៍តស៊ូរបស់គាត់នៅក្នុងរបបខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំ និងប្រពន្ធរបស់ខ្ញុំឈ្មោះខាត់ មឿន បានរៀបការនៅក្នុងឆ្នាំ១៩៧៣ និងមានកូនចំនួន៥នាក់គឺស្រី២នាក់ និងប្រុស៣នាក់ៗ កូនរបស់ខ្ញុំបានរៀបការកសាងគ្រួសារថ្មីអស់ចំនួន៤នាក់រួចហើយៗ សព្វថ្ងៃនេះខ្ញុំមានអាយុ៧០ឆ្នាំ រីឯប្រពន្ធរបស់ខ្ញុំមានអាយុ៦៦ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការបន្តិចបន្តួចនៅក្បែរផ្ទះៗ ខ្ញុំមានស្រុកកំណើតនៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺៗ ខ្ញុំរៀនសូត្របានតិចតួចណាស់គឺរៀនបានត្រឹមតែចេះអានអក្សរ «ក» ឬ «ខ» តែប៉ុណ្ណោះៗ ឪពុករបស់ខ្ញុំឈ្មោះ ចូត រីឯម្តាយរបស់ខ្ញុំឈ្មោះ ទិត្យ នូវៗ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូន១២នាក់ ដែលមានស្រី២នាក់ និងប្រុស១០នាក់ៗ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំមានអាយុប្រហែល១៧ឆ្នាំៗ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាទាហានបានរយៈ

ពេលប្រហែល២ឆ្នាំដែរ។ មិនយូរប៉ុន្មាន បន្ទាប់ពីរដ្ឋប្រហារទម្លាក់ព្រះមុខរដ្ឋសម្ដេច នរោត្តម សីហនុ ចេញពីតំណែង និង បន្ទាប់ពីការបោះឆ្នោតក្នុងសភា ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាយោធាខ្មែរក្រហម ក្រោយពីបានឮការប្រកាសរបស់សម្ដេច នរោត្តម សីហនុ ឲ្យបងប្អូនជនរួមជាតិខ្មែរទាំងអស់គ្នារត់ចូលព្រៃម៉ាគី ដើម្បីតស៊ូវាយផ្ដួលរំលំរបប លន់ នល់ វិញ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំបានចូលធ្វើជាទាហានប្រចាំការនៅខេត្តកំពង់ស្ពឺ និងបន្ទាប់ពីស្ម័គ្រចិត្តចូលបម្រើការងារជាយោធាខ្មែរក្រហម ខ្ញុំក៏នៅតែប្រចាំការនៅខេត្តកំពង់ស្ពឺដដែល។ មិនយូរប៉ុន្មាន ខ្ញុំបានមករស់នៅក្នុងព្រៃនៅភ្នំពីស ដែលស្ថិតនៅខាងត្បូងភ្នំឱរ៉ាល់។ នៅពេលខ្ញុំមកដល់ភ្នំពីស គឺខ្ញុំឃើញមានការរៀបចំបង្កើតជាអង្គភាពខ្លះៗរួចទៅហើយ។ ក្នុងអំឡុងពេលនោះ ខ្ញុំមិនបានដឹងថា ប៉ុល ពត គឺជាមេដឹកនាំរបបខ្មែរក្រហមនោះទេ ប៉ុន្តែខ្ញុំធ្លាប់បានឮឈ្មោះ តាម៉ុក និង ចាន់ ស៊ី ដែលស្ថិតនៅក្នុងជួរដឹកនាំ។ ចន្លោះឆ្នាំ១៩៧០ ដល់ ១៩៧១ ខ្ញុំបានធ្វើជានីរសាអស់រយៈពេលប្រហែល២ឆ្នាំ ដែលប្រធានអង្គភាពរបស់ខ្ញុំឈ្មោះ ស៊ូ គឺជាប្រធានផ្នែកនីរសាភូមិភាគនិរតី ដែលមានសមាជិកប្រហែល៣០នាក់។ ខ្ញុំធ្លាប់បានរត់សំបុត្រពីភូមិភាគនិរតី ទៅភូមិភាគពាយ័ព្យ និងទៅកាន់ខេត្តពោធិ៍សាត់ដោយជិះដំរីទៅដាក់សំបុត្រនៅតាមស្នាក់ការរបស់ខ្មែរក្រហមផ្សេងៗ។ នៅចុងឆ្នាំ១៩៧១ ខ្ញុំបានចូលបម្រើកងទ័ពក្នុងតំបន់៣២ ដែលស្ថិតនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ នៅពេលនោះ ខ្ញុំទទួលបានតួនាទីជាប្រធានវរសេនាតូចដែលគ្រប់គ្រងយោធា៣០នាក់។ នៅកំឡុងឆ្នាំ១៩៧៥ ខ្ញុំធ្លាប់ដឹកនាំយោធាប្រយុទ្ធជាមួយទាហាន លន់ នល់ នៅតាមបណ្ដោយផ្លូវជាតិលេខ៤ នៅតាជ័រ ភ្នំប្រសិទ្ធ ដែលពេលនោះយោធាតំបន់ និងភូមិភាគបានបញ្ចូលគ្នា និងមានយោធាសរុបប្រមាណជា ១.០០០នាក់ បានចេញប្រយុទ្ធ។ នៅពេលដែលយោធាខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ ខ្ញុំនៅតែបន្តរស់នៅខេត្តកំពង់ស្ពឺដដែល។ ពេលនោះហើយដែលខ្មែរក្រហមបានរំសាយខ្ញុំ ឲ្យមករស់នៅតាមមូលដ្ឋានអស់រយៈពេលប្រហែល២ឆ្នាំ ដោយសារតែខ្ញុំមានប្រវត្តិធ្វើការងារជាកងទ័ពក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំត្រូវបានខ្មែរក្រហមតាមដានជាប់រហូត នៅពេលដែលខ្ញុំរស់នៅក្នុងសហករណ៍ នៅក្នុងឃុំតាសាល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ការរស់នៅក្នុងសហករណ៍ ខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យលើកប្រព័ន្ធភ្លឺស្រែដូចប្រជាជនដទៃទៀត។ ខ្ញុំខិតខំធ្វើការងារណាស់ ទោះបីជាជួបការលំបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំស៊ូទ្រាំដែរ ព្រោះខ្ញុំគឺជាមនុស្សស្មោះត្រង់។ នៅក្នុងឆ្នាំ១៩៧៧ ឈ្មោះ ខ្លយ និង ខឹម ដែលរស់នៅឃុំតាសាល ស្រុកភ្នំស្រួច បានហៅខ្ញុំទៅធ្វើការងារជាយោធាខ្មែរក្រហមវិញ ដោយឲ្យខ្ញុំធ្វើជាយុទ្ធជននៅក្នុងយោធាតំបន់នៅខេត្តកំពង់ស្ពឺ។ ក្រោយមកក្នុងឆ្នាំ១៩៧៨ ខ្ញុំបានយកប្រពន្ធរបស់ខ្ញុំមករស់នៅជាមួយ។ តាស៊ី និង វី គឺជាក្រុមក្បត់ដែលបានធ្វើឲ្យប្រជាជនអត់បាយ ហើយត្រូវបានអង្គការចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨។ តាស៊ី មានអាយុស្រករខ្ញុំដែរ ប៉ុន្តែគាត់មានមាឌល្អិត និងពាក់វ៉ែនតា។ តាស៊ី និងក្រុមរបស់គាត់ កាចសាហាវខ្លាំងណាស់ គ្រាន់តែប្រជាជនមើលមុខក៏មិនបានដែរ។ តាស៊ី ក៏ធ្លាប់បានដាក់ទណ្ឌកម្មខ្ញុំឲ្យឈរជើងម្ខាងទៀតផង។ នៅចុងឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពវៀតណាមចូលមកប្រទេសកម្ពុជា មានព្រឹត្តិការណ៍ប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងកងទ័ពវៀតណាមយ៉ាងខ្លាំងក្លាស្ទើរគ្រប់ទីកន្លែង។ ខ្ញុំក៏បានចូលប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមនៅខេត្តកំពង់ស្ពឺដែរ ហើយក្រោយពេលប្រយុទ្ធគ្នាបានរយៈពេលប្រហែល ៦ខែ ក្រុមរបស់ខ្ញុំបានទទួលដំណឹងថាកងកម្លាំងរបស់ខ្មែរក្រហមចាប់ផ្ដើមខ្វះខាតខ្សោយទាំងកម្លាំង និងស្បៀងអាហារ ដែលធ្វើឲ្យក្រុមរបស់ខ្ញុំ ចាប់ផ្ដើមរំដោះខ្លួនទៅបោះទីតាំងនៅខាងលិចភ្នំឱរ៉ាល់។ នៅក្នុងឆ្នាំ១៩៧៩ ក្រុមរបស់ខ្ញុំចាប់ផ្ដើមអស់គ្រាប់អស់កម្លាំងរួចក៏ត្រូវបានបញ្ចូលមកនៅជាមួយភូមិភាគចំណុះកងពលតូចលេខ១៨ នៅភ្នំឱរ៉ាល់ដដែល។

ក្រោយពីបោះឆ្នោតដែលរៀបចំដោយអាជ្ញាធរបណ្ដោះអាសន្ន ហៅកាត់ថា អ៊ុន តាក់ នៅឆ្នាំ១៩៩៣ រួច ខ្មែរក្រហម

បានបញ្ជូនខ្ញុំ រួមទាំងក្រុមគ្រួសារយោធាសរុបចំនួន៦០គ្រួសារ មកពីខេត្តកំពង់ស្ពឺ ឲ្យមករស់នៅតំបន់ផ្ទះ១ (សព្វថ្ងៃជាវាលស្រែ ស្ថិតនៅក្នុងឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់)។ ខ្ញុំបានធ្វើដំណើរមកដល់តំបន់ផ្ទះ១ដំបូងគេបង្អស់ គឺឃើញមានតែសរសរផ្ទះនៅសេសសល់តែមួយដើមប៉ុណ្ណោះ។ ខ្ញុំធ្លាប់បានឮប្រជាជននិយាយតៗគ្នាថា តំបន់ផ្ទះ១នេះ គឺកសាងឡើងតាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ។ តំបន់នេះមានផ្ទះមួយខ្នង ដែលក្រុមចោររត់មកពីខេត្តផ្សេងមករស់នៅ និងលាក់ខ្លួននៅទីនេះ។ រហូតមកដល់សម័យខ្មែរក្រហមតំបន់ផ្ទះ១នេះក៏ត្រូវបានខ្មែរក្រហមប្រើប្រាស់ជាកន្លែងស្នាក់អាស្រ័យ នៅពេលធ្វើដំណើរឆ្លងកាត់ពីខេត្តបាត់ដំបង ស្រុកសំឡូត ទៅកាន់ខេត្តកោះកុង។ នៅពេលខ្ញុំមកដល់តំបន់នេះដំបូង គឺគ្មានមនុស្សរស់នៅទេ។ តំបន់នេះសម្បូរព្រៃឈើ និងសត្វព្រៃណាស់ ប៉ុន្តែក្រោយមានការទន្ទ្រានពីក្រុមឈ្មួញ។ ព្រៃឈើជាច្រើនបានដុះយ៉ាងស៊ុបទ្រុបនៅជុំវិញផ្ទះរបស់ខ្ញុំ ប៉ុន្តែបច្ចុប្បន្នមិនមានទៀតទេ ចំណែកឯដើមឈើធំៗនៅលើភ្នំក៏មិនសូវសម្បូរដែរ។ ស្ថានភាពផ្លូវថ្នល់នៅពេលនោះ គឺមានតែផ្លូវរទេះគោតែប៉ុណ្ណោះ រហូតដល់ឆ្នាំ២០០៣ ទើបមានផ្លូវលំដែលអាចធ្វើដំណើរបានខ្លះៗ។ ក្រុមគ្រួសាររបស់យោធា ៦០គ្រួសារនោះបានរស់នៅ និងបង្កើតជាភូមិមួយ។ ក្រោយៗមក ក៏មានអ្នកចំណូលថ្មីចូលមករស់នៅតាមរយៈបងប្អូនរបស់គ្រួសារយោធា និងបានជាភូមិផ្សេងៗបន្ថែមទៀត។ ប្រជាជនរស់នៅតំបន់ផ្ទះ១ គឺរស់នៅពឹងផ្អែកខ្លាំងទៅលើការធ្វើចម្ការ ប៉ុន្តែជីវភាពនៅតែមិនសូវធូរធារព្រោះឈ្មួញបានធ្វើការបញ្ចុះតម្លៃស្រេចតែចិត្តទៅលើដំឡូងសណ្តែកពោតដែលប្រជាជនដាំដុះបាន។ សព្វថ្ងៃនេះ ខ្ញុំមិនចង់បានអ្វីទៀតទេ ព្រោះតែខ្ញុំពិការជើង និងគ្មានកម្លាំងធ្វើស្រែចម្ការច្រើនដូចប្រជាជនខ្លះទៀត។ ខ្ញុំពឹងផ្អែកតែលើប្រាក់ខែចូលនិវត្តន៍សម្រាប់ចិញ្ចឹមជីវិត។ ខ្ញុំបានសម្រេចចិត្តមិនត្រឡប់ទៅរស់នៅឯស្រុកកំណើតវិញទេព្រោះខ្ញុំមានដីតិចតួចណាស់នៅទីនោះ ហើយខ្ញុំក៏មានបងប្អូនច្រើននាក់រស់នៅទីនោះដែរ។ ចំណែកឯនៅតំបន់ផ្ទះ១នេះ មានដីធំទូលាយ ងាយស្រួលរស់នៅ និងប្រកបរបររស៊ីជាងនៅស្រុកកំណើត។ បន្ទាប់ពីចាកចេញពីស្រុកកំណើត ខ្ញុំបានទៅលេងស្រុកកំណើតបានតែពីរដងតែប៉ុណ្ណោះ គឺនៅពេលម្តាយឪពុករបស់ខ្ញុំឈឺ ព្រោះស្ថានភាពផ្លូវនៅពេលនោះក៏ពិបាករឹងគ្រាប់មីនក៏នៅសេសសល់ច្រើន។ សព្វថ្ងៃនេះតំបន់ផ្ទះ១គ្មានមនុស្សរស់នៅ និងសល់ស្លាកស្នាមផ្ទះទៀតទេ។ វាបានក្លាយជាវាលស្រែរបស់ប្រជាជន។

**អ៊ុន សុដាវី**



ផ្ទះរបស់ អ៊ុំ ធុច នៅក្នុងស្រុកវាលវែងខេត្តពោធិ៍សាត់ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

# តំបន់អន្លង់វែង គឺជាទីតាំងចុងក្រោយនៃជីវិតតស៊ូរបស់ខ្ញុំ

ខ្ញុំឈ្មោះ ជួប សួរ អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិតាណង ស្រុកអណ្តូងមាស ខេត្តរតនៈគិរី។ នៅឆ្នាំ១៩៧០ ខ្ញុំបានចាកចេញពីឪពុកម្តាយ និងសាច់ញាតិបងប្អូន ដើម្បីចូលរួមក្នុងចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហមប្រឆាំងនឹងរបប លន់ នល់។ នាពេលនោះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាកងឈ្លបនៅក្នុងស្រុកអណ្តូងមាស អស់រយៈពេលពីរឆ្នាំ។ ក្នុងអំឡុងពេលនោះ ខ្ញុំ និងសមាជិកក្រុមបានដើរយាមល្បាត និងឃ្លាំមើលសភាពការណ៍ក្នុងស្រុកដើម្បីរាយការណ៍ទៅថ្នាក់លើ។ ទោះបីជាខ្ញុំដឹងថា ការងារនេះមានភាពប្រថុយប្រថានយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែខំប្រឹងប្រែងធ្វើការសព្វគ្រប់បែបយ៉ាងបម្រើទៅដល់ថ្នាក់លើ។ ការងាររបស់ខ្ញុំពិតជាប្រឈមនឹងគ្រោះថ្នាក់ខ្លាំងណាស់ពី ព្រោះសម្បូរទៅដោយគ្រាប់មីន និងការបាញ់ប្រហារពីសំណាក់ទាហាន លន់ នល់។

ពីរឆ្នាំក្រោយមក ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាយោធានៅក្នុងខេត្តរតនៈគិរី ក្រោមការបញ្ជាផ្ទាល់ពី តាសារឿន (តា០៥) ប្រធានកងពល៨០១។ នៅទីនោះ ខ្ញុំនិងកងកម្លាំងយោធាខ្មែរក្រហមបានប្រយុទ្ធតទល់ជាមួយកងទ័ព លន់ នល់ ជាញឹកញាប់។ កងទ័ព លន់ នល់ មានការគាំទ្រពីប្រទេសអាមេរិក និងមានគ្រឿងសព្វាវុធទំនើប។ ទោះបីយ៉ាងនេះក្តី ក៏កងកម្លាំងរបស់ខ្ញុំ នៅតែអាចធ្វើសង្គ្រាមតទល់ជាមួយកងទ័ព លន់ នល់ បានព្រមទាំងទទួលបានជ័យជម្នះលើសមរភូមិជាច្រើនកន្លែងទៀតផង។ រហូតដល់ឆ្នាំ១៩៧៤ ថ្នាក់លើបានបញ្ជូនខ្ញុំ និងយោធាខ្មែរក្រហមដទៃទៀតឲ្យទៅវាយប្រយុទ្ធតទល់ជាមួយកងទ័ពលន់នល់ នៅខេត្តកំពង់ឆ្នាំង។ ការប្រយុទ្ធលើកនេះ ក៏គ្មានអ្វីខុសប្លែកពីសមរភូមិនៅខេត្តរតនៈគិរីដែរ ដោយកងពល៨០១របស់ខ្ញុំ បានចូលវាយពីប៉ែកខាងលិចឆ្ពោះទៅទីក្រុងភ្នំពេញ រហូតដល់ពោធិ៍ចិនតុង។ ស្របពេលជាមួយគ្នានេះដែរ ខ្ញុំក៏ត្រូវបានថ្នាក់លើដកមកធ្វើជានីសារវិញ ដើម្បីនាំសារភ្ជាប់ពីខ្សែត្រៀមមួយទៅកាន់ខ្សែត្រៀមមួយទៀត ស្ថិតនៅក្នុងសមរភូមិប្រយុទ្ធពោធិ៍ចិនតុង។ ក្នុងការបំពេញការងារ ខ្ញុំតែងតែធ្វើដំណើរដោយថ្មើរជើងនៅលើដងផ្លូវដ៏តូចចង្អៀតដែលមានគ្រាប់មីនបង្កប់នៅអមសងខាង។ ខ្ញុំក៏ត្រូវលូនក្រាប និងគេចពីការបាញ់ប្រហាររបស់កងទ័ព លន់ នល់ ដែរ។ ខ្ញុំធ្វើជានីសាររហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះ ខ្ញុំបានគិតថា សង្គ្រាមនៅកម្ពុជានឹងត្រូវបញ្ចប់ទាំងស្រុង ហើយខ្ញុំក៏អាចវិលត្រឡប់ទៅជួបជុំក្រុមគ្រួសាររបស់ខ្ញុំនៅឯស្រុកកំណើត។ ផ្ទុយទៅវិញ បន្ទាប់ពីថ្ងៃរំដោះ ខ្មែរក្រហមមិនបានផ្តល់ឱកាសឲ្យខ្ញុំ ក៏ដូចជាយោធាខ្មែរក្រហមដទៃទៀតចាកចេញពីអង្គ



ជួប សួរ នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងស្រុកអន្លង់វែង
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភាពយោធាឡើយ។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមក៏បានប្រកាសតាមខ្ទោឃោសនសព្ទ ឲ្យកងកម្លាំងយោធាទាំងអស់ដែលនៅក្នុងទីក្រុងភ្នំពេញ រួមមានទាំងរូបខ្ញុំឲ្យបន្តឈរជើងនៅទីក្រុងភ្នំពេញរយៈពេលប្រាំមួយខែថែមទៀត។ ក្នុងអំឡុងពេលនោះ ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ ត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់ទីជនបទដាច់ស្រយាលនៅលើដងផ្លូវដ៏សែនឆ្ងាយ។ នៅក្នុងទីក្រុងភ្នំពេញពេលនោះ គឺមានវត្តមានតែយោធាខ្មែរក្រហមប៉ុណ្ណោះដែលនៅឈរជើង។ស្នូរកាំភ្លើងក៏បានបន្លឺឡើងវិញម្តងទៀតរវាងកងកម្លាំងយោធាខ្មែរក្រហម និងកងទ័ព លន់ នល់ នៅអំឡុងពេលនៃការបោសសម្អាត និងការរៀបចំទីក្រុង។ ហេតុការណ៍នេះក៏បានស្ងប់ស្ងាត់ទៅវិញក្រោយពេលយោធាខ្មែរក្រហមវាយបង្ក្រាបទៅលើកងទ័ព លន់ នល់ ទាំងស្រុង។

រយៈពេលប្រាំមួយខែក្រោយមក គឺនៅចុងឆ្នាំ១៩៧៥ ខ្ញុំត្រូវបានថ្នាក់លើដកចេញពីទីក្រុងភ្នំពេញ ឲ្យទៅឈរជើងការពារនៅព្រំដែន (កន្ទុយនាគ) ឬ១០២០ ក្នុងខេត្តរតនៈគិរី។ នៅអំឡុងពេលនោះ ខ្ញុំ និងយោធាខ្មែរក្រហមដទៃទៀត ពុំមានសិទ្ធិដើរហើរទៅទីណាឡើយ ដែលធ្វើឲ្យរូបខ្ញុំ និងយោធាដទៃទៀតហាក់ដូចជាកាន់តែឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងប្រជាជនដែលរស់នៅសមរភូមិក្រោយ។ រហូតដល់ឆ្នាំ១៩៧៦ ការប៉ះទង្គិចគ្នារវាងកងកម្លាំងខ្មែរក្រហម និងកងទ័ពវៀតណាមនៅតាមបណ្តោយព្រំដែនក៏បានផ្ទុះឡើង។ នាពេលនោះ ខ្ញុំបានត្រូវរបួសជាញឹកញាប់ដោយសារការវាយប្រហារពីសំណាក់កងទ័ពវៀតណាម។ បន្ទាប់ពីរងរបួសខ្ញុំត្រូវបានកងកម្លាំងយោធាខ្មែរក្រហមបញ្ជូនទៅសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរបស់អង្គភាពនៅទីក្រុងភ្នំពេញ។ បន្ទាប់ពីជាសះស្បើយ ខ្ញុំត្រូវបានថ្នាក់លើបញ្ជូនទៅកាន់សមរភូមិ១០២០វិញ ហើយក៏បានបំពេញការងារជាយោធាដូចមុន។ ក្នុងអំឡុងពេលនោះ សមរភូមិនៅតាមព្រំដែន១០២០ នៅតែមានស្ថានភាពតានតឹងនៅឡើយនិងមានការប្រយុទ្ធតទល់គ្នាអស់រយៈពេលយ៉ាងយូរ ដែលបណ្តាលឲ្យសមាជិកនៅក្នុងក្រុមរបស់ខ្ញុំស្លាប់អស់ជាច្រើននាក់។ ពីមួយថ្ងៃទៅមួយថ្ងៃ កងកម្លាំងរបស់ខ្ញុំក៏



ចម្ការដំឡូងមីរបស់ប្រជាជននៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ផ្តើមចុះជយ និងស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់។

រហូតដល់ចុងឆ្នាំ១៩៧៨ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាម បានសហការគ្នាវាយប្រហារជាទ្រង់ទ្រាយធំក្នុងគោលបំណងផ្តួលរំលំរបបខ្មែរក្រហមដែលបណ្តាលឲ្យកងកម្លាំងខ្មែរក្រហមរត់បែកបាក់ខ្ចាត់ខ្ចាយអស់។

ក្រោយពីខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងកងកម្លាំងដែលនៅសេសសល់ក្នុងកងពល៨០១ បាននាំគ្នារត់ចូលក្នុងព្រៃ ដើម្បីគេចចេញពីការវាយប្រហាររបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពស្ម័គ្រចិត្តវៀតណាម។ ខ្ញុំនិងកងកម្លាំងផ្សេងទៀតបានធ្វើដំណើរតាមបណ្តោយព្រំដែនចេញពីសមរភូមិ១០២០ក្នុងខេត្តរតនៈគិរី ឆ្ពោះទៅសមរភូមិក្រុងប៉ៃលិន ដោយឆ្លងកាត់តាមខេត្តនានារួមមាន ខេត្តស្ទឹងត្រែង ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបាត់ដំបង ដោយបានចំណាយពេលវេលាអស់ជាច្រើនខែ។ ក្នុងកំឡុងពេលធ្វើដំណើរកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមបានបន្តវាយប្រហារមកលើកងកម្លាំងរបស់ខ្ញុំពីក្រោយជាប់ជានិច្ច។ អ្នកដែលមានសំណាងគេចផុតពីការសម្លាប់ ក៏បានបន្តដំណើរឆ្ពោះទៅមុខទៀត ហើយអ្នកដែលស្លាប់បាត់បង់ជីវិត គឺត្រូវកប់ ឬទុកចោលនៅតាមផ្លូវ។ លុះមកដល់ក្នុងទឹកដីខេត្តឧត្តរមានជ័យ ខ្ញុំបានសម្រាកនៅអន្លង់វែងអស់រយៈពេលពីរយប់ និងបានបន្តដំណើរទៅមុខទៀតដោយឆ្លងកាត់តាមភូមិតាដេវ។ ភូមិតាដេវគឺជាភូមិចំណាស់មួយរបស់ខ្មែរក្រហម ហើយមានយោធាខ្មែរក្រហមជាច្រើនបានរត់គេចខ្លួនពីសមរភូមិខាងមុខដើម្បីមករស់នៅទីនេះ។ យោធាខ្មែរក្រហមដែលរស់នៅក្នុងភូមិតាដេវ ក៏ចាប់ផ្តើមធ្វើការបាញ់ប្រហារមកលើកងពល៨០១របស់ខ្ញុំទៀត ដោយអ្នកទាំងនោះយល់ច្រឡំថា កងពល៨០១មានទំនាក់ទំនងនិងរួមគំនិតជាមួយកងទ័ពវៀតណាម។ ការផ្ទុះអាវុធក៏បានស្ងប់ទៅវិញ បន្ទាប់ពីមានការចរចាពីប្រធានកងពលរបស់ខ្ញុំ គឺ តាសារឿន (តា០៥)។ កងកម្លាំងរបស់ខ្ញុំក៏បានបន្តដំណើរចាកចេញពីភូមិតាដេវ រហូតដល់សមរភូមិប៉ៃលិន។ ខ្ញុំនិងកងកម្លាំងដទៃទៀតបានបន្តរស់នៅទីនោះអស់រយៈពេលមួយឆ្នាំ ក៏ស្រាប់តែមានការវាយប្រហារពីសំណាក់កងទ័ពរដ្ឋាភិបាល និងកងទ័ពវៀតណាម ដូចពេលមុនៗទៀត។

មកដល់ឆ្នាំ១៩៨១ ខ្ញុំក៏បានរត់ភៀសខ្លួនបន្តទៀត ដោយឆ្ពោះទៅកាន់ខេត្តខប៊ុន នៃប្រទេសថៃ។ នៅពេលដែលទៅដល់ខេត្តខប៊ុន ខ្ញុំនិងកងកម្លាំងដទៃទៀតពុំទាន់មានការផ្គត់ផ្គង់ស្បៀងអាហារពីថ្នាក់លើនៅឡើយទេ។ ខ្ញុំនិងកងកម្លាំងផ្សេងទៀតក៏បាននាំគ្នាដើរដីកដំឡូងព្រៃ ដើម្បីយកមកបរិភោគបណ្តោះអាសន្ន។ ក្រោយមកទៀត ជំនួយស្បៀងអាហារពីប្រទេសចិនត្រូវបានដឹកជញ្ជូនមកដល់ទឹកដីថៃ ក្នុងគោលបំណងឧបត្ថម្ភដល់កងកម្លាំងរបស់ខ្មែរក្រហមដែលនៅសេសសល់។ ទោះបីជាស្បៀងអាហារបានមកដល់ទឹកដីថៃហើយក្តី ខ្ញុំនិងយោធាខ្មែរក្រហមដទៃទៀតមិនទាន់ទទួលបានស្បៀងអាហារភ្លាមៗនោះទេ ព្រោះអ្នកគ្រប់គ្រងស្បៀងអាហារដែលជាជនជាតិថៃបានសង្ស័យថា យោធាខ្មែរក្រហមដែលរត់គេចខ្លួនទាំងនេះ គឺជាកងទ័ពវៀតណាម។ ក្រោយមកទើបមានការចរចារវាងថ្នាក់ដឹកនាំខ្មែរក្រហម និងអ្នកគ្រប់គ្រងស្បៀងអាហារ ទើបខ្ញុំនិងយោធាខ្មែរក្រហមដទៃទៀតទទួលបានស្បៀងអាហារពីអ្នកគ្រប់គ្រងឃ្លាំង។

រហូតមកដល់ចុងឆ្នាំ១៩៨៩ កងទ័ពវៀតណាមបានដកចេញទាំងស្រុងពីប្រទេសកម្ពុជា។ ខ្ញុំ និងយោធាខ្មែរក្រហមដែលឈរជើងនៅខេត្តខប៊ុន ក៏បានវិលត្រឡប់មកឈរជើងនៅតំបន់អន្លង់វែងវិញ។ ទោះជាយ៉ាងនេះក្តី សង្គ្រាមរវាងកងកម្លាំងខ្មែរក្រហម និងរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តរហូតដល់ខ្មែរក្រហមបានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅចុងឆ្នាំ១៩៩៨ ទើបប្រទេសជាតិមានសុខសន្តិភាព និងសិទ្ធិសេរីភាពពេញបរិបូរណ៍ ហើយខ្ញុំក៏បានបន្តរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ រហូតមកដល់សព្វថ្ងៃនេះ។

សួត វិចិត្រ

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែមិថុនា ឆ្នាំ២០១៩ ដល់ខែសីហា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្ដុះបណ្ដាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៨ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# ខ្ញុំបានរួចរស់ជីវិត ដោយសារលាក់ប្រវត្តិរូប

ខ្ញុំឈ្មោះ ចាន់ ធឿន គឺជាប្រជាជនមួយរូបបានធំពេញវ័យចំពេលប្រទេសជាតិកើតមានសង្គ្រាម។ សព្វថ្ងៃខ្ញុំមានអាយុ ៦៨ឆ្នាំ និងមានស្រុកកំណើតនៅភូមិកណ្តោក ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ខ្ញុំមានឪពុកឈ្មោះ សេក វែន ស្លាប់នៅឆ្នាំ១៩៧២។ ឪពុករបស់ខ្ញុំគឺជាអតីតអាចារ្យវត្តកំបោរ ចំណែកម្តាយរបស់ខ្ញុំឈ្មោះ សោម សារូ ស្លាប់ក្នុងជំនាន់ ប៉ុល ពត។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ប្រុស៣ និងស្រី១។ ខ្ញុំបានរៀនសូត្រនៅសាលាវត្តកំបោរត្រឹមថ្នាក់ឧត្តមដ្ឋានក៏ឈប់រៀន។ បន្ទាប់មក ខ្ញុំបានបួសជាព្រះសង្ឃចំនួនបួនវស្សាក៏លាសិក្ខាបទវិញនៅឆ្នាំ១៩៦៨ ដើម្បីមកជួយធ្វើស្រែចម្ការឪពុកម្តាយ។


ចាន់ ធឿន ស្ថិតនៅក្នុងវត្តមួយស្ថិតនៅឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅឆ្នាំ១៩៧០ ប្រទេសជាតិក៏ជួបវិបត្តិនយោបាយមិនអាចផ្សះផ្សាគ្នាបាន ក៏កើតមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ។ ប្រទេសជាតិទាំងមូលធ្លាក់ចូលក្នុងភ្លើងសង្គ្រាមរវាងកម្លាំងខ្មែរក្រហម និងរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ពេលនោះ ខ្ញុំមានវ័យ១៨ឆ្នាំហើយ ប៉ុន្តែខ្ញុំមិនបានស្ម័គ្រចិត្តចូលបម្រើយោធាខ្មែរក្រហមជាមួយមិត្តភក្តិឡើយ គឺខ្ញុំសុខចិត្តនៅផ្ទះជាមួយឪពុកម្តាយប្រកបមុខរបរធ្វើស្រែចម្ការ។ ក្រោយមកសង្គ្រាមកាន់តែរីករាលដាល ដូច្នេះខ្ញុំមិនអាចសម្ងំលាក់ខ្លួនបានឡើយ ពីព្រោះបើខ្ញុំមិនរត់ចូលព្រៃជាមួយក្រុមចលនាខ្មែរក្រហមទេក៏ខ្ញុំមិនអាចគេចផុតពីការកេណ្ឌធ្វើជាទាហានរបស់របបសាធារណរដ្ឋខ្មែរដែរ។ ខ្ញុំត្រូវបានមេឃុំឈ្មោះ ម៉ាន កត់ឈ្មោះឲ្យជាទាហាន លន់ នល់ រួចនាំទៅសាលាស្រុកកណ្តាលស្ទឹង។ ខ្ញុំបានឃើញ យុវជនមកពីភូមិឃុំផ្សេងៗរាប់រយនាក់ និងរថយន្តធំៗចំនួន១៥គ្រឿងរង់ចាំនៅទីនោះរួចជាស្រេច។ ខ្ញុំបានឡើងលើរថយន្តជាមួយយុវជនទាំងនោះ រួចអ្នកបើកបរក៏បើករថយន្តចេញពីសាលាស្រុកកណ្តាលស្ទឹងសំដៅទៅបន្ទាយស៊ីបក្រុងតាខ្មៅ។ ពេលខ្ញុំមកដល់បន្ទាយដំបូង ប្រធានវរសេនាតូចលេខ៩៤ ឈ្មោះ ងិន រស់ ឋានៈស័ក្តិពីរ បានរៀបចំបង្កើតជាអង្គភាពតូចៗសម្រាប់ខ្ញុំរួចហើយ និងចាប់បង្រៀនខ្ញុំ រួមទាំងយុវជនទាំងផ្សេងទៀតឲ្យចេះដោះកាំភ្លើងនិងរៀនក្បួនយុទ្ធសាស្ត្រកងទ័ព ដូចជា រៀនលូនក្រាបជាដើម។ ពេលចប់វគ្គរយៈពេលមួយខែ ខ្ញុំត្រូវបានអង្គភាពបញ្ជូនទៅសមរភូមិបន្ទាយស៊ីបសត្បូរដើម្បីវាយមួយយោធាខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៧០ នៅជាយៗទីក្រុងភ្នំពេញមិនទាន់មានការវាយប្រយុទ្ធគ្នាជាមួយកងកម្លាំងខ្មែរក្រហមដូចនៅជនបទដាច់ស្រយាលទេ ប៉ុន្តែខ្មែរក្រហមមានសកម្មភាពជាសម្ងាត់នៅទីក្រុងភ្នំពេញ។ ពេលនោះ ខ្ញុំមានប្រាក់ខែ

ដូច្នេះខ្ញុំអាចដើរលេង និងជប់លៀងជាមួយមិត្តភក្តិជាញឹកញាប់។ ចំណែកមន្ត្រីរាជការនៅតាមអង្គភាព និងក្រសួងផ្សេងទៀត ក៏នាំគ្នាដើរលេងសប្បាយទៅតាមបែបប្រទេសលោកសេរីដែរ។

នៅអំឡុងពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ ប្រជាជននៅទីក្រុងភ្នំពេញសប្បាយផងកើតទុក្ខព្រួយផង ព្រោះសង្គ្រាមកាន់តែខិតជិតមកដល់។ ទោះបីយ៉ាងណាក៏មានជនបរទេសរស់នៅទីក្រុងភ្នំពេញច្រើនដែរ ហើយវត្តសាលសម្រាប់រាំរែកផឹកស៊ី និងកម្សាន្តក៏មានច្រើនកន្លែងដែរ។ វត្តសាលដែលល្បីឈ្មោះនៅពេលនោះគឺ វត្តសាលមេគង្គ។ សង្គ្រាម អសន្តិសុខ និងភាពសប្បាយហឺហារនៅតាមហាង និងវត្តសាលទាំងនោះបានធ្វើឲ្យរបបសាធារណរដ្ឋខ្មែរធ្លាក់ចូលទៅក្នុងសង្គមមានអំពើពុករលួយកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ទោះបីដឹងថា តាមទីជនបទស្រុកស្រែចម្ការប្រជាជនរស់នៅរងទុក្ខវេទនាដោយសារសង្គ្រាមទម្លាក់គ្រាប់បែក និងអត់ឃ្លានក៏ដោយ។ នៅខែមិថុនា ឆ្នាំ១៩៧០ មេបញ្ជាការ ងិន រស់ បានបញ្ជាឲ្យទាហានមួយកងអនុសេនាធំ ទៅប្រតិបត្តិការណ៍នៅសមរភូមិអ្នកលឿង និងគគីរធំដើម្បីទប់ទល់ជាមួយយោធាខ្មែរក្រហមផង និងពិនិត្យមើលជនជាតិវៀតណាមដែលមិនព្រមត្រឡប់ទៅប្រទេសវៀតណាមផង។ នៅក្នុងរបបសាធារណរដ្ឋខ្មែរមានការរឹតបណ្តឹងយ៉ាងខ្លាំង ចំពោះជនជាតិវៀតណាម ដែលចូលមករស់នៅខុសច្បាប់ក្នុងប្រទេសកម្ពុជា ដូច្នេះក៏មានការប្រកាសប្រាប់ឲ្យជនជាតិវៀតណាមទាំងនោះត្រឡប់ទៅស្រុកវិញ។ មានជនជាតិវៀតណាមខ្លះបានស្ម័គ្រចិត្តត្រឡប់ទៅប្រទេសវិញ ប៉ុន្តែក៏មានអ្នកខ្លះមិនព្រមចាកចេញដែរ ដោយសារជនជាតិវៀតណាមទាំងនោះចេះនិយាយភាសាខ្មែរ និងមានប្តីប្រពន្ធជាជនជាតិខ្មែរ។

នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ សរ សុខែម ជាអ្នករស់នៅបឹងទំពុនទីក្រុងភ្នំពេញ។ ក្នុងសម័យសង្គ្រាម ពិធីរៀបការមិនបានធំដុំទេ គឺមានតែចាស់ទុំ និងសាច់ញាតិទាំងសងខាងចូលរួម។ សូម្បីតែបងប្អូននៅស្រុកកំណើតក៏មិនបានមកចូលរួមដែរ ព្រោះតំបន់មួយកាន់កាប់ដោយខ្មែរក្រហម។ បន្ទាប់ពីខ្ញុំរៀបការ បានរយៈពេលមួយសប្តាហ៍ ខ្ញុំក៏ចេញទៅសមរភូមិនៅខាងអ្នកលឿងវិញ។ ខ្ញុំបានឡើងឋានៈជាប្រធានកងតូចកាន់កូនទាហានជាង៣០នាក់ ដឹកនាំនាវាចម្បាំងវាយខ្មែរក្រហមនៅតាមច្រាំងទន្លេ និងជួយដឹកគ្រាប់ ស្បៀងអាហារ ផ្តល់ឲ្យទាហាន លន់ នល់ ដែលប្រចាំការនៅតាមបន្ទាយ។ នៅចុងឆ្នាំ១៩៧៤ មានការប្រយុទ្ធកាន់តែខ្លាំងឡើងៗ ដោយយោធាខ្មែរក្រហមដែលទទួលជំនួយពីប្រទេសចិន កាន់តែមានប្រៀបជាងទាហាន លន់នល់ ពីមួយថ្ងៃទៅមួយថ្ងៃ។ ពេលយោធាខ្មែរក្រហមវាយបែកបន្ទាយទាហាន លន់ លន់ ម្តងៗ មានទាហាន លន់ នល់ ស្លាប់ជាច្រើន ហើយសាកសពអណ្តែតតាមទឹកទន្លេមេគង្គ ហូរចុះទៅប្រទេសវៀតណាម។

នៅក្នុងហេតុការណ៍ប្រយុទ្ធគ្នានោះ ខ្ញុំក៏ត្រូវរបួសដែរ ប៉ុន្តែសំណាងល្អអ្នកដែលនៅក្នុងអង្គភាពជាមួយគ្នាបានជួយសែងខ្ញុំដាក់លើកប៉ាល់ចម្បាំង យកមកព្យាបាលនៅមន្ទីរពេទ្យ៧០១ក្រុងភ្នំពេញ។ ខ្ញុំមានរបួសស្រាលត្រង់ស្មា។ ខ្ញុំសម្រាកព្យាបាលរបួសរយៈពេលជាងមួយខែ ទើបជាសះស្បើយ។ ខ្ញុំមិនបានត្រឡប់ទៅសមរភូមិវិញទេ។ ខ្ញុំសម្រេចចិត្តមករស់នៅជាមួយប្រពន្ធនៅម្តុំបឹងទំពុន ដោយប្រកបមុខរបរជាអ្នកកាប់ជ្រូកលក់វិញ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបានឃើញយោធាខ្មែរក្រហមចូលមកក្រុងភ្នំពេញ ហើយយោធាខ្លះក៏បាញ់រះដែរ។ ខ្ញុំឃើញទាហាន លន់ នល់ ខ្លះដែលបានលាក់ខ្លួននៅក្នុងបាននាំគ្នារត់ចេញមកក្រៅ អ្នកខ្លះបានពាក់ឯកសណ្ឋានទាហានចេញរួចចូលបន្លំខ្លួនជាមួយប្រជាជនដែលដើរចេញនៅពេលជម្លៀស។ ទាហាន លន់ នល់ ខ្លះបានចាញ់បោកខ្មែរក្រហមដោយត្រឡប់មកវិញឲ្យយោធាខ្មែរក្រហមចាប់ដាក់ឡានយកទៅបាត់។ ខ្ញុំមិនបានចាញ់បោកខ្មែរក្រហមទេ ព្រោះធ្លាប់ដឹងច្បាស់ថា យោធាខ្មែរក្រហមកាចសាហាវណាស់។ ពេលនោះខ្ញុំបាននាំប្រពន្ធកូនចេញពីភ្នំពេញតាមផ្លូវជាតិលេខ១ឆ្លងកាត់

ច្បារអំពៅរហូតទៅដល់កោះក្របី។ ខ្ញុំក៏បានជួបម្តាយបង្កើត និងបងប្អូននៅទីនោះដែរ។ បន្ទាប់មកយើងនាំគ្នាធ្វើដំណើរ បន្តទៅមុខរហូតដល់ស្រុកស្អាង។ ខ្ញុំស្នាក់នៅទីនោះបានរយៈពេលតែពីរថ្ងៃ ក៏ត្រឡប់ទៅរកស្រុកកំណើតវិញ។ នៅស្រុកកំណើតអង្គការបានចែកអង្ករ ពោតសំឡីតាមសមាជិកគ្រួសារ។ មិនយូរប៉ុន្មានអង្គការចាប់ផ្តើមប្រមូលទ្រព្យសម្បត្តិឯកជនមកដាក់រួមទាំងអស់។ អង្គការបែងចែកប្រជាជនទៅតាមកង និង ចាត់តាំងប្រជាជនទាំងប្រុសទាំងស្រីឲ្យចុះធ្វើស្រែ និងដកស្ទូង។ នៅឆ្នាំ១៩៧៥ អង្គការមានផែនការជម្លៀសប្រជាជនចេញពីភូមិ។ ខ្ញុំបានដឹងថា ប្រសិនបើខ្ញុំរស់នៅក្នុងភូមិបន្តទៀតច្បាស់ជាមានអ្នកភូមិណាម្នាក់នឹងរាយការណ៍ជូនអង្គការថា ខ្ញុំធ្លាប់ធ្វើជាទាហាន លន់ នល់ មិនខាន។ ដូច្នេះខ្ញុំក៏ស្ម័គ្រចិត្តចុះឈ្មោះមុនគេដើម្បីចាកចេញពីភូមិ។ អង្គការបានបញ្ជូនក្រុមគ្រួសារខ្ញុំ និងអ្នកភូមិជាច្រើននាក់មកភ្នំពេញ និងជិះរថភ្លើងបន្តសំដៅទៅខេត្តបាត់ដំបងក្នុងភូមិភាគពាយ័ព្យ។ ខ្ញុំបានទៅរស់នៅជើងភ្នំធិបតី ដែលជាកន្លែងលត់ដំសម្រាប់ប្រជាជនថ្មី។ អង្គការបានចាត់តាំងឲ្យប្រជាជនថ្មីទាំងនោះឲ្យធ្វើការងារធ្ងន់ធ្ងរ និងមិនឲ្យអាហារហូបចុកគ្រប់គ្រាន់។ នៅទីនោះខ្ញុំឃើញ ជនជាតិចិនកាត់ខ្មែរខ្លះដែលនិយាយប៉ៃឡាំ។ ត្រូវខ្មែរក្រហមធ្វើបាប និងយកទៅសម្លាប់ចោលនៅជើងភ្នំធិបតី។

នៅឆ្នាំ១៩៧៧ខ្ញុំនិងក្រុមគ្រួសារ ត្រូវបានអង្គការបញ្ជូនទៅធ្វើការ និងរស់នៅខាងទួលម្ទេស ស្ថិតនៅក្នុងស្រុកគាស់ក្រឡ ភូមិភាគពាយ័ព្យ ដែលមានលេខាភូមិភាគឈ្មោះ រស់ ញឹម គណៈតំបន់ឈ្មោះ វ៉ាញ គណៈស្រុកឈ្មោះ តាឃឿន និង តាផុន។ ខ្ញុំ ខិតខំធ្វើការងារបម្រើអង្គការដោយមិនហ៊ានឈប់សម្រាកឡើយ ទោះបីពេលនោះខ្ញុំមានជំងឺក៏ដោយ ហើយខ្ញុំក៏មិនដែលនិយាយអំពីប្រវត្តិខ្លួនប្រាប់ទៅដល់អ្នកដទៃដែរ។

នៅក្នុងឆ្នាំ១៩៧៧ ដដែល អង្គការតែងតែមកសួរនាំអំពីប្រវត្តិផ្ទាល់ខ្លួនរបស់ខ្ញុំ ប៉ុន្តែខ្ញុំបានកុហកថាខ្ញុំជាកូនកសិករធ្វើស្រែចម្ការ។ ពេលនោះអង្គការចង់ពិសោធន៍ក៏បានប្រគល់គោមួយនឹមសម្រាប់ភ្ជួររាស់ស្រែចម្ការ និងរទេះមួយដើម្បីដឹកស្បៀង។ នៅឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមភូមិភាគនិរតីបានចូលមកគ្រប់គ្រង ដូច្នេះកម្មាភិបាលខ្មែរក្រហមខាងភូមិភាគពាយ័ព្យមួយចំនួនត្រូវចាប់ខ្លួន រួមមានគណៈឃុំ គណៈសហករណ៍ គណៈស្រុក គណៈតំបន់រហូតដល់ភូមិភាគ។ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីចូលមកដល់មិនមានអ្វីផ្លាស់ប្តូរទេ គឺនៅតែបង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំងនិងមិនបានផ្តល់អាហារឲ្យប្រជាជនហូបចុកគ្រប់គ្រាន់ដដែល។

នៅឆ្នាំ១៩៧៩ ខ្ញុំត្រូវបានអង្គការបង្ខំឲ្យដឹកស្រូវចេញពីសហករណ៍យកទៅលាក់ទុកនៅ តាមភ្នំ។ ពេលនោះខ្ញុំមានការព្រួយបារម្ភពីសុវត្ថិភាពប្រពន្ធកូន ដែលរស់នៅក្នុងភូមិយ៉ាងខ្លាំង។ ខ្ញុំ បានបររទេះគោចេញពីក្នុងព្រៃនៅពេលយប់ចូលមកភូមិវិញ រួចហើយទុករទេះគោចោល ដើម្បីទៅរកប្រពន្ធកូន។ ខ្ញុំរកមិនឃើញប្រពន្ធ និងកូនរបស់ខ្ញុំឡើយ ដូច្នេះខ្ញុំក៏ដើរសួរនាំមនុស្សនៅតាមផ្លូវជាហូរហែ។ ខ្ញុំបានបន្តដំណើរ រហូតមកដល់ខេត្តបាត់ដំបង និងបានសម្រាកនៅទីនោះរយៈពេលបីថ្ងៃ។ ក្រោយមក ខ្ញុំមានសំណាងបានជួបប្រពន្ធកូនវិញ។ កាលនោះ ខ្ញុំមិនទាន់ចង់ត្រឡប់មកស្រុកកំណើតវិញទេ។ ខ្ញុំចង់រស់នៅខេត្តបាត់ដំបងមួយរយៈដើម្បីដើររកស្រូវអង្ករទុកហូប។ នៅទីនោះខ្ញុំឮសូរប្រជាជនដែលរស់នៅក្បែរខ្ញុំពិភាក្សាគ្នាពីការរត់ទៅព្រំដែនថៃ ដើម្បីងាយស្រួលរត់ទៅប្រទេសទីបី។ បន្ទាប់មក ខ្ញុំបានពិភាក្សាជាមួយប្រពន្ធខ្ញុំ។ លុះស្អែកឡើងខ្ញុំក៏នាំប្រពន្ធកូនរត់ចូលព្រៃសំដៅទៅព្រំដែនថៃ។ ខ្ញុំបានទៅដល់ជំរំណងចាន់ដើម្បីរង់ចាំចេញទៅប្រទេសទីបី ប៉ុន្តែខ្ញុំគ្មានសំណាង។ នៅឆ្នាំ១៩៩១ មានអង្គការបានរៀបចំបញ្ជូនជនភៀសខ្លួនឲ្យវិលត្រឡប់មកស្រុកកំណើតវិញ។ នៅពេលនោះ ខ្ញុំក៏ចុះឈ្មោះជាមួយប្រជាជនខ្មែរយើងជាច្រើនទៀត ដើម្បីវិលត្រឡប់មកស្រុកកំណើតវិញ។ សព្វថ្ងៃប្រកបមុខរបរធ្វើស្រែចម្ការ និងមកជួយធ្វើការងារនៅវត្តកំបោរ។

*សុខ វណ្ណៈ*

# ការចងចាំប្រវត្តិសាស្ត្រ និងសិល្បៈតន្ត្រីខ្មែរ

សិល្បៈ និងតន្ត្រីខ្មែរ បានផ្លាស់ប្តូរ និងវិវឌ្ឍន៍ ទៅតាមបរិបទសង្គមនយោបាយ និងភាពរីកចម្រើនរបស់ប្រទេស។ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដោយ សម្តេចព្រះនរោត្តម សីហនុ នៅទសវត្សរ៍ទី៥០ បានដាក់គោលនយោបាយអទិភាពទៅលើសិល្បៈនិងតន្ត្រី។ នៅក្នុងអំឡុងទសវត្សរ៍ទី៦០ និងដើមទសវត្សរ៍ទី៧០ សិល្បៈ និងតន្ត្រីខ្មែរ ទទួលបានការរីកចម្រើន និងប្រែប្រួលដោយសារគំនិតច្នៃប្រឌិតជាមួយការបើកទទួលយកតន្ត្រីយ៉ាងសម្បូរបែបពីបរទេសដែលបានបង្កើតនូវចក្ខុវិស័យថ្មីមួយនៃតន្ត្រី។ នៅពេលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលរវាងរដ្ឋាភិបាល លន់ នល់ (ឆ្នាំ១៩៧០-៧៥) និងកងទ័ពកុម្មុយនីស្តខ្មែរក្រហម (ឆ្នាំ១៩៧៥-៧៩) សិល្បៈ និងតន្ត្រីបានផ្លាស់ប្តូរបន្តិចម្តងៗ។ នៅក្នុងរយៈពេលជិត៥ឆ្នាំនៃការផ្ទុះឡើងសង្គ្រាមស៊ីវិលរវាងទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម ចម្រៀងត្រូវបាននិពន្ធឡើងទៅតាមស្ថានភាពនយោបាយសង្គម។

បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានផ្លាស់ប្តូរ សិល្បៈ និងតន្ត្រីខ្មែរទាំងស្រុង។ ខ្មែរក្រហមមានបំណងបង្កើតសង្គមថ្មីមួយដែលខ្មែរក្រហមតែងតែស្រមើស្រមៃចង់បាន។ ខ្មែរក្រហមបានបង្កើតក្រុមសិល្បៈ ដើម្បីបម្រើដល់នយោបាយ



ព្រឹទ្ធាចារ្យ ប៉េ ប៊ុន កំពុងលេងភ្លេងរនាថឈើ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាមួយការបញ្ចូលមនោគមវិជ្ជារបស់ខ្លួនៗ សិល្បៈថ្មីត្រូវបានបង្កើតឡើង ចំណែកឯសិល្បៈរបស់របបចាស់ (របបសង្គមរាស្ត្រនិយម និងរបប លន់ នល់) ត្រូវបានបំផ្លាញចោល។ ខ្មែរក្រហមមិនត្រឹមតែបំផ្លាញរាល់ទម្រង់នៃសិល្បៈ និងតន្ត្រីរបស់របបចាស់នោះទេ គឺថែមទាំងបានដាក់គោលដៅទៅលើសិល្បៈករទាំងឡាយ ដើម្បីយកទៅសម្លាប់ចោល។ សិល្បៈករខ្មែរ គឺជាជនរងគ្រោះនៅក្នុងចំណោមប្រជាជនកម្ពុជាជិត ២លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម តាមរយៈការបង្ខំឲ្យធ្វើការហួសកម្លាំង ការបង្អត់អាហារ ឈឺដោយគ្មានថ្នាំព្យាបាល ការធ្វើទារុណកម្ម និងការសម្លាប់។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មានសិល្បៈករខ្មែរមួយចំនួនតូចប៉ុណ្ណោះបាននៅរស់រានមានជីវិត។

វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចូលរួមចំណែកក្នុងការលើកកម្ពស់ការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការតាំងពិព័រណ៍សហសម័យ ការបញ្ចាំងខ្សែភាពយន្តឯកសារ ការធ្វើបឋកថា និងការគាំទ្រសិល្បៈខ្មែរ តាមរយៈការផ្តល់ទីតាំងដល់សិល្បៈករ ក្នុងការដាក់បង្ហាញស្នាដៃសិល្បៈរបស់ខ្លួន ថែមទាំងចងក្រងជីវប្រវត្តិសិល្បៈករ ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម។

### *ខ្សែជីវិតសិល្បៈករ ព្រឹទ្ធាចារ្យ ប៉ើ ប៊ុន នៅក្នុងរបបខ្មែរក្រហម*

ព្រឹទ្ធាចារ្យប៉ើប៊ុនបានប្រសូតនៅថ្ងៃពុធ០៩កើតខែជេស្ឋ ព.ស២៤៧១ (គ.ស១៩២៨) ស្ថិតក្នុងរជ្ជកាលព្រះបរមខត្តិយកោដ្ឋ នៅភូមិស្វាយជ្រុំឃុំស្វាយជ្រុំស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ព្រឹទ្ធាចារ្យ ប៊ុន គឺជាបុត្ររបស់លោកតា កៅ ប៉ើ ដែលជាសិល្បៈករភ្លេងពិណពាទ្យ និងភ្លេងការ និងយាយ នឹម។ ព្រឹទ្ធាចារ្យ ប៊ុន មានបងប្អូនបង្កើតសរុប១០នាក់ ក្នុងនោះស្រី៧នាក់ ប្រុស៣នាក់។ ពេលមានអាយុ១៨ឆ្នាំ ព្រឹទ្ធាចារ្យ ប៊ុន បានចូលរួមសម្តែងល្ខោនប្រាមោទ្យទ័យដែលសម្តែងជាតួ (ស្វា និង ឥសី) និងបានចាប់ចិត្តទៅលើភ្លេងពិណពាទ្យ។

គួររំឭកផងដែរថា ល្ខោនប្រាមោទ្យទ័យ គឺជាល្ខោនមួយបន្ទាប់ពីល្ខោនព្រះរាជទ្រព្យដែលមានសិទ្ធិប្រើមកុដ និងគ្រឿងតែងកាយ ដូចល្ខោនហ្លួងដែរ។ លក្ខណៈពិសេសនៃល្ខោននេះ គឺតួសម្តែង ត្រូវរាំ និងច្រៀងដោយខ្លួនឯងដោយមិនមានអ្នកច្រៀងបន្ទរឡើយ ហើយល្ខោននេះប្រគំដោយភ្លេងពិណពាទ្យ ដែលតួសម្តែងភាគច្រើនគឺជាស្ត្រី លើកលែងតែតួស្វាដែលមានលាយបុរស។

នៅឆ្នាំ១៩៥០ ព្រឹទ្ធាចារ្យ ប៊ុន បានរៀបការជាមួយលោកយាយ ស៊ឹម ហ៊ីង និងប្រសូតបានបុត្រាបុត្រីចំនួន៨នាក់ ប្រុស៤នាក់ ស្រី៤នាក់។ ឪពុករបស់ព្រឹទ្ធាចារ្យ ប៊ុន បានបង្កើតវង់ភ្លេងមួយដែលធ្លាប់ត្រូវបានសម្តេចសង្ឃរាជ ជួន ណាត អញ្ជើញឲ្យទៅលេងនៅពេលមានកម្មវិធីផ្សេងៗ។ វង់ភ្លេងរបស់ព្រឹទ្ធាចារ្យ ប៊ុន មិនស្ថិតនៅក្នុងក្របខណ្ឌព្រះបរមរាជវាំងទេ។ ព្រឹទ្ធាចារ្យ ប៊ុន បានបញ្ជាក់ថា «បើវង់ភ្លេងវាំង ទទួលប្រាក់ខែវាំង ដូច្នេះវង់ភ្លេងវាំងមិនអាចចេញទៅលេងនៅខាងក្រៅបានទេ»។ ព្រឹទ្ធាចារ្យ ប៊ុន បានដើរលេងភ្លេងរហូតដល់ឪពុករបស់គាត់ស្លាប់។

បន្ទាប់ពីរដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីអំណាច និងការបង្កើតរបបសាធារណរដ្ឋខ្មែរ ព្រឹទ្ធាចារ្យ ប៊ុន បានបន្តការងារសិល្បៈជាអ្នកលេងភ្លេងដូចធម្មតា។ ក្រៅពីការលេងភ្លេងនៅតាមកម្មវិធីផ្សេងៗ ព្រឹទ្ធាចារ្យ ប៊ុនក៏បានធ្វើស្រែចម្ការ ដើម្បីជួយសម្រួលជីវភាពគ្រួសារ។ ព្រឹទ្ធាចារ្យ ប៊ុន បានលើកឡើងថា សិល្បៈ និងតន្ត្រីមានការផុសផុល រីកចម្រើនខ្លាំង ហើយសិល្បៈករទទួលបានការគោរពស្រឡាញ់ច្រើន។ នៅក្នុងរបបសាធារណរដ្ឋខ្មែររបស់លន់នល់ព្រឹទ្ធាចារ្យ ប៊ុន បានធ្វើជាប្រធានកង៥០ខ្ទង ដែលត្រូវបានបង្កើតឡើងចាប់តាំងពីជំនាន់សង្គមរាស្ត្រនិយម ដើម្បីគ្រប់គ្រងប្រជាជនមូលដ្ឋាន និងចែកគ្រឿងសម្ភារប្រើប្រាស់ផ្សេងៗ។ នៅឆ្នាំ១៩៧៤ ភូមិកំណើតរបស់ព្រឹទ្ធាចារ្យ

ប៉ុន គឺជាសមរភូមិក្តៅ រវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហម។ ព្រឹទ្ធាចារ្យ ប៉ុន និងគ្រួសារបានរត់គេចខ្លួនមកត្រើយម្ខាងក្នុងទីក្រុងភ្នំពេញ ហើយក្រោយមកគាត់បានស្នាក់នៅជាយក្រុង ស្ថិតនៅម្តុំវត្តក្តីតាកុយ។

បន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រឹទ្ធាចារ្យ ប៉ុន និងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសមកភូមិកំណើត នៅឃុំស្វាយជ្រុំវិញ។ នៅពេលមកដល់ភូមិកំណើត ផ្ទះរបស់ព្រឹទ្ធាចារ្យ ប៉ុនត្រូវបានភ្លើងឆេះអស់គ្មានសល់ ហើយព្រឹទ្ធាចារ្យផ្ទាល់ក៏ត្រូវបានមេភូមិខ្មែរក្រហមចោទថាជានាយទុន។ បន្ទាប់ពីខ្មែរក្រហមបានដឹងថា ព្រឹទ្ធាចារ្យ ប៉ុន ចេះលេងភ្លេងខ្មែរ ខ្មែរក្រហម ក៏បានជ្រើសរើសព្រឹទ្ធាចារ្យឲ្យចូលធ្វើការក្នុងក្រុមសិល្បៈខ្មែរក្រហម។ ក្រុមសិល្បៈរបស់ព្រឹទ្ធាចារ្យ ប៉ុន មានសមាជិកទាំងអស់ចំនួន៤នាក់ រួមមាន ឈ្មោះ គ្រឹក ឈ្មោះសាម ឈ្មោះ ពុំ និងឈ្មោះ ប៉ុន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឈ្មោះ លីន។ ក្រុមសិល្បៈរបស់ព្រឹទ្ធាចារ្យ ប៉ុន ត្រូវបានខ្មែរក្រហម យកទៅលេងភ្លេងឲ្យអ្នកចម្រៀងបដិវត្តន៍។ ចំណេះដឹងភ្លេងបុរាណ និងភ្លេងពិណពាទ្យ បានជួយសង្គ្រោះព្រឹទ្ធាចារ្យ ប៉ុន ឲ្យរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។ ព្រឹទ្ធាចារ្យ ប៉េ ប៉ុន គឺជាសិល្បៈករខ្មែរផ្នែកតន្ត្រីបុរាណម្នាក់ ក្នុងចំណោមសិល្បៈករខ្មែរមួយចំនួនតូច ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម។

### ខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច ខ្មែរបាត់បង់តន្ត្រីរ៉ក់»

«កុំស្មានបងភ្លេច ខ្មែរបាត់បង់តន្ត្រីរ៉ក់» គឺជាខ្សែភាពយន្តឯកសារស្តីពីប្រវត្តិសិល្បៈ និងតន្ត្រីខ្មែរនៅទសវត្សរ៍ទី៦០ និង៧០។ កុំស្មានបងភ្លេច បានបង្ហាញពីទស្សនវិស័យ និងសុទិដ្ឋិនិយមរបស់ប្រទេសកម្ពុជា ដែលធ្លាប់បានឆ្លងកាត់សង្គ្រាម និងអំពើប្រល័យពូជសាសន៍។ នៅពេលខ្មែរក្រហមបានឡើងកាន់អំណាចថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមការកសាងសង្គមបរិសុទ្ធថ្មីមួយ។ បញ្ញវន្ត សិល្បៈករ និងតន្ត្រីករ ត្រូវបានយកទៅសម្លាប់ ហើយប្រជាជនធម្មតាត្រូវបានបង្ខំឲ្យធ្វើការនៅជំរំពលកម្មនៅទីជនបទ។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម នៅឆ្នាំ១៩៧៩ សិល្បៈករ និងតន្ត្រីករខ្មែរតិចតួចណាស់បានរួចផុតពីការកាប់សម្លាប់របស់ខ្មែរក្រហម និងចាប់ផ្តើមស្តារឡើងវិញនូវសិល្បៈ និងតន្ត្រីខ្មែរ។ គួរបញ្ជាក់ថា ខ្សែភាពយន្តឯកសារ **«កុំស្មានបងភ្លេច»** បានរួមបញ្ចូលជាមួយចម្រៀង៧២បទ និងរឿងរ៉ាវរបស់សិល្បៈករខ្មែរ ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីពន្យល់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដល់សិស្ស និស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទូទៅនៅក្នុងប្រទេសកម្ពុជា និងទូទាំងពិភពលោក។

### ពិព័រណ៍សហសម័យ៖ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា»

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយសាលាជំនាញសិល្បៈសូន្យរូបហ្វាពន្ធីសិល្បៈ បានផ្តួចផ្តើមរៀបចំការតាំងពិព័រណ៍សហសម័យស្តីអំពី ៖ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា»។ «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា» ជាបណ្តុំនៃរូបគំនូរសហសម័យចំនួន១៩ផ្ទាំង ដែលជាស្នាដៃសិល្បៈរបស់និស្សិតផ្នែកសិល្បៈនៃសាលាជំនាញសូន្យរូបហ្វាពន្ធីសិល្បៈ។

ខ្មែរក្រហម បានបំផ្លាញមិនត្រឹមតែខ្លួនប្រាណ ក៏ប៉ុន្តែភាពក្លាហាននៃគំនិតស្រមៃ ពីព្រោះប្រជាជនកម្ពុជាបានបន្តរស់នៅក្នុងភាពភ័យខ្លាច ដោយសារខ្មែរក្រហមបានបន្តធ្វើសង្គ្រាមទ័ពព្រៃ នៅតាមបណ្តោយព្រំដែនខ្មែរថៃ អស់រយៈពេលជាច្រើនឆ្នាំទៀត។ ពិព័រណ៍សហសម័យនេះ បានជំរុញឲ្យមានការកកើតឡើងវិញ នៃសេចក្តីក្លាហានស្រមើស្រមៃតាមរយៈការប្រើប្រាស់សិល្បៈ និងទស្សនវិស័យថ្មីនៃក្មេងជំនាន់ក្រោយរបស់ប្រទេសកម្ពុជា។ បន្ថែមលើនេះទៀត ស្នាដៃសិល្បៈនៃគំនូរសហសម័យ ក៏ជំរុញការយល់ដឹងពីអត្តសញ្ញាណស្ថាបត្យកម្មខ្មែរ ដែលត្រូវបានបំផ្លាញស្ទើរតែ

ទាំងស្រុងដោយសារសង្គ្រាម និងការស្តារឡើងវិញនៃរចនាបទសំណង់អគារខ្មែរដែលទទួលឥទ្ធិពលពីសាកលភាវូបនីយកម្ម ទៅលើគំនិតក្នុងស្ថាបត្យកម្ម នៅទីក្រុងភ្នំពេញ នាពេលបច្ចុប្បន្ន និងអនាគត។

**«ប្រសិនបើមិនមានសង្គ្រាមនិងអំពើប្រល័យពូជសាសន៍នៅកម្ពុជា»** ត្រូវបានដាក់តាំងបង្ហាញឲ្យសិស្សនិស្សិតសិល្បៈករ អ្នកស្រាវជ្រាវ និងសាធារណជនទូទៅចូលទស្សនា រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ស្ថិតនៅក្នុងអាគារHនៃវិទ្យាស្ថានជាតិអប់រំ។

*ព្រាំ គិតម៉ាន់ និង ណុប សុវណ្ណឧត្តម*



ហ្កាថាណា និស្សិតច្បាប់មកពីសកលវិទ្យាល័យ Canterbury Christ Church នៃចក្រភពអង់គ្លេស
(រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ» ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញភារកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទេ្ទសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។






***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្តាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជា ការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ៕

# អង្គជំនុំជម្រះសាលាដំបូង
# សេចក្តីសង្ខេបសាលក្រមសំណុំរឿង០០២/០២
## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

*(តពីលេខមុន)*

*១.៣.២ សហករណ៍ និងការដ្ឋានការងារ*

១៤. អង្គជំនុំជម្រះយល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើតនិងដំណើរការសហករណ៍ និងការដ្ឋានការងារ ដែលត្រូវបានចាត់ទុកជាឧបករណ៍សំខាន់សម្រាប់ ការតស៊ូវណ្ណៈ និងមានគោលដៅបង្កើតកម្លាំងពលកម្ម និងកម្លាំងផលិតរបស់ប្រជាជន ក្រោមការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។ ទីតាំងឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ គឺសហករណ៍ត្រាំកក់ ការដ្ឋានការងារទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់ ១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

១៥. ចំពោះសហករណ៍ត្រាំកក់ ដែលស្ថិតនៅស្រុកត្រាំកក់ តំបន់ ១៣ ភូមិភាគនិរតី (បច្ចុប្បន្នខេត្ត តាកែវ) អង្គជំនុំជម្រះយល់ឃើញថា ប្រជាជនត្រូវបានគេបង្ខំដោយចេតនាឲ្យធ្វើការងារក្រោម បរិយាកាសនៃការគ្រប់គ្រង ការគំរាមកំហែង ការភ័យខ្លាច ការអត់អាហារ និងរើសអើង។ កង្វះអាហារខ្លាំងបានកើតមានច្រើនដងនៅក្នុងស្រុកត្រាំកក់ ហើយបានធ្វើឲ្យមនុស្សស្លាប់។ មនុស្សជាច្រើនបានស្លាប់ដោយសារតែកង្វះអាហាររូបត្ថម្ភ ធ្វើការបាក់កម្លាំង និងមានជំងឺ។ ប្រជាជនថ្មី ដែលមកពីទីក្រុង និងទីរួមខេត្ត ខុសពីប្រជាជនមកពីតំបន់ជនបទដែលគេហៅថា ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់នោះ បានទទួលរងផលប៉ះពាល់ទាំងនេះជាពិសេស។ លើសពីនេះទៀត ប្រជាជនបានស្លាប់ក្នុងមន្ទីរពេទ្យស្រុក ក្នុងចំណោមទីតាំងផ្សេងៗទៀត ដោយសារតែការព្យាបាលមិនសមស្រប កង្វះអាហាររូបត្ថម្ភ និងធ្វើការបាក់កម្លាំង។ អង្គជំនុំជម្រះក៏យល់ឃើញដែរថា មនុស្សជាច្រើននាក់បានបានបាត់ខ្លួននៅស្រុកត្រាំកក់ ដោយគ្មានដំណើរការតាមផ្លូវច្បាប់ ដែលតាមរយៈដំណើរការនេះ ប្រជាជនអាចស្វែងរក និងទទួលបានព័ត៌មានយ៉ាងត្រឹមត្រូវអំពីជោគវាសនាសាច់ញាតិរបស់ខ្លួន។ ស្ថានភាពនេះបានបង្កើតឲ្យមានបរិយាកាសភ័យខ្លាច និងភាពមិនច្បាស់លាស់ជាបន្តទៅទៀត។ លើសពីនេះ ការប្រណិប័តន៍សាសនា និងវប្បធម៌ប្រពៃណីត្រូវបានលុបបំបាត់ដោយបង្ខំនៅស្រុកត្រាំកក់។ អង្គជំនុំជម្រះក៏យល់ឃើញថា ប្រជាជនត្រូវគេគ្រប់គ្រងទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយសារថា ពួកគេត្រូវបានរឹតត្បិតសេរីភាពក្នុងការដើរហើរ ត្រូវចូលរួមប្រជុំទិតៀន និងស្វ័យទិតៀន បាត់បង់របនាសម្ព័ន្ធគ្រួសារដែលមាន និងទទួលរងការគំរាមកំហែងថានឹងបញ្ជូនទៅអប់រំ ចាប់ខ្លួន ឬបាត់ខ្លួន។ ទង្វើទាំងនេះ គឺជាការបំពាក់បំប៉ន ការគំរាមកំហែង ការរឹតត្បិត សេរីភាពក្នុងការដើរហើរ ការធ្វើពលកម្មដោយបង្ខំ ការភ័យខ្លាច និងអំពើហិង្សា ដែលស្ថិតក្រោម ការគ្រប់គ្រងយ៉ាងតឹងរ៉ឹង។

១៦. ចំពោះការដ្ឋានការងារទំនប់ត្រពាំងថ្មដែលស្ថិតនៅតំបន់ ៥ ភូមិភាគពាយព្យ (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការត្រូវបានគេបង្ខំឲ្យសង់ទំនប់មួយ និងអាងស្តុកទឹកពីរ ដែលជារចនាសម្ព័ន្ធសំណង់រួមមួយ ដែលដំណើរការរហូតមកទល់សព្វថ្ងៃ នេះហើយនៅតែមានទ្រង់ទ្រាយដើមដដែល។ អ្នកធ្វើការនៅទំនប់នេះគ្មានជម្រើសអ្វីផ្សេងក្រៅពីត្រូវ ធ្វើការដោយមិនគិតពីស្ថានភាពអាកាសធាតុ ត្រូវធ្វើការធ្ងន់ជាច្រើនម៉ោង មិនត្រូវបានគេអនុញ្ញាត ឲ្យមានថ្ងៃឈប់សម្រាក ត្រូវបានមេកងតាមដាន

ជាប្រចាំ ដើម្បីពិនិត្យមើលថា តើពួកគេបំពេញ ការងារបាន ប៉ុន្មាន និងត្រូវដាក់ពិន័យបើសិនពួកគេមិនបានសម្រេចការងារតាមផែនការ។ អ្នកធ្វើការត្រូវគេគំរាមកំហែងថា នឹងត្រូវសម្លាប់ ឬបាត់ខ្លួន ឬត្រូវគេកាត់បន្ថយរបបអាហារ បើពួកគេមានអាកប្បកិរិយាដែលគេចាត់ទុកថាប្រឆាំងនឹងអង្គការ ឬបើពួកគេមិនសម្រេចភារកិច្ច ដែលបានប្រគល់ឲ្យ។ សាក្សីបានឃើញអ្នកធ្វើការត្រូវបានគេសម្លាប់នៅនឹងមុខ ហើយត្រូវបានគេគំរាមកំហែងថា នឹងត្រូវគេសម្លាប់ដែរ បើមិនប្រឹងធ្វើការ។ អង្គជំនុំជម្រះយល់ឃើញថា ការស្លាប់នៅការដ្ឋានមិនត្រឹមតែបណ្ដាលមកពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅលំបាកវេទនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដោយសារតែការសម្លាប់ដោយចេតនាផងដែរ។

១៧. ចំពោះការដ្ឋានការងារទំនប់ ១ មករា ដែលស្ថិតនៅតំបន់ ៤២ និងតំបន់ ៤៣ ភូមិភាគ កណ្ដាល (ខេត្តរបាស់) (បច្ចុប្បន្នខេត្តកំពង់ធំ) អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅមានភាពលំបាកវេទនាដូចគ្នាខ្វះអាហារ និងមានការព្យាបាលមិនគ្រប់គ្រាន់ដូចគ្នា។ អ្នកធ្វើការនៅទីនោះក៏គ្មានជម្រើសអ្វីឡើយ ដោយពួកគេត្រូវគេបង្ខំឲ្យធ្វើការជុំយនឹងឆន្ទៈរបស់ខ្លួន និងក្រោមលក្ខខណ្ឌលំបាកខ្លាំងបំផុត ដែលជាហេតុបណ្ដាលឲ្យស្លាប់ក្នុងករណីខ្លះ។ លើសពីនេះទៀត អ្នកធ្វើការខ្លះត្រូវបានគេសម្លាប់ចោលដោយចេតនា។ វត្ថុបារាយណ៍ជាន់ដែក នៅក្បែរនោះជាកន្លែងដែលគេរកឃើញអដ្ឋិធាតុ និងសម្លៀកបំពាក់ជាច្រើន ក្រោយរបបកម្ពុជាប្រជាធិតេយ្យដួលរលំ ត្រូវបានគេប្រើប្រាស់ជាកន្លែងឃុំឃាំង និងសម្លាប់មនុស្ស។ អ្នកធ្វើការខ្លះត្រូវ បានគេផ្ទេរពី ការដ្ឋានការងារទំនប់ ១ មករា ទៅកន្លែងនោះ ហើយត្រូវបានគេសម្លាប់ចំណែកឯអ្នកធ្វើការខ្លះ ទៀតបានបាត់ខ្លួនតែម្ដង។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិចាម និងប្រជាជនថ្មី ត្រូវបានគេ រើសអើងខ្លាំងនៅក្នុងការដ្ឋានការងារនេះ។ ក្នុងអំឡុងសាងសង់ អ្នកធ្វើការនៅ



អតីតមន្ទីរសន្តិសុខវត្តចំពុះក្អែក ក្នុងរបបខ្មែរក្រហម (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការដ្ឋានទំនប់ ១មករា មានចំនួនរាប់ម៉ឺននាក់ គឺចន្លោះពី ២០.០០០នាក់ ទៅ ៤០.០០០នាក់ ក្នុងពេលការងារមមាញឹកបំផុត។

១៨. ចំពោះការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំងដែលស្ថិតនៅតំបន់ ៣១ ភូមិភាគបស្ចិម(បច្ចុប្បន្នខេត្តកំពង់ឆ្នាំង) អង្គជំនុំជម្រះយល់ឃើញថា អ្នកធ្វើការនៅការដ្ឋាននេះ គឺជាកងទ័ពមកពីតាមកងពលនានានៃកងទ័ពបដិវត្តន៍កម្ពុជា។ ការងារដែលពួកគេធ្វើ គឺសម្រាប់គោលបំណងយោធា។ ទោះជាយ៉ាងណាក៏ដោយ អ្នកធ្វើការត្រូវគេប្រើឲ្យធ្វើការងារដូចទាសករ និងមិនអាចប្រកែកមិនធ្វើការងារបានឡើយ បើមិនដូចច្នេះទេពួកគេទទួលរងការគំរាមកំហែង ហើយក្នុងករណីខ្លះបាត់ខ្លួន។ ពួកគេទទួលដំណឹងថា អ្នកមិនគោរពតាមការណែនាំនឹងត្រូវដកចេញ ឬសម្លាប់ចោល។ អង្គជំនុំជម្រះយល់ឃើញទៀតថា អ្នកធ្វើការប្រឈមមុខនឹងលក្ខខណ្ឌការងារគ្មាន សុវត្ថិភាព និងត្រូវគេបង្ខំឲ្យធ្វើការច្រើនម៉ោងដោយគ្មានអាហារគ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យមនុស្សជាច្រើនស្លាប់។ កងទ័ពមកពីភូមិភាគបូព៌ាឬកងពលដែលមេដឹកនាំរបស់ពួកគេត្រូវបានគេ ចាត់ទុកថាជាជនក្បត់ត្រូវធ្វើការងារធ្ងន់ឬប្រកបដោយគ្រោះថ្នាក់ខ្លាំង ដើម្បីកសាងខ្លួន។ ជាពិសេស ការវាយថ្មមានហានិភ័យខ្ពស់ ហើយអ្នកធ្វើការស្ទើរតែគ្មានមធ្យោបាយអ្វីដើម្បីការពារខ្លួនឡើយ។ ជីវិតរបស់ពួកគេត្រូវបានចាត់ទុកដូចជាឧបករណ៍ប្រើប្រាស់។ នៅទីបំផុត អ្នកធ្វើការជាច្រើននាក់ បានបាត់ខ្លួនដោយគ្មានដំណឹង និងលែងឃើញនៅការដ្ឋានការងារទៀត ចំណែកឯអ្នកផ្សេងទៀតត្រូវបានគេចាប់ខ្លួន ហើយក្រោយមក ក៏បាត់ខ្លួន ឬត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។

១៩. អង្គជំនុំជម្រះយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចតទៅនេះត្រូវបានប្រព្រឹត្ត ទាក់ទងនឹងការបង្កើត និងដំណើរការសហករណ៍ និងការដ្ឋានការងារ។ ឧក្រិដ្ឋកម្មទាំងនោះ មានការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ អំពីអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។

### ១.៣.៣. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

២០. អង្គជំនុំជម្រះយល់ឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយបង្កើត និងដំណើរការនៅមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដើម្បីកំណត់អត្តសញ្ញាណ ចាប់ខ្លួនដាក់ឲ្យនៅដាច់ដោយឡែកតែម្នាក់ឯង និង «កម្ទេច» អ្នកដែលគេចាត់ទុកជាខ្មាំងប្រភេទធ្ងន់ធ្ងរបំផុត។ ទីតាំងឧក្រិដ្ឋកម្មដែលជាផ្នែកមួយនៃសំណុំរឿង ០០២/០២ គឺមន្ទីរសន្តិសុខ ស-២១ (រួមទាំង ទីតាំងសម្លាប់មនុស្សនៅ



អដ្ឋិធាតុរបស់ជនរងគ្រ

ជើងឯក) មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

២១. ចំពោះមន្ទីរសន្តិសុខ ស-២១ ដែលស្ថិតនៅវិទ្យាល័យពញាយ៉ាត ក្នុងទីក្រុងភ្នំពេញ ស្ទើរតែពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះយល់ឃើញថា មន្ទីរសន្តិសុខ ស-២១ បានចាប់ផ្តើមដំណើរការយូរបំផុតនៅខែតុលា ឆ្នាំ១៩៧៥។ មន្ទីសន្តិសុខ ស-២១ មានមុខងារចម្បងក្នុងការឃុំខ្លួនបក្ខជន និងយុទ្ធជនបដិវត្តន៍ ដែលត្រូវគេសង្ស័យថាជាខ្មាំង។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ត្រូវគេឃុំឃាំង ដោយគ្មានការការពារ តាមនិតិវិធីច្បាប់ឡើយ ហើយលក្ខខណ្ឌឃុំឃាំង


...គ្រោះនៅខេត្តស្វាយរៀង

មានសភាពគួរឲ្យអាណោចអាធ័ម ដែលជាហេតុធ្វើឲ្យអ្នកជាប់ឃុំខ្លះស្លាប់។ ថ្វីត្បិតតែអ្នកជាប់ឃុំខ្លះ ត្រូវគេប្រើឲ្យធ្វើការងារជាបណ្តោះអាសន្ន តែអ្នកជាប់ឃុំស្ទើរតែទាំងអស់ត្រូវគេសួរចម្លើយ ដោយប្រើវិធីធ្វើបាបខុសៗគ្នាមុននឹងយកទៅសម្លាប់ចោល។ អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំត្រូវគេនាំទៅបន្ទប់សួរចម្លើយទាំងដៃ ជាប់ខ្នោះ បិទមុខ និងជើងជាប់ច្រវ៉ាក់ក្នុងពេលសួរចម្លើយ។ វិធីសួរចម្លើយរួមមានការវាយដំនឹងដំបង ព្រនង់ ខ្សែភ្លើង រំពាត់ និងឧបករណ៍ផ្សេងៗទៀតការឆក់ខ្សែភ្លើងការគ្របក្បាលនឹងថង់ប្លាស្ទិកឲ្យថប់ដង្ហើម ការយកក្រណាត់រុំមុខ ការចាក់ទឹកត្រដាក់ពីកំសៀវ និងការដកក្រចកដៃ ក្រចកជើង។ អ្នកជាប់ឃុំខ្លះបានស្លាប់ ក្រោយពីត្រូវបានគេបូមឈាមចេញ យកឈាមទៅព្យាបាល កងទ័ពបដិវត្តន៍កម្ពុជា ដែលបានរងរបួស។ អង្គជំនុំជម្រះយល់ឃើញទៀតថា យ៉ាងហោចណាស់ អ្នកជាប់ឃុំចំនួន ១១.៧៤២ នាក់ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ឬនៅជុំវិញនោះនិងនៅជើងឯក។ ឧទាហរណ៍នៅជើងឯក អ្នកជាប់ឃុំត្រូវគេសម្លាប់ដោយវាយនឹងដែកត្រង់កញ្ចឹងក រួចអារកនឹងកាំបិត ហើយសាកសពត្រូវគេវះពោះ និងកប់ក្នុងរណ្តៅសាកសពរួមៗ អង្គជំនុំជម្រះក៏យល់ឃើញដែរថា មានការណែនាំផ្ទាល់ពីថ្នាក់លើរួមទាំង នួន ជា និង សុន សេន ឲ្យសម្លាប់អ្នកជាប់ឃុំ ឬក្រុមអ្នកជាប់ឃុំ។ ក្នុងចំណោមអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ មានបក្ខជនសំខាន់ៗដូចជា រស់ ញឹម និង វន វេត ព្រមទាំងអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏ដូចជាទាហាន និងជនស៊ីវិលវៀតណាម។ បញ្ជីអ្នកជាប់ឃុំនៃមន្ទីរសន្តិសុខ ស-២១ ក៏បង្ហាញឲ្យឃើញផងដែរថា កុមារជាច្រើនត្រូវបានគេឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខនេះ និងនៅជើងឯក នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

២២. មន្ទីរសន្តិសុខក្រាំងតាចាន់ដែលស្ថិតនៅស្រុកត្រាំកក់ ខាងលិចក្រុងតាកែវ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៣ និងបន្តដំណើរការ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះយល់ឃើញថា អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខនេះ ត្រូវបានឃុំខ្លួនដោយគ្មានការការពារតាមនិតិវិធីច្បាប់ និង ក្រោមលក្ខខណ្ឌគួរឲ្យខ្លាច ត្រូវគេបង្ខំឲ្យអង្គុយទាំងជាប់ខ្នោះ និងច្រវ៉ាក់ រួមគ្នាជាជួរ លើកម្រាលអាគារឃុំឃាំង។ អ្នកជាប់ឃុំមួយចំនួនដែលភាគច្រើនជាប្រជាជនថ្មីដែលត្រូវគេសម្លាប់ភ្លាមៗក្រោយពីត្រូវបានបញ្ជូនទៅដល់មន្ទីរសន្តិសុខក្រាំងតាចាន់ ដោយគ្មានសួរចម្លើយឡើយ។ អ្នកជាប់ឃុំជាច្រើនទៀតត្រូវបានគេសួរចម្លើយរយៈពេលពីរ បីសប្តាហ៍ ក្រោយពីមកដល់។ អង្គជំនុំជម្រះយល់ឃើញថា ជារឿយៗ ការសួរចម្លើយនៅមន្ទីរសន្តិសុខក្រាំងតាចាន់មាន ការវាយដំ ការទាត់ធាក់ និងការធ្វើឲ្យថប់ដង្ហើមស្ទើរស្លាប់ ហើយការធ្វើបាបបែបនេះបានបណ្តាលឲ្យអ្នកជាប់ឃុំខ្លះបានស្លាប់។ អ្នកជាប់ឃុំជាច្រើនក៏បានបាត់ខ្លួនផងដែរ។ អង្គជំនុំជម្រះយល់ឃើញទៀតថាមានរបបការងារសម្រាប់អ្នកជាប់ឃុំមួយ ចំនួនតូចដែលត្រូវគេប្រើដើម្បីជាប្រយោជន៍បក្ស ហើយក្នុងករណីជាច្រើន ពួកគេត្រូវបានសម្លាប់ចោលផងដែរ។

២៣. មន្ទីរសន្តិសុខអូរកន្សែងដែលស្ថិតនៅតំបន់១០២ ភូមិភាគឦសាន (បច្ចុប្បន្នខេត្តរតនគិរី)ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ហើយបន្តដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថាមន្ទីរសន្តិសុខអូរកន្សែងត្រូវគេប្រើជាជំនួយដល់មន្ទីរសន្តិសុខ ស-២១ សម្រាប់ឃុំខ្លួននិងលត់ដំអ្នកប្រព្រឹត្តកំហុសស្រាលមកពីភូមិភាគឦសានចំណែកឯកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងកម្មាភិបាលនៃកងពល៨០១ ដែលត្រូវបានចាប់ខ្លួនមកពីភូមិភាគឦសាន ត្រូវបានគេបញ្ជូនទៅឃុំខ្លួន និងសម្លាប់ជាញឹកញាប់នៅមន្ទីរសន្តិសុខ ស-២១។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ មកជនស៊ីវិលដែលមិនមានដំណែងជាន់ខ្ពស់រួមទាំងអ្នកធ្វើការមកពីសហករណ៍ និងសហដីពចម្ការកៅស៊ូ នៅទូទាំងភូមិភាគឦសានក៏ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែងផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌនៃការឃុំខ្លួនមានភាពខុសគ្នារវាងអ្នកដែលត្រូវបានគេចោទប្រកាន់ថា បានប្រព្រឹត្តកំហុសស្រាលស្ទើរ និងកុមារ។ អ្នកដែលគេចាត់ទុកថាគ្រោះថ្នាក់ ត្រូវគេដាក់ច្រវ៉ាក់ ឬខ្នោះជាប់រហូតក្នុងអាគារឃុំឃាំងជាប់ដោយខ្សែក។ អ្នកប្រព្រឹត្តកំហុសស្រាល ក៏ដូចជាស្ត្រី និងកុមារមិនត្រូវបានគេដាក់ខ្នោះ ច្រវ៉ាក់ ឬមិនត្រូវបានគេដាក់ក្នុងបន្ទប់ឃុំឃាំងឡើយ។ អង្គជំនុំជម្រះក៏យល់ឃើញថា អ្នកជាប់ឃុំត្រូវគេសួរចម្លើយតាមរយៈការវាយដំ ការទាត់ធាក់ និងការឆក់ខ្សែភ្លើងដោយប្រើខ្សែទូរស័ព្ទ ឬមធ្យោបាយប្រហាក់ប្រហែល។ អង្គជំនុំជម្រះមិនអាច ជឿឲ្យហួសពីវិមតិសង្ស័យថា អ្នកជាប់ឃុំដែលគេគិតថា មិនអាចកែប្រែបានត្រូវគេសម្លាប់ទាំងអស់ ដោយគ្មានការលើកលែងនោះទេ ក៏ប៉ុន្តែអង្គជំនុំជម្រះជឿជាក់ថា ការសម្លាប់ពិតជាកើតមានមែន។ លើសពីនេះទៀត អ្នកខ្លះស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន។ អង្គជំនុំជម្រះយល់ឃើញទៀតថា ជនជាតិចារ៉ាយយ៉ាងហោចណាស់ ១០០នាក់ ដែលក្នុងនោះ រួមមានទាំងបុរស កុមារ និងស្ត្រីប្រហែល ៥នាក់ ត្រូវគេឃុំខ្លួននៅមន្ទីរសន្តិសុខអូរកន្សែង នៅពាក់កណ្តាលឆ្នាំ១៩៧៧។ ក្រោយពីត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខនេះ បានប្រហែលមួយសប្តាហ៍ ជនជាតិចារ៉ាយទាំងនេះ ត្រូវបានគេបណ្តើរចេញពីកន្លែងឃុំឃាំង រួចនាំទៅសម្លាប់ចោល។ អង្គជំនុំជម្រះជឿជាក់ថា បទបញ្ជាឲ្យសម្លាប់ជនជាតិចារ៉ាយ ត្រូវបានបញ្ជូនតាមរយៈ សុន សេន និង សូ សារឿន មេបញ្ជាការកងពល ៨០១ ដោយមានការចូលរួមពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ទៅឲ្យបុគ្គលិកនៅមន្ទីរសន្តិសុខនេះដើម្បីអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះ មិនអាចជឿឲ្យហួសពីវិមតិសង្ស័យថាជនជាតិចារ៉ាយដែលទំនងជាអតីតទាហាននៃរបប សាធារណរដ្ឋវៀតណាមខាងត្បូង ឬត្រូវបានគេសន្មតបែបនេះគឺជាជនដែលត្រូវទទួលបានការការពារ នៅក្នុងអត្ថន័យនៃអនុសញ្ញាទីក្រុងហ្សឺណែវនោះឡើយ។ **(នៅមានត)**

***អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា***

# ការលើកឡើងពីអតីតកាល គឺជាការផ្សះផ្សា និងព្យាបាលរបួសផ្លូវចិត្ត

ល្ខោននិយាយ«ទម្លាយភាពស្ងៀមស្ងាត់» គឺជាសាច់រឿងល្ខោនដែលដកស្រង់ចេញពីរឿងរ៉ាវពិតរបស់អ្នករស់រានមានជីវិតក្រោយរបបខ្មែរក្រហម តាមរយៈការស្រាវជ្រាវនិងការសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតជនដៃដល់ខ្មែរក្រហមនៅតាមភូមិឃុំនានាក្នុងប្រទេសកម្ពុជា។ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» មានទាំងអស់៨ឈុត ដែលឈុតនីមួយៗមានរឿងរ៉ាវផ្សេងៗគ្នា និងធ្លាប់បានសម្តែងនៅតាមបណ្តាភូមិឃុំមួយចំនួននៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលបច្ចុប្បន្ន។ នៅក្នុងឆ្នាំ២០១៨ ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ត្រូវបានដាក់បញ្ចូលសាច់រឿងថ្មីមួយទៀត ទាក់ទងនឹងដំណើរការស្វែងរកយុត្តិធម៌របស់សាលាក្តីខ្មែរក្រហមដែលហៀបនឹងបញ្ចប់នាពេលដ៏ខ្លីខាងមុខ និងកម្មពារទៅតាមធម៌ព្រះពុទ្ធ។ សាច់រឿងចំនួន៨ឈុតនៃល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» បានឆ្លុះបញ្ចាំងអំពីភាពសោកសង្រេងនៃការបែកបាក់ ការបាត់បង់មនុស្សជាទីស្រឡាញ់ ភាពមិនទុកចិត្តគ្នា អំពើ


យាយ លុយ សំរិទ្ធ នៅវត្តប្រាសាទនគរបាជ័យ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


ប្រាសាទនគរបាជ័យ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


ប្រាសាទនគរបាជ័យ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


ប្រជាជននិងគរុសិស្សរង់ចាំទស្សនាល្ខោននិយាយទម្លាយភាពស្ងៀមស្ងាត់ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃោរឃៅ គំនុំគុំកួនដែលពិបាកក្នុងការអភ័យទោសសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម។

មកដល់សព្វថ្ងៃ មានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតប្រមាណតែពរូបប៉ុណ្ណោះ ត្រូវបានកាត់ទោសដោយសាលាក្តីខ្មែរក្រហមឲ្យជាប់គុកអស់មួយជីវិត រីឯអតីតជនដៃដល់ខ្មែរក្រហមថ្នាក់មូលដ្ឋាន កំពុងរស់នៅលាយឡំជាមួយជនរងគ្រោះនៅឡើយ។ អស់រយៈពេល៤០ឆ្នាំមកហើយ ដោយសារមិនមានការកាត់ទោស និងមានការចោទប្រកាន់ អតីតជនដៃដល់ខ្មែរក្រហមថ្នាក់មូលដ្ឋានទាំងនោះបានរស់នៅជាប្រជាជនសាមញ្ញ មានសេរីភាពប្រកបរបរចិញ្ចឹមជីវិត និងមានកូនចៅទៅរៀននៅសាលាដូចប្រជាជនដ៏ទៃ។ ចំណែកជនរងគ្រោះកំពុងរស់ក្នុងភាពមន្ទិលសង្ស័យ អស់សង្ឃឹម គ្មានដំណឹងពីសាច់ញាតិ ឪពុកម្តាយបងប្អូនដែលបានស្លាប់ ឬបាត់ខ្លួននៅក្នុងអំឡុងរបបខ្មែរក្រហម និងនៅតែមិនអស់ចិត្តពីយុត្តិធម៌ដែលខ្លួនទទួលបានពីសាលាក្តីខ្មែរក្រហម។ ជាមួយនឹងការបាត់បង់ដ៏ធំធេង និងភាពលំបាកវេទនា ដែលទទួលរងពីការប្រព្រឹត្តរបស់ក្រុមខ្មែរក្រហម បានធ្វើឲ្យការឈឺចាប់របស់ជនរងគ្រោះនៅតែបន្តកើតមាន និងក្លាយទៅជាជំងឺបាក់ទឹកចិត្តដែលមិនអាចព្យា-បាលបាន។ នៅពេលបច្ចុប្បន្នទាំងជនរងគ្រោះ និងអតីតជនដៃដល់ខ្មែរក្រហមថ្នាក់មូលដ្ឋានបានរស់នៅ និងបានទំនាក់ទំនងគ្នាក្នុងជីវភាពរស់ប្រចាំថ្ងៃ។ ប៉ុន្តែរឿងរ៉ាវដែលមិនបានលើកមកនិយាយគឺ អំពើឃោរឃៅរបស់អតីតជនដៃដល់ខ្មែរក្រហមទាំងនោះ ដែលនៅតែលាក់បាំង និងមិនត្រូវបានលាតត្រដាងនៅឡើយ។ ទំនៀមទម្លាប់ប្រពៃណី ការគោរពប្រណិ-ប័តន៍ និងជំនឿទៅលើកម្មផលនៅក្នុងសង្គមកម្ពុជា បានធ្វើឲ្យអំពើឃោរឃៅ ដែលប្រព្រឹត្តដោយអតីតជនដៃដល់ខ្មែរ-ក្រហមកាន់តែរសាត់ឆ្ងាយ ខណៈដែលអតីតជនដៃដល់ ជនរងគ្រោះ រួមទាំងសាក្សីនៃរបបខ្មែរក្រហម កាន់តែមានវ័យចំណាស់។

នៅពេលមានការចង់ដឹងកាន់តែច្រើន អំពីការប្រព្រឹត្តរបស់អតីតជនដៃដល់នៃរបបខ្មែរក្រហមពីក្មេងៗជំនាន់ក្រោយ មានរឿងរ៉ាវកាន់តែតិចតួចប៉ុណ្ណោះត្រូវបានលើកមកនិយាយ ដោយសារតែដំណើរការយុត្តិធម៌របស់សាលាក្តីខ្មែរនឹងបញ្ចប់នាពេលឆាប់ៗខាងមុខ ដែលមានន័យថា មានជនដៃដល់ខ្មែរក្រហមតែប៉ុន្មានរូបប៉ុណ្ណោះ ដែលត្រូវបានតុលាការរកឃើញថា បានប្រព្រឹត្តឧក្រិដ្ឋកម្ម និងត្រូវបានផ្តន្ទាទោសជាមួយការចេញសាលក្រមឲ្យជាប់គុកអស់មួយជីវិត។ ចំណែកជនដៃដល់ខ្មែរក្រហមថ្នាក់មូលដ្ឋានដែលនៅសេសសល់ គឺបានរួចផុតពីការចោទប្រកាន់ ហើយអតីតជនដៃដល់មួយចំនួនក៏បានចាត់ទុកខ្លួនឯងថា ជាជនរងគ្រោះដូចប្រជាជនកម្ពុជាដទៃទៀតដែរ ដែលទទួលបញ្ជា ឬការបង្ខិតបង្ខំពីមេដឹកនាំខ្មែរក្រហម។ រឿងរ៉ាវរបស់ជនរងគ្រោះ និងជនដៃដល់ បានធ្វើឲ្យមានភាពចម្រូងចម្រាស់សម្រាប់ការគិតរបស់ក្មេងជំនាន់ក្រោយដែលមានយាយតា ឪពុកម្តាយ បងប្អូនឆ្លងកាត់ និងស្លាប់នៅក្នុងរបបខ្មែរក្រហម ដែលទាមទារឲ្យមានការបកស្រាយ និងពិភាក្សាគ្នា។ ដំណើរការផ្សះផ្សាជាតិនឹងអូសបន្លាយ និងរាំងស្ទះនៅពេលរឿងរ៉ាវឧក្រិដ្ឋកម្មអតីតកាលមិនត្រូវបាននិយាយចេញមក។

នៅក្នុងឈុតទី៨នេះ អ្នកនិពន្ធបានបញ្ចូលនូវសាច់រឿងពិភាក្សារបស់ក្មេងប្រុសម្នាក់ ដែលកើតក្រោយរបបខ្មែរក្រហម ដែលបានស្តាប់ឮការជជែករបស់អតីតកម្មាភិបាលនៃរបបខ្មែរក្រហមដែលធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម និងការសម្លាប់។ ក្មេងប្រុសម្នាក់នោះមានការងឿងឆ្ងល់យ៉ាងខ្លាំង និងសូមឲ្យជនដៃដល់ទាំងនោះបកស្រាយរឿងរ៉ាវអតីតកាល និងអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ក្មេងប្រុសនោះក៏បានលើកឡើងពីការគុំកួនរបស់ឪពុកគាត់ជាមួយអតីតកម្មាភិបាលខ្មែរក្រហម ថែមទាំងហាមគាត់មិនឲ្យទៅលេង ឬមានទំនាក់ទំនងជាមួយកូនៗរបស់អតីតខ្មែរក្រហម ដែលត្រូវជាមិត្តភក្តិរបស់គាត់ទៀតផង។ ប៉ុន្តែក្មេងប្រុសនោះមិនហ៊ានសួរឪពុកគាត់ថា មូលហេតុអ្វីបានជាហាមឃាត់គាត់។ ក្មេងប្រុសនោះមិនបានសួរសំណួរ

នេះ រហូតដល់ឪពុករបស់គាត់បានស្លាប់ជាមួយការចងចាំ កំហឹង ការស្អប់ ការគុំគួន និងការឈឺចាប់។

នៅក្នុងឈុតនេះក៏មានបានលើកឡើងពីព្រះពុទ្ធដីកាថា យើងកើតមកជាមួយអំពើបាប។ ទង្វើពីមុនរបស់យើងនឹងនាំយើងទៅរកអ្វីដែលយើងកំពុងធ្វើនៅពេលបច្ចុប្បន្ន។ ប្រសិនបើយើងមិនជឿទៅលើទង្វើនិងលទ្ធផលដែលចេញមកពីទង្វើទាំងនេះទេ យើងនឹងមិនអាចរស់នៅបានសេចក្តីសុខឡើយសម្រាប់ជីវិតរបស់យើងឡើយ។ ការផ្តន្ទាទោសដោយតុលាការចំពោះជនដែលប្រព្រឹត្តបទឧក្រិដ្ឋ ការអត់ឱន និងការអភ័យទោសក៏ត្រូវបានលើកមកពិភាក្សានៅក្នុងឈុតនេះដែរ។ បន្ទាប់ពីក្មេងប្រុសនោះបានស្តាប់ការបកស្រាយរបស់អតីតជនដៃដល់ និងអ្នកចូលរួមពិភាក្សារួចមក បានធ្វើគាត់មានអារម្មណ៍ធូរស្បើយ។

ប្រជាជនកម្ពុជាប្រមាណ៩៥ភាគរយបានប្រតិបត្តិ និងមានជំនឿយ៉ាងមុតមាំទៅលើព្រះពុទ្ធសាសនា។ ប្រជាជនកម្ពុជាទាំងនេះបានរស់នៅជាមួយភាពស្ងៀមស្ងាត់ និងមិនចងកម្មពារគ្នាឡើយ រួមទាំងអតីតជនដៃដល់ខ្មែរក្រហម។

នៅអំឡុងពេលមានការរៀបចំសម្តែង ល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់» ខ្ញុំបានជួបសម្ភាសន៍ប្រជាជនកម្ពុជាដែលមានអាយុខុសៗគ្នា ខ្លះបានកើតក្រោយរបបខ្មែរក្រហម ខ្លះទៀតជាមនុស្សជំនាន់មុនដែលបានឆ្លងកាត់របបខ្មែរក្រហម។ អ្នកផ្តល់បទសម្ភាសន៍ទាំងនោះមានទស្សនៈយល់ឃើញស្រដៀងគ្នាទាក់ទងនឹងកម្មផល ជាជាងផ្តោតទៅលើដំណើរការយុត្តិធម៌នៅសាលាក្តីខ្មែរក្រហម ៖

ផាត ស្រីណា គឺជាគរុសិស្សឆ្នាំទី១ ផ្នែកប្រវត្តិវិទ្យា មកពីស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ បានរៀបរាប់ថា៖ យាយរបស់ខ្ញុំត្រូវបានឈ្លប់ខ្មែរក្រហមនៅក្នុងភូមិយកទៅសម្លាប់ ចំណែកជីតារបស់ខ្ញុំបានបើកឡានកិនលើគ្រាប់មីនបណ្តាលឲ្យផ្ទុះស្លាប់នៅអំឡុងពេលបំពេញបេសកម្ម។ ម្តាយរបស់ខ្ញុំបានរស់នៅកំព្រាឪពុកម្តាយ ហើយត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅរស់នៅក្នុងកងកុមារ។ រៀងរាល់ពេលដែលម្តាយខ្ញុំពិបាកចិត្ត ម្តាយខ្ញុំតែងតែលើកយករឿងរ៉ាវពីអតីតកាលរបស់គាត់មកនិយាយប្រាប់ខ្ញុំ ហើយគាត់បានយំ។ ដោយសារខ្ញុំដឹងពីទំហំនៃការឈឺចាប់ និងភាពរន្ធត់របស់ម្តាយខ្ញុំនៅក្នុងរបបខ្មែរក្រហម ដូច្នេះខ្ញុំមិនបានសួរនាំគាត់ពីរឿងរ៉ាវអតីតកាលរបស់គាត់ឡើយ ព្រោះខ្ញុំគិតថានឹងធ្វើឲ្យគាត់រឹតតែឈឺចាប់ថែមទៀត។ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីខ្ញុំរៀននៅថ្នាក់ទី១០។ ខ្ញុំបានរស់នៅជាមួយបងប្រុសដែលធ្វើជាគ្រូបង្រៀនថ្នាក់បឋមសិក្សា និងបងប្អូនបង្កើត៦នាក់ទៀត។ ខ្ញុំធ្លាប់បានធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតបឹងជើងឯក។ ខ្ញុំបានឃើញប្រជាជន រួមទាំងកុមារស្លាប់នៅទីនោះ ដែលដូចទៅនឹងការរៀបរាប់របស់ម្តាយខ្ញុំដែរ។

ស្រីណា បានបន្តថា ប្រសិនបើខ្ញុំកើតក្នុងអំឡុងហេតុការណ៍នៃការកាប់សម្លាប់របស់ខ្មែរក្រហម ខ្ញុំប្រាកដជាខឹងនឹងអតីតជនដៃដល់ និងចង់សងសឹកវិញ។ ប៉ុន្តែតាមធម៌របស់ព្រះពុទ្ធដែលលើកឡើងពី «កម្មពារ» ដូច្នេះអ្នកប្រព្រឹត្តនឹងទទួលកម្ម។ អតីតជនដៃដល់ខ្មែរក្រហមនឹងជួបផលអាក្រក់របស់ខ្លួននៅថ្ងៃណាមួយមិនខាន ហើយជនដៃដល់ក៏នឹងមិនអាចរស់នៅបានសេចក្តីសុខដែរ។

ឯម សំអឿន គឺជាគរុសិស្សឆ្នាំទី២ ផ្នែកភាសាអង់គ្លេស-ខ្មែរ មកពីខេត្តត្បូងឃ្មុំបានរៀបរាប់ថា ខ្ញុំបានដឹងរឿងរ៉ាវពីរបបខ្មែរក្រហមតាមរយៈឪពុករបស់ខ្ញុំនិយាយប្រាប់ថា កាលសម័យនោះកុមារខ្មែរក្រហមម្នាក់ប៉ុណ្ណោះ អាចចាប់ចងប្រជាជន និងបណ្តើរមនុស្សធំរាប់រយនាក់ដោយមិនមានការតបតឡើយ ដោយសារតែប្រជាជននៅសម័យនោះបាក់ស្បាត។ ប្រសិនបើប្រជាជនទាំងនោះប្រឆាំង ប្រាកដជាក្មេងនោះរាយការណ៍ទៅថ្នាក់លើ ហើយយោធាខ្មែរក្រហមមកពីកន្លែងផ្សេង មកបង្ក្រាបប្រជាជនទាំងនោះមិនខាន។ នៅក្នុងភូមិរបស់ខ្ញុំមានអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ទឹម ដែលធ្លាប់ប្រព្រឹត្តអាក្រក់។ ប្រជាជននៅក្នុងភូមិជាច្រើនបានដឹងអតីតកាលរបស់ ទឹម ប៉ុន្តែដោយសាររឿងរ៉ាវបានកន្លង

ផុតទៅយូរឆ្នាំ ទើបប្រជាជនមិនមានការចងគំនុំជាមួយគាត់ ហើយសព្វថ្ងៃគាត់បានរស់នៅជាប្រជាជនសាមញ្ញ។ ខ្ញុំមិនដែលបានជួប និងបានសួរអំពីប្រវត្តិរបស់គាត់ទេ។ ខ្ញុំក៏មិនបានស្អប់ និងគុំគួនគាត់ដែរព្រោះគាត់មិនបានប្រព្រឹត្តអាក្រក់តមកទៀត ហើយគាត់ក៏មិនបានសម្លាប់សាច់ញាតិរបស់ខ្ញុំដែរ។ ប្រសិនបើខ្ញុំសងសឹកជាមួយគាត់ គឺខ្ញុំមានទោសកំហុសមិនខាន។ ខ្ញុំគិតថា គាត់គ្រាន់តែទទួលបញ្ជាពីថ្នាក់លើប៉ុណ្ណោះ។ ដោយសារប្រជាជនក្នុងភូមិបានដឹងពីតួនាទីរបស់គាត់ក្នុងរបបខ្មែរក្រហម ដូច្នេះខ្ញុំគិតថា គាត់នឹងមិនអាចលាក់ប្រវត្តិរបស់គាត់បានឡើយ ហើយគាត់នឹងនិយាយអំពីរឿងរ៉ាវរបស់គាត់។ ថ្ងៃណាមួយនៅពេលខ្ញុំមានឱកាស ខ្ញុំនឹងសួរនាំគាត់ថា មូលហេតុអ្វីបានជាគាត់ចូលរួមជាមួយខ្មែរក្រហម ប៉ុន្តែខ្ញុំមិនហ៊ានសួរគាត់ពីបទឧក្រិដ្ឋដែលធ្លាប់ប្រព្រឹត្តទេ។

លាង លាប គឺជាគរុសិស្សឆ្នាំទី២ ផ្នែកភាសាអង់គ្លេស-ខ្មែរ មកពីខេត្តត្បូងឃ្មុំបានរៀបរាប់ថា ខ្ញុំនឹងមិនហ៊ានសួរនាំអតីតជនដៃដល់ខ្មែរក្រហមទេ ព្រោះខ្ញុំភ័យខ្លាចអ្នកទាំងនោះគុំគួន និងខឹងខ្ញុំ។ ម្តាយរបស់ខ្ញុំធ្លាប់បានរៀបរាប់អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ខ្ញុំ រួមទាំងកម្មាភិបាលខ្មែរក្រហមម្នាក់ដែលធ្លាប់ប្រព្រឹត្តអាក្រក់នៅក្នុងភូមិ ប៉ុន្តែខ្ញុំមិនដែលបានសួរនាំម្តាយរបស់ខ្ញុំអំពីកម្មាភិបាលនោះទេ ព្រោះខ្ញុំគិតថាវាជារឿងរ៉ាវដែលត្រូវលាក់បាំង និងរឿងផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ។ កម្មាភិបាលនោះក៏មិនបានរស់នៅជិតផ្ទះរបស់ខ្ញុំដែរ។

លុយ សំរិទ្ធ អាយុ៧៩ឆ្នាំ បច្ចុប្បន្នជាដូនជី និងមកសុំសីលនៅវត្តនគរបាជ័យជារៀងរាល់ថ្ងៃបានរៀបថា ខ្ញុំនៅតែមានការខឹងសម្បារ និងស្អប់ខ្មែរក្រហមរហូតមកដល់សព្វថ្ងៃ។ ខ្មែរក្រហមបានមកហៅប្តីរបស់ខ្ញុំចេញពីផ្ទះដោយប្រាប់ថា យកទៅរៀនសូត្រ ព្រោះប្តីរបស់ខ្ញុំបានធ្វើឲ្យកូនក្របីដែលអង្គការប្រគល់មកឲ្យគាត់ចិញ្ចឹម វង្វេងបាត់ពីមេ។ បន្ទាប់ពីឈ្លបខ្មែរក្រហមយកប្តីខ្ញុំចេញទៅ ស្រាប់តែកូនក្របីបានរត់ត្រឡប់មករកមេរបស់វានៅក្នុងភូមិវិញ ប៉ុន្តែប្តីរបស់មិនបានវិលត្រឡប់មកវិញទេ។ ខ្ញុំបានតាមស៊ើបសួរដំណឹងប្តីរបស់ខ្ញុំពីឈ្លបខ្មែរក្រហមដែលបានបណ្តើរប្តីរបស់ខ្ញុំចេញទៅ ប៉ុន្តែខ្ញុំមិនដែលទទួលដំណឹងពីប្តីរបស់ខ្ញុំឡើយ។ ជាផលកម្មអាក្រក់ ក្រោយមកឈ្លបខ្មែរក្រហមនោះ និងប្រពន្ធក៏បានស្លាប់ទៅដែរ។ ចំណែកខ្ញុំបានរស់នៅជាស្ត្រីមេម៉ាយ រងទុក្ខវេទនាដែលត្រូវចិញ្ចឹមបីបាច់កូន៥នាក់ ក្រោយរបបខ្មែរក្រហមបានដួលរលំទៅ។ ប្រសិនបើប្តីរបស់ខ្ញុំនៅមានជីវិត ខ្ញុំក៏មិនលំបាកវេទនាតែម្នាក់ឯងដែរ។ រហូតមកដល់សព្វថ្ងៃខ្ញុំក៏មិនចង់និយាយជាមួយអតីតខ្មែរក្រហមទាំងនោះដែរ។ ខ្ញុំមកវត្តរាល់ថ្ងៃដើម្បីសន្សំបុណ្យកុសល និងកុំឲ្យមានកម្មពារជាមួយខ្មែរក្រហមទាំងនោះទៀត។

ជំនឿលើកម្មផលបានធ្វើឲ្យជនដៃដល់រស់នៅយ៉ាងស្ងៀមស្ងាត់ និងគ្មានការរំខាន ចំណែកជនរងគ្រោះបានរស់នៅជាមួយការចងចាំពីភាពឈឺចាប់ រងទុក្ខវេទនាដែលគ្មានថ្ងៃបំភ្លេចជារៀងរហូត។ ដូច្នេះហើយទើបយន្តការនៃការរកយុត្តិធម៌ និងដំណើរការផ្សះផ្សារបួសផ្លូវចិត្តតាមរយៈការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម រួមទាំងការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតឲ្យមានកម្មវិធីជាច្រើន ដូចជាការដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជននិងកីឡា ការបារីកពាក្យស្លោកដែលនិយាយពីរបបខ្មែរក្រហម ការផ្សះផ្សា ការអត់ឱន អធ្យាស្រ័យគ្នានៅតាមសាលារៀន វេទិការអប់រំសាធារណៈ វគ្គបណ្តុះបណ្តាលគ្រូប្រវត្តិសាស្ត្រ និងការសម្តែងល្ខោននិយាយ «ទម្លាយភាពស្ងៀមស្ងាត់»។

ការសម្តែងល្ខោននិយាយ បានធ្វើឲ្យមានការជជែកពិភាក្សា និងរំឭកឡើងវិញ ពីអតីតកាលក្នុងអន្តរជំនាន់ (មនុស្សជំនាន់មុន និងមនុស្សជំនាន់ក្រោយ) ដែលជាដំណើរការនៃការផ្សះផ្សា និងវិធីព្យាបាលរបួសផ្លូវចិត្តដ៏មានប្រសិទ្ធភាព។

**សោម ប៊ុនថន**

# ការសិក្សាស្វែងយល់ប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ

មជ្ឈមណ្ឌលឯកសារកម្ពុជា ដាក់អាទិភាពលើការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម, ការចងក្រងឯកសារ និងការសិក្សាស្រាវជ្រាវ។ ជាមួយការរួមបញ្ចូលគំនិតផ្តួចផ្តើមនៃការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម និងការស្រាវជ្រាវ មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់វិធីសាស្ត្រអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការតាំងពិព័រណ៍សិល្បៈ ល្ខោន អក្សរសិល្ប៍ និងការផ្តល់សក្ខីកម្មដែលអនុញ្ញាតឲ្យសិស្សនិស្សិត អ្នកស្រាវជ្រាវ និងសាធារណជនទូទៅ ទាំងនៅប្រទេសកម្ពុជា និងទូទាំងពិភពលោកស្វែងយល់យ៉ាងទូលំទូលាយទៅលើរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហម។ នេះជាគោលបំណងដើម្បីលើកកម្ពស់ការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម។

នៅព្រឹកថ្ងៃសៅរ៍ ១១រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩ និស្សិតអន្តរជាតិចំនួន១២នាក់ នៃមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវបរិស្ថាន ដឹកនាំដោយលោកស្រីបណ្ឌិត លីសា អារ៉ែនសេន បានមកធ្វើទស្សនកិច្ចសិក្សានៅវិចិត្រសាល សិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលស្ថិតក្នុងអាគារ H នៃវិទ្យាស្ថានជាតិអប់រំ។

នៅក្នុងដំណើរទស្សនៈកិច្ចសិក្សានេះ និស្សិតទាំងអស់ទទួលបានកម្មវិធីអប់រំប្រវត្តិសាស្ត្រ រួមមាន ៖

១) ពិព័រណ៍សិល្បៈសហសម័យ ៖ «មិនផុតរលត់» «សំណេះសំណាល់សង្គ្រាម» និង «ប្រសិនបើមិនមានសង្គ្រាម និងអំពើប្រល័យពូជសាសន៍ នៅកម្ពុជា, បានចូលរួមក្នុងការលើកកម្ពស់ការស្វែងយល់ និងការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម។

២) ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ ៖ «កុំស្មានបងភ្លេចៈខ្មែរបាត់បង់តន្ត្រីរ៉ក់» បានឆ្លុះបញ្ចាំងពីរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជាជាច្រើន ជាមួយភាពសម្បូរបែបនៃសិល្បៈ និងចម្រៀងខ្មែរ នៅទសវត្សរ៍ទី៦០ និងទសវត្សរ៍ទី៧០ និងការបាត់បង់នូវវីរសិល្បៈករ សិល្បៈការនីខ្មែរ រួមមាន លោក ស៊ិន ស៊ីសាមុត និងអ្នកស្រី រស់ សេរីសុទ្ធា និងអ្នកសិល្បៈជាច្រើនដទៃទៀតនៅក្នុងរបបខ្មែរក្រហម។ ខ្សែភាពយន្តឯកសារនេះ ក៏បានបង្ហាញពីសោកនាដកម្ម និងសង្គ្រាមនានាដែលធ្លាក់ទៅលើប្រជាជនកម្ពុជា។

៣) ជំនួបពិភាក្សាស្វែងយល់ពីការផ្សះផ្សា ការចងចាំ និងយុត្តិធម៌ នៅក្នុងប្រទេសកម្ពុជា ជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ប្រេន ដា មកពីមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវបរិស្ថាន បានឲ្យដឹងថា តាមរយៈទស្សនកិច្ចសិក្សានេះ បានធ្វើឲ្យខ្ញុំដឹងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានការយល់ដឹងច្រើនជាងមុនពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈពិព័រណ៍បែបសិល្បៈ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការពិភាក្សាទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំពេញចិត្តចំពោះខ្សែភាពយន្តឯកសារនេះ ដែលមានការលាយឡំជាមួយ ប្រវត្តិសាស្ត្រ តន្ត្រី និងសិល្បៈ។

រតនៈ បានបញ្ចេញទស្សនៈយល់ឃើញ «ទោះបីខ្ញុំមិនបានឆ្លងកាត់របបខ្មែរក្រហមក៏ដោយ ក៏ប៉ុន្តែនៅពេលខ្ញុំទស្សនាខ្សែភាពយន្តឯកសារនេះ បានធ្វើឲ្យខ្ញុំមានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំង ដោយសារការបាត់បង់តន្ត្រីខ្មែរ និងសោកនាដកម្មនៅក្នុងរបបខ្មែរក្រហម។ **ព្រាំ គិតម៉ាន់**

# ភាពរីករាយ និងសោកនាដកម្មរបស់ប្រជាជនកម្ពុជា នៅខែមេសា

ប្រជាជនកម្ពុជាបានប្រារព្ធពិធីចូលឆ្នាំខ្មែររយៈពេលបីថ្ងៃ នៅរៀងរាល់ខែមេសា ដែលត្រូវនឹងខែចែត្រនៅក្នុងចន្ទគតិ។ ថ្ងៃចូលឆ្នាំនេះ គឺជាថ្ងៃដែលប្រជាជនកម្ពុជាជួបជុំក្រុមគ្រួសារ បងប្អូន សាច់ញាតិ និងជាថ្ងៃឈប់សម្រាកបន្ទាប់ធ្វើការងារនៅនឿយហត់ពេញមួយឆ្នាំ និងបន្ទាប់ពីប្រមូលផលស្រូវដំណាំ។

ខែមេសាក៏ជាខែដែលយោធាខ្មែរក្រហម បានរំដោះប្រទេសកម្ពុជាពីរបបសាធារណរដ្ឋខ្មែរដែលគ្រប់គ្រងដោយលន់ នល់ និងជាថ្ងៃបញ្ចប់សង្គ្រាមស៊ីវិលដែលបានអូសបន្លាយរយៈពេល៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា។ ប្រជាជននៅទូទាំងប្រទេសបានចូលរួមអបអរជ័យជម្នះនេះ និងបានស្វាគមន៍វត្តមានរបស់យោធាខ្មែរក្រហម ស្របពេលពិធីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរ។ ប្រជាជនសង្ឃឹមថា សន្តិភាព សេចក្តីចម្រុងចម្រើន និងភាពរីករាយនឹងកើតមាននៅក្នុងប្រទេសកម្ពុជា។

ប៉ុន្តែពីបីម៉ោងបន្ទាប់មក ការសង្ឃឹមរបស់ប្រជាជនក៏បានរសាយបាត់ទៅវិញ ហើយភាពភ័យរន្ធត់ តក់ស្លុត ក៏បានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ដោយយោធាខ្មែរក្រហមបានបង្ខំប្រជាជនឲ្យធ្វើដំណើរចាកចេញពីផ្ទះសម្បែង ក្រោមកម្តៅថ្ងៃក្តៅហួតហែង។ កម្ពុជាគឺជាប្រទេសដែលទទួលរងអាកាសធាតុត្រូពិក និងបានបែងចែកយ៉ាងច្បាស់លាស់រវាងរដូវប្រាំងដែលស្ថិតនៅចន្លោះពីខែធ្នូ ដល់ខែឧសភា និងរដូវវស្សាដែលស្ថិតនៅចន្លោះពីខែមិថុនា ដល់ខែវិច្ឆិកា។ ខែមេសាស្ថិតនៅក្នុងរដូវប្រាំងដែលខ្វះខាតទឹកស្អាតសម្រាប់ផឹក និងប្រើប្រាស់ ហើយអាកាសធាតុក្តៅក្នុងខែនេះ ក៏ងាយនឹងបង្កឲ្យកើតមានជំងឺឆ្លង និងជំងឺអាសន្នរោគផ្សេងៗដល់ប្រជាជនកម្ពុជាដែរ។

គោលនយោបាយជម្លៀសរបស់មេដឹកនាំខ្មែរក្រហមក្នុងខែមេសានេះ បានបណ្តាលឲ្យប្រជាជនកម្ពុជាដែលត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយ និងគ្មានគោលដៅច្បាស់លាស់ បានស្លាប់ជាបន្តបន្ទាប់ៗ ការបែកបាក់ គ្រោះទុរ្ភិក្ស ភាពអត់ឃ្លាន និងការចាប់យកទៅសម្លាប់ ក៏បានកើតឡើងចាប់ពីពេលនោះដែរ។

ភាពរីករាយដែលមានតែក្នុងចិត្ត និងសោកនាដកម្មនៅក្នុងខែមេសានេះ បានបន្សល់នូវការចងចាំ ភាពឈឺចាប់ និងជំងឺផ្លូវចិត្តដល់ជនរងគ្រោះរហូតមកដល់សព្វថ្ងៃ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ដំណើរការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ត្រូវបានផ្តួចផ្តើមឡើងតាមរយៈការបង្កើតតុលាការប្រជាជនបដិវត្តន៍ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម រួមទាំងការធ្វើញត្តិប្តឹងមេដឹកនាំខ្មែរក្រហម និងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើប្រជាជនកម្ពុជាទៅអង្គការសហប្រជាជាតិទៀតផង។

ទោះបីយ៉ាងណាតុលាការប្រជាជនបដិវត្តន៍កម្ពុជា មិនត្រូវទទួលស្គាល់ជាអន្តរជាតិឡើយ។ តុលាការនេះបានត្រឹមតែចេញសាលក្រម ប៉ុន្តែមិនមានជនជាប់ពិរុទ្ធមកទទួលទោស។ ចំណែកញត្តិដែលបានបញ្ជូនទៅ អង្គការសហប្រជាជាតិក៏មិនត្រូវបានអើពើដែរ ព្រោះរបបកម្ពុជាប្រជាធិបតេយ្យនៅមានអសនៈនៅអង្គការសហប្រជាជាតិនៅឡើយ ថែមមានការគាំទ្រពីប្រទេសមហាអំណាច និងប្រទេសអាស៊ានទៀតផង។

ដំណើរការស្វែងរកយុត្តិធម៌ជូនរងគ្រោះ ត្រូវបានអូស



បន្ទាយអស់រយៈពេលជាង បីទសវត្សរ៍ រហូតដល់មានកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ដែលចាប់ផ្តើមដំណើរក្តីតាំងពីឆ្នាំ២០០៦មក។ រហូតមកដល់សព្វថ្ងៃ មានមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតខ្មែរក្រហមបីរូបដែលស្ថិតនៅក្នុងសំណុំរឿង០០១ និង០០២ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ខណៈពេលដែលសំណុំរឿង ០០៣ និង០០៤ កំពុងដំណើរការ និងបិទបញ្ចប់នៅពេលដ៏ខ្លីខាងមុខៗ ទោះបីយ៉ាងណាដំណើរការយុត្តិធម៌ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅមិនទាន់គ្រប់គ្រាន់តាមការបង់បានរបស់ប្រជាជនកម្ពុជានៅឡើយ ដូច្នេះហើយទើបមានស្ថាប័នអង្គការសង្គមស៊ីវិល និងមជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំប្រឹងប្រែងធ្វើការផ្សារភ្ជាប់ទងនឹងយុត្តិធម៌ និងការបងចាំដើម្បីជួយប៉ះប៉ូវការខ្វះខាតនៃតុលាការនេះ ដូចជា ការដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ការចារឹកពាក្យស្លោកដែលនិយាយពីរបបខ្មែរក្រហម ដែលនិយាយពីការផ្សះផ្សា ការអត់ឱនអធ្យាស្រ័យគ្នានៅតាមសាលារៀន វេទិកាអប់រំសាធារណៈអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់សិស្សានុសិស្ស វគ្គបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់គរុសិស្សនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ នៅក្នុងប្រទេសកម្ពុជា ហើយនៅដើមខែមេសា ឆ្នាំ២០១៩ នេះ មជ្ឈ-មណ្ឌលឯកសារកម្ពុជា ក៏បានរៀបចំវគ្គបណ្តុះបណ្តាលពីអំពើប្រល័យពូជសាសន៍លើកទីពីរ ដល់សាស្ត្រាចារ្យតាមសាកលវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះគឺជាផ្នែកមួយនៃយុត្តិធម៌ និងសំណងជំងឺចិត្តដ៏យូរអង្វែង ព្រោះអំពើប្រល័យពូជនឹងត្រូវបានកត់ត្រាក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ និងត្រូវបានយកទៅបង្រៀនដល់ក្មេងៗនៅជំនាន់ក្រោយ និងរំឭកឡើងវិញពីការកាប់សម្លាប់យ៉ាងរង្គាលទៅលើប្រជាជនស្លូតត្រង់ ចាប់តាំងពីរបបខ្មែរក្រហម ឡើងកាន់អំណាច នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ **សោម ប៊ុនថន**



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

# «ផ្ទះផង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

## គង់ មារតី ៖ ធនាគារិក

ម្ដាយខ្ញុំបានស្លាប់នៅពេលដែលខ្ញុំនៅតូចៗ ខ្ញុំនៅចាំថា បន្ទាប់មកឪពុកខ្ញុំបានស្លាប់ ទៀតនៅពេលដែលខ្ញុំមានអាយុ ១០ឆ្នាំៗ ដូចនេះ ខ្ញុំបានធំឡើងដោយខិតខំប្រឹងប្រែងខ្លួនឯង យ៉ាងខ្លាំងៗ បន្ទាប់ពីឪពុករបស់ខ្ញុំស្លាប់ ខ្ញុំមានឪពុកធម៌ម្នាក់ គឺជាចៅហ្វាយស្រុកមួយនៅក្នុងខេត្តកំពង់ធំៗ គាត់បានសុំខ្ញុំធ្វើជាកូនធម៌របស់គាត់ៗ ក្រោយមក គាត់បានស្លាប់នៅពេលដែលខ្ញុំអាយុបាន១១ឆ្នាំ និងបន្ទាប់ពីនោះមក ម្ដាយធម៌របស់ខ្ញុំបានស្លាប់នៅពេលដែលខ្ញុំអាយុបាន១៥ឆ្នាំៗ

ខ្ញុំបានជួបលោកសង្ឃមួយអង្គ នៅតាមផ្លូវនៅខេត្តកំពង់ធំៗ ព្រះអង្គមានសង្ឃដីកាថា «អ្នកឯងមិនមានម្ដាយមិនមានឪពុកៗ អ្នកអាចទៅភ្នំពេញជាមួយអាត្មាបាន»ៗ ខ្ញុំបានទៅជាមួយព្រះអង្គ និងរស់នៅក្នុងវត្តមួយបានរយៈពេលមួយឆ្នាំៗ ខ្ញុំបានបញ្ចប់ការសិក្សានៅវិទ្យាល័យទួលស្វាយព្រៃ ក្រោយមកវិទ្យាល័យនេះ បានក្លាយទៅជាគុកទួលស្លែងៗ

នៅខណៈពេលដែលខ្ញុំរៀននៅមហាវិទ្យាល័យ ខ្ញុំបានធ្វើការមិនពេញម៉ោងដូចជា លក់នំប័ុង និងផាក់ស៊ីក្លូ ដើម្បីរកប្រាក់បន្ថែមៗ ខ្ញុំក៏បានរៀនភាសាបារាំងដែរ ហើយនៅម៉ោងទំនេរ បានទៅហាត់រៀនយូដូ ដោយបានទទួលខ្សែក្រវ៉ាត់ខ្មៅៗ នៅពេលដែលខ្ញុំជានិស្សិតឆ្នាំទីបី នៅសកលវិទ្យាល័យពាណិជ្ជសាស្ត្រ ខ្ញុំបានចាប់ផ្ដើមធ្វើការនៅធនាគារខ្មែរពាណិជ្ជ និងបង្ហាត់យូដូផងៗ

ខ្ញុំមិនមានគ្រួសារ ឬអ្នកជិតខាងណាណែនាំខ្ញុំឡើយ ដូចនេះខ្ញុំប្រាកដណាស់ដឹងអំពីការរស់នៅ និងយល់ថាខ្ញុំត្រូវតែធ្វើអ្វីៗទាំងអស់ដែលជាការចាំបាច់ដើម្បីរស់ៗ ខ្ញុំមិនមានសំណាងអ្វីឡើយក្នុងការរស់នៅប៉ុន្តែខ្ញុំជាមនុស្សប៉ុនប្រសប់ៗ ខ្ញុំខិតខំប្រឹងប្រែងដើម្បីអនាគត និងបន្តប្រឹងប្រែងទៀតនៅពេលដែលខ្ញុំជាប់ឃុំឃាំងៗ

នៅថ្ងៃទី១៧ មេសា ១៩៧៥ ខ្ញុំនៅធនាគារកំពុងរៀបចំឯកសារៗ ពេលនោះសហការីរបស់ខ្ញុំ និងខ្ញុំបានដឹងថា មានរឿងចម្លែកៗ យើងក្រឡេកមើលទៅខាងក្រៅឃើញយោធាស្លៀកពាក់ឯកសណ្ឋានពណ៌ខ្មៅ មួរដើងខោខាងស្ដាំ និងមានកាន់អាវុធៗ យោធាទាំងនោះបានចូលក្នុងធនាគារ ហើយបានបាញ់ និងបង្ខំបុគ្គលិកធនាគារទាំងអស់ឲ្យចេញទៅខាងក្រៅៗ បុគ្គលិករបស់ខ្ញុំជាច្រើននាក់ និងខ្ញុំបានចាកចេញដោយមិនបានចាក់សោរបន្ទប់ឡើយៗ

នៅតាមផ្លូវចេញពីទីក្រុង ខ្មែរក្រហមបានប្រកាសតាមមេក្រូថា«អង្គការត្រូវការអ្នកមានចំណេះដឹង អ្នកបច្ចេកទេស និងរដ្ឋការជាន់ខ្ពស់ពីរបប លន់ នល់ ដើម្បីជួយកសាងទីក្រុងឡើងវិញៗ វាត្រូវការពេលវេលាដើម្បីរៀបចំប្រទេសឡើងវិញ»ៗ ប្រជាជនជាច្រើននាក់ មានបុរសស្ទើរទាំងអស់បានចុះឈ្មោះៗ ខ្មែរក្រហមបានផ្ដល់ឲ្យអ្នកទាំងនោះមានជាអង្ករ ត្រីងៀត សាច់ជ្រូក និងនំប័ុង ដើម្បីលើកទឹកចិត្តពួកគេឲ្យចុះឈ្មោះៗ

ខ្ញុំបានចំណាយពេលមួយខែបន្ទាប់មកនៅក្នុងវត្តមួយនៅស្រុកកៀនស្វាយៗ សេចក្ដីអស់សង្ឃឹមបានកើនឡើងរៀងរាល់ថ្ងៃៗ នៅពេលរដូវភ្លៀងបានមកដល់ ខ្មែរក្រហមបានចាប់ផ្ដើមបែងចែកប្រជាជនៗ អ្នកខ្លះស្នាក់នៅធ្វើការនៅតាមវាលស្រែ ខណៈដែលអ្នកមានសាច់ញាតិនៅតាមខេត្តបានចាកចេញទៅៗ គ្រួសារអ្នកមានជាជនជាតិចិនខ្លះ ដែលរស់នៅក្រុងភ្នំពេញជានិរន្តរ៍ ហើយមិនមានកន្លែងណាត្រូវទៅនោះ

UNIVERSITE DE PHNOM-PENH

N° 205/SC/72

សាធារណរដ្ឋខ្មែរ

RÉPUBLIQUE KHMÈRE

FACULTÉ DES SCIENCES COMMERCIALES

## ATTESTATION DE REUSSITE

LE DOYEN DE LA FACULTE DES SCIENCES COMMERCIALES

soussigné certifie que

M onsieur KONG MEARDEY

né le 1 JUILLET 1950

à CHHEP ( KAMPONG- THOM )

a été déclaré reçu à l'examen du BREVET SUPERIEUR DE L'ENSEIGNEMENT COMMERCIAL

Mention PASSABLE

Session du 19 JUIN 1972

Centre de PHNOM-PENH

Phnom-Penh, le 27 AOUT 1972



N. B. Aucun duplicata du présent certificat ne sera délivré.

---

BANQUE KHMERE POUR LE COMMERCE

PERSONNEL

## RENSEIGNEMENTS ET PIÈCES JUSTIFICATIVES

CLASSER DANS CE DOSSIER TOUS LES DOCUMENTS SUSCEPTIBLES DE FIXER SUR L'ETAT-CIVIL, LA MORALITE, LA SITUATION ET LES CHARGES DE FAMILLE, LA SANTE DE L'AGENT, NOTAMMENT :

BULLETIN DE RENSEIGNEMENTS REMPLI PAR L'AGENT
RESULTAT DE L'ENQUÊTE FAITE SUR L'INTERESSE,
PHOTOGRAPHIES,
EXTRAIT DE NAISSANCE.



---

BANQUE KHMERE POUR LE COMMERCE
CAPITAL 100.000.000 RIELS

N/REF. 001/75/D

Dos. pers

Phnom-Penh, le 02 Janvier 1975

## DECISION

LE PRESIDENT-DIRECTEUR GENERAL,

Vu le Krâm n° 153-CE du 16/12/63 portant création de la Banque Khmère pour le Commerce,
Vu le Kret n° 205-CE du 28/3/64 fixant les Statuts de la Banque Khmère pour le Commerce,
Vu le Kret n° 409-72/PRK du 27/6/72 portant nomination de M. HING KUNTHON au poste de Président-Directeur Général de la Banque Khmère pour le Commerce,
Vu les nécessités de service,

D E C I D E

ARTICLE 1er- Sont nommés à compter du 1er/1/75 aux fonctions respectives ci-après au Département Etranger :

M. SIN CHAMROEUN, Sous-Chef de Service au Service Import avec signature de 1ère Catégorie ( Etranger )

M. SVAY TO, Chef de Bureau au Service des Changes (Position devises)

Mme KVIN SOK, Chef de Section au Service des Changes

Mme DOUTCH SALAPHANG, Chef de Section au Service des Changes,

M. KOAM SAVOEUN, Employé Principal au Service des Changes avec signature de 2è Catégorie ( Etranger )

M. KONG MEARDEY, Employé Principal au Service des Changes avec signature de 2è catégorie ( Etranger )

Mme CHEA PUNLOK, Employé Principal au Service Import ( OCD )

...2/..

---

... 2 ...

ARTICLE 2.- Les intéressés bénéficient des divers indemnités et avantages prévus par les textes en vigueur à compter de la même date.

ARTICLE 3.- Les Directeurs du DA et du DE sont chargés chacun en ce qui le concerne de l'exécution de la présente Décision.

LE PRESIDENT-DIRECTEUR GENERAL,

Kunthon

HING KUNTHON

Copie à :

- Tous Dépts.
- Toutes Agences
- Intéressés
- Dos.pers.
- Chrono

បានបើករថយន្តរបស់ខ្លួនចូលក្នុងទន្លេសម្លាប់ខ្លួនឯង។

ខ្ញុំមិនមានទីកន្លែងដែលត្រូវទៅនោះទេខ្ញុំក៏បានធ្វើដំណើរឆ្លងទន្លេអ្នកលឿង។ នៅព្រំប្រទល់ខេត្តព្រៃវែង និងខេត្តស្វាយរៀង ខ្ញុំបានសម្រេចចិត្តបោះដុំថ្មមួយដុំឡើងទៅលើ។ ប្រសិនបើដុំថ្មធ្លាក់ចុះមកដី ឈរត្រង់ ខ្ញុំនឹងធ្វើដំណើរឆ្ពោះទៅតំបន់ខាងកើត និងប្រសិនបើថ្មធ្លាក់មកមិនត្រង់ ខ្ញុំនឹងធ្វើដំណើរឆ្ពោះទៅតំបន់ខាងជើង។ ដុំថ្មនោះបានធ្លាក់ចុះមកក្រោមត្រង់ ដូចនេះខ្ញុំបានងាកទៅទិសខាងកើត។

នៅពេលដែលខ្ញុំមកដល់ឃុំកំពង់សិង្ហ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនទាំងអស់អង្គុយពេញមួយថ្ងៃ ដោយមិនមានអាហារ ឬទឹកផឹកឡើយ។ បន្ទាប់មកខ្មែរក្រហមបានចាប់ផ្តើមស្រង់ជីវប្រវត្តិរបស់ប្រជាជន។ ខ្ញុំបានសម្រេចចិត្តប្រាប់គេថាខ្ញុំគឺជានិស្សិត។

ខ្ញុំបានជ្រើសយកឈ្មោះដែលអ្នកសុំខ្ញុំធ្វើជាកូនចិញ្ចឹមបានដាក់ឈ្មោះឲ្យខ្ញុំថា គង់ មារតីភក្តី។ ឈ្មោះខ្មែរមានតែមួយ ឬពីរពាក្យប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងរបប ប៉ុល ពត ប្រសិនបើអ្នកមានឈ្មោះវែង វាមានន័យថាអ្នកមិនមែនបុគ្គលខ្មែរ (កសិករ) ទេ និងត្រូវស្លាប់។ ដូច្នេះតាំងពីពេលនោះមក ខ្ញុំបានប្រើឈ្មោះគង់ មារតី ប៉ុណ្ណោះ។

ថ្ងៃបន្ទាប់មក យោធាខ្មែរក្រហមបាននិយាយថា យើងត្រូវការរៀនសូត្រឡើងវិញ។ កម្មាភិបាលសក់រួញម្នាក់បានប្រកាសថា «មិត្តទាំងអស់គ្នាមានសំណាងហើយ។ អង្គការចង់អប់រំអ្នកទាំងអស់គ្នា។ មិនបាច់យករបស់ប្រើប្រាស់ផ្ទាល់ខ្លួនទៅជាមួយទេ អង្គការមានអ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការ»។ យើងត្រូវបានដាក់ឲ្យដើរក្នុងជួរជាច្រើន ដោយមានយោធាប្រដាប់អាវុធម្នាក់ដើរពីក្រោយជួរនីមួយៗ។ បន្ទាប់មក ខ្មែរក្រហមបានយកយើងទៅមន្ទីរសន្តិសុខពងទឹក នៅខេត្តព្រៃវែង។ បន្ទាប់ពីបានស្រង់ជីវប្រវត្តិរបស់យើងម្តងទៀត ខ្មែរក្រហមបានដាក់យើងនៅក្នុងការិយាល័យមួយ និងចាក់សោទ្វារពីខាងក្រៅ។ នៅខាងក្នុងនោះគឺមានតែកេសគ្រាប់រំសេវលោហៈមួយ ដែលយើងអាចប្រើជាបង្គន់។ បន្ទាប់មកខ្ញុំដឹងថា ខ្ញុំបានជាប់អន្ទាក់ហើយ។

នៅក្នុងមន្ទីរសន្តិសុខនោះ មានអ្នកទោស៥១៨នាក់ ដែលអ្នកទាំងនោះគឺជាអតីតនិស្សិត គ្រូបង្រៀន និងទាហានលន់ នល់។ នៅពេលយប់ យើងម្នាក់ៗដេកផ្ទុយគ្នា។ ជើងរបស់យើងជាប់ច្រវាក់ភ្ជាប់ជាមួយនឹងដែកសរសៃវែងមួយដែលឆ្នាំគុកចាក់សោនៅខាងចុង។ ខ្ញុំបានជាប់នៅទីនោះចំនួន ១០ថ្ងៃ អង្គការបានបញ្ជូនចេញអ្នកដែលមានឋានៈខ្ពស់ ខណៈដែលអ្នកផ្សេងទៀតត្រូវបានបញ្ជូនទៅធ្វើការ។ ខ្ញុំបានធ្វើការនៅផ្នែកកសាងផ្លូវថ្នល់ ដែលមានអ្នកទោសចំនួន៥០នាក់។ យើងដើរទៅការដ្ឋានរបស់យើងក្នុងរយៈពេលមួយម៉ោង ជាទីកន្លែងដែលយើងកាប់ដីរាល់ថ្ងៃ ពីម៉ោង៥ព្រឹក ទៅដល់ថ្ងៃត្រង់ បន្ទាប់មកពីម៉ោងមួយរសៀល ដល់ម៉ោង៦ល្ងាច។ យើងអាចបានហូបបាយបានតែម្តងប៉ុណ្ណោះ។ អ្នកទោសទាំងអស់បានធ្វើការយ៉ាងខ្លាំង ទាំងយប់ទាំងថ្ងៃ ព្រោះអង្គការបានប្រកាសថា នៅពេលយើងបញ្ចប់ការសាងសង់ផ្លូវ អង្គការនឹងដោះលែងយើង។

ប៉ុន្តែខ្មែរក្រហមបានកុហកយើងហើយការសង្ឃឹមរបស់យើងលែងមានទៀតដែរ។ ជំនួសឲ្យការដោះលែងយើង ខ្មែរក្រហម បានបញ្ជូនយើងទៅការដ្ឋានថ្មីមួយទៀតដើម្បីជីកប្រឡាយ។ ពេលនេះជារដូវវស្សា យើងបានដេកនៅក្បែរប្រឡាយ ខ្ញុំអស់កម្លាំងជាខ្លាំង និងបានដេកលក់នៅពេលភ្លៀង។ ខ្មែរក្រហមបានបន្ថយរបបអាហាររបស់យើង អ្នកទោសជាច្រើននាក់បានធ្លាក់ខ្លួនឈឺធ្ងន់ និងស្លាប់ដោយសារ

ធ្វើការងារច្រើនជ្រុល។

បន្ទាប់មក ខ្ញុំត្រូវបានបញ្ជាឲ្យទៅរកបន្លែសម្រាប់សហករណ៍ និងទទួលបានអាហារប្រសើរជាងមុន។ នៅពេលយប់ ខ្ញុំបានម៉ាស្សាឲ្យប្រធានដាំស្ល និងអ្នកដាំស្លផ្សេងទៀត នៅក្នុងកងសម្រាប់ជាថ្នូរនឹងអាហារបន្តិចបន្តួច។ ខ្ញុំព្យាយាមអស់ពីសមត្ថភាពដើម្បីយកចិត្តអ្នកទាំងនោះ និងបានប្រាប់អង្គការថាខ្ញុំគឺជាអ្នកម៉ាស្សា។ នៅពេលដែលខ្ញុំរស់នៅក្រុងភ្នំពេញ ខ្ញុំជាគ្រូបង្ហាត់យូដូម្នាក់ ដូច្នេះខ្ញុំស្គាល់ប្រព័ន្ធសរសៃក្នុងតួខ្លួនរបស់មនុស្ស។ យប់មួយនោះបុរសម្នាក់បានប្រាប់ថា អង្គការចង់ជួបខ្ញុំ។ ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង។ នៅពេលដែលខ្ញុំបានដើរចូលទៅក្នុងការិយាល័យនោះ មេខ្មែរក្រហមបានឲ្យខ្ញុំម៉ាស្សា ញីច្របាច់កែងជើងរបស់គាត់។ ខ្ញុំបានញីច្របាច់យ៉ាងខ្លាំង និងលាបប្រេងខ្លាញ់ពស់លាយនឹងផេះធ្យូងលើកែងជើងរបស់គាត់។ បន្ទាប់មកខ្ញុំបានផ្ទុះតម្រង់សរសៃឲ្យចូលក្នុងផ្លូវឆ្អឹងវិញ។ បន្ទាប់ពីនោះមក ខ្មែរក្រហមបានផ្តល់ឲ្យខ្ញុំនូវរបបអាហារពេញលេញ។

នៅចុងឆ្នាំ១៩៧៦ នៅពេលដែលយើងបញ្ចប់ដីកប្រឡាយ អង្គការបានហៅឲ្យទៅចូលរួមប្រជុំមួយ និងបានដោះលែងអ្នកទោសស្ត្រីជាច្រើននាក់ពីរមន្ទីរសន្តិសុខ ប៉ុន្តែពួកយើងដែលនៅសល់ត្រូវបានបញ្ជូនទៅការដ្ឋានសំណង់ថ្មីមួយទៀត នៅក្នុងខេត្តព្រៃវែង។ យើងបានដើរទៅទីនោះតាមផ្លូវជាតិលេខ១១។ បុរសជាច្រើននាក់មានការសប្បាយរីករាយ ព្រោះមិនបានឃើញផ្លូវជាតិជាយូរមកហើយ។ យើងបានដើរជាជួរ ប្រសិនបើអ្នកណាម្នាក់ឈានចេញក្រៅជួរ អ្នកនោះនឹងត្រូវបានវាយដំ។ ការងាររបស់យើងនៅការដ្ឋានថ្មីនោះ គឺសង់ទំនប់ស្តុកទឹកសម្រាប់ស្រោចស្រពវាលស្រែ ចិញ្ចឹមសត្វពាហនៈភ្ជួរស្រែ និងជីកប្រឡាយ។ ខ្មែរក្រហមបានវាយយើងនៅពេលយើងឈប់សម្រាកអ្នកមើលការខុសត្រូវបានសើច និងឲ្យអ្នកជាប់ទោសរាប់ចំនួនដងដែលត្រូវវាយ។ អ្នកមើលការខុសត្រូវនោះបានវាយដំអ្នកទោសពីរនាក់រហូតដល់ស្លាប់ ដោយសារជីកទឹកប្រឡាយ។ យោធាខ្មែរក្រហមបានវះយកថ្លើមរបស់អ្នកទោសយកមកចម្អិនហូប។

ខ្ញុំស្ទើរតែស្លាប់ ដោយសារអត់ឃ្លាននៅការដ្ឋាននោះ។ ពេលខ្លះខ្ញុំលួចចេញទៅរកចាប់កង្កែប ក្តាម ខ្យង និងកណ្តុរមកហូប។ ប៉ុន្តែខ្មែរក្រហមបានចាប់ខ្ញុំ និងវាយដំខ្ញុំជាមួយនឹងមែកឫស្សីទាល់តែហូរឈាម។

មានកើតសត្វរុយជាច្រើននៅឆ្នាំនោះ ដូច្នេះនៅពេលដែលយើងហូបអ្វីៗ យើងត្រូវតែប្រយ័ត្នបិទមាត់របស់យើង។ អ្នកទោសបានស្លាប់ម្តងមួយៗ អ្នកខ្លះស្លាប់នៅពេលដេក អ្នកខ្លះស្លាប់ខណៈដែលកំពុងដើរ ខ្លះត្រូវបានប្រហារជីវិត និងអ្នកទោសផ្សេងទៀតបានចងកសម្លាប់ខ្លួន។ អ្នកទោសខ្លះដោយមានការស្រេកឃ្លានខ្លាំង គាត់បានហូបសាកសព។

នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ អង្គការបានឲ្យយើងទាំងអស់គ្នាឈរមួយជួរ។ កម្មាភិបាលបាននិយាយថា អ្នកទោសស្ទើរតែទាំងអស់បានគោរពនិងជឿជាក់លើអង្គការ អ្នកទាំងនោះនឹងត្រូវបានបញ្ជូនទៅមូលដ្ឋានវិញ។ ប៉ុន្តែនៅមានអ្នកទោស២០នាក់ទៀតដែលរៀនសូត្រមិនទាន់គ្រប់គ្រាន់នៅឡើយ។ ខ្ញុំស្ថិតនៅក្នុងចំណោមអ្នកទាំង២០នាក់នោះ។ ក្រោយមកខ្ញុំបានឮកម្មាភិបាលនិយាយថា អ្នកដែលបានដោះលែងនោះត្រូវបានសម្លាប់។

ក្រោយមកសន្តិសុខគុកបានហៅអ្នកទោសទាំង២០នាក់ទៅឈរតម្រង់ជួរ។ រថយន្ត៦គ្រឿង ដែលផលិតនៅប្រទេសចិនបានឈប់ ហើយអង្គការឲ្យយើងឡើងលើរថយន្តនោះ។ អង្គការបានប្រាប់យើងថា យើងមានសំណាងហើយដែលបានបញ្ជូនត្រឡប់ទៅមូលដ្ឋានវិញ។ ខ្ញុំយំ ហើយគ្រប់គ្នាបានថ្លែងអំណរគុណដល់អង្គការ។ ខ្ញុំជាប់គុកអស់រយៈពេលមួយឆ្នាំ ប្រាំមួយខែ និងប្រាំមួយថ្ងៃ។ មានតែយើង២០នាក់គត់ដែលបានរស់រានមានជីវិត នៅក្នុងចំណោមប្រជាជន៥១៨នាក់នៅក្នុងគុក។

***រូបថត និង អត្ថបទ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា***

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

ង៉ែត យាម មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៦ នៅរៀន មានស្រុកកំណើតនៅកោះធំ ខេត្តកណ្ដាល ជាកូនរបស់ពូ ង៉ែត យុត និងមីង ទូច សុខ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែមិនា ឆ្នាំ១៩៧៦ នៅមន្ទីរ១៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ១៤។ ខ្មែរក្រហមបញ្ជូន ង៉ែត យាម មកដល់គុកទួលស្លែងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៧ ថ្ងៃ។

ង៉ែត ចន ហៅ ឃួន មនអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្ដាល ជាកូនរបស់ពូ ង៉ែត សន និងមីង អុន ស៊ុន យុទ្ធជនសេដ្ឋកិច្ច កងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៥០២។ ខ្មែរក្រហមសម្លាប់ ង៉ែត ចន នៅថ្ងៃទី១៧ ខែមិនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ២៨ ថ្ងៃ។

ង៉ែត ជិន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅត្បូងឃ្មុំ ខេត្តកំពង់ចាម ជាកូនរបស់ពូ ង៉ែត លគ និងមីង ម៉ៃ សេង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៥ នៅព្រែកក្ដាម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ៩។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ង៉ែត ជិន ត្រូវបានខ្មែរក្រហមចាប់បញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៥ ឬថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ង៉ែត ជិន នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦។

ង៉ែត ឈុនង៉ាន ហៅ សំណាង មានអាយុ ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្អាង ខេត្តកណ្ដាល ជាកូនរបស់ពូ ង៉ែត ឌូ និងមីង អ៊ុច ធឿង ធ្វើយោធា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៥ នៅច្បារអំពៅ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ៥។ ង៉ែត ឈុនង៉ាន ត្រូវបានខ្មែរក្រហមចាប់បញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៥ ថ្ងៃ។

ង៉ែត ញ៉ាន់ មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ជាកូនរបស់ពូ ង៉ែតគិននិងមីង ឈុន សាម៉ោង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅពោធិ៍ចិនតុង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៦ បន្ទប់តូច ៥។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ង៉ែត ញ៉ាន់ ត្រូវបានខ្មែរក្រហមចាប់បញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៦ ឬថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៦ ឬថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ង៉ែត ញ៉ាន់ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៦។

ង៉ែត ញ៉ុក ហៅ វ៉ាន់ ថន កងចល័តពោធិ៍សាត់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅពោធិ៍សាត់។ ខ្មែរក្រហមបញ្ចូល ង៉ែត ញ៉ុក ក្នុងគុកទួលស្លែងនៅថ្ងៃទី៤ ខែតុលា ឆ្នាំ

១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១១ ថ្ងៃ។

ង៉ែត ម៉ន មានអាយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបន្ទាយមាស ខេត្តកំពត ជាកូនរបស់អ៊ំ ង៉ែត អ៊ាក់ និងអ៊ំស្រី អ៊ូ មុំ មានប្រពន្ធឈ្មោះ យក់ លាន មានកូនប្រុស៤នាក់និងស្រី៤នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៦ នៅមន្ទីរឡានទឹក ភ្នំពេញ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ០៣ បន្ទប់តូច ១៨។ ខ្មែរក្រហមបញ្ចូល ង៉ែត ម៉ន ក្នុងគុកទួលស្លែងនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៨៣ ថ្ងៃ។

ង៉ែត សារិន ហៅ ទូច មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្អាង ខេត្តកណ្តាល ជាកូនរបស់អ៊ំ ង៉ែត សារ៉ុង និងអ៊ំស្រី អ៊ុន ពេញ មានប្រពន្ធឈ្មោះ ខូវ គីមថៅ មានកូនប្រុស១នាក់និងស្រី១នាក់ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៤ខែកញ្ញាឆ្នាំ១៩៧៦ នៅស្ទឹងប្រាល ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៣ បន្ទប់តូច ១០។ ខ្មែរក្រហមបញ្ចូល ង៉ែត សារិន ក្នុងគុកទួលស្លែងនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៩៣ ថ្ងៃ។

ង៉ោល ហុង មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៨ (ស្រុកកោះធំ) ខេត្តកណ្តាល ជាកូនរបស់ពូ ឌួន ង៉ោល និងមីង គម មែន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកង១៣ មន្ទីរ ស-២១ ឃ ហើយបញ្ចូលទៅក្នុងគុកទួលស្លែងនៅថ្ងៃបន្ទាប់។ ខ្មែរក្រហមសម្លាប់ ង៉ោល ហុង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ២៣ ថ្ងៃ។

ងិច សេង ជាប្រពន្ធរបស់ឈ្មោះ តុប ម៉ុង កម្មករអគ្គីសនីទី២ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ នៅអគ្គីសនីទី២ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់។ ចំណែកឯប្តីវិញ ត្រូវបានខ្មែរក្រហមឃាត់ខ្លួនបញ្ជូនទៅគុកទួលស្លែងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ គឺ២ថ្ងៃមុនការចាប់ប្រពន្ធ។ ខ្មែរក្រហមសម្លាប់ តុប ម៉ុង នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ លើសពីនេះទៀត ឪពុកក្មេកឈ្មោះ តុប ស្រ៊ុន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននិងសម្លាប់ នៅថ្ងៃជាមួយគ្នានឹងកូនប្រសារដែរ។ (មានរូបថតរបស់ តុប ម៉ុង និង តុប ស្រ៊ុន នៅលេខរៀង ក្រោយ តាមព្យញ្ជនៈ «ត»)។

ងិន លីម មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១០៨ (ស្រុកកោះអណ្តែត) ខេត្តតាកែវ ជាកូនរបស់ពូ ងិន សាង និងមីង ហង់ លី ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ នៅកងកេង កំពង់សោម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់ធំ ៤។ ខ្មែរក្រហមបញ្ចូល ងិន លីម ក្នុងគុកទួលស្លែងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៨៦ ថ្ងៃ។

ងិន សារិន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ចូល ងិន សារិន ក្នុងគុកទួលស្លែងនៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៣៦ ថ្ងៃ។

ងិន សាអ៊ិត មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតវិស្វករអណ្តូងរ៉ែ និងប្រេងកាត មានស្រុកកំណើតនៅកំពង់ត្របែក ខេត្តព្រៃវែង ជាកូនរបស់អ៊ំ ងិន អ៊ុង និងអ៊ំស្រី ប៉ែន អេង មានប្រពន្ធឈ្មោះ យឹម ប៉ោហ៊ី មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១០ខែមករាឆ្នាំ១៩៧៦ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០១ បន្ទប់លេខ ១៣។ ខ្មែរក្រហមបញ្ចូល ងិន សាអ៊ិត ក្នុងគុកទួលស្លែងនៅថ្ងៃទី២៦ខែមីនាឆ្នាំ១៩៧៦និងសម្លាប់ចោលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

ឈ្នួន ឈានគីម ហៅ និគីម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល១៧០ ហើយសម្លាប់ចោលនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១១ ថ្ងៃ។

ឈ្នួន ឆេង ហៅ ធីន មានអាយុ៣២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រីសន្ធរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ឆាយ គាត និងអ៊ំស្រី យុន សេង មានប្តីឈ្មោះ អ៊ុំ ម៉ុល ហៅ ថន មានកូនប្រុស១នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧ នៅកងពល៣១០ ខេត្តកណ្តាល ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ០៣ បន្ទប់តូច ៥។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ឈ្នួន ឆេង ត្រូវបានខ្មែរក្រហមបញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី៣០ ឬ ៣១ ខែធ្នូ ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ រីឯ ប្តីឈ្មោះ អ៊ុំ ថន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ និងពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈ្នួន ឆែម មានអាយុ៤៩ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់អ៊ំ កែវ ឈ្នួន និងអ៊ំស្រី យូស អ៊ុំ មានប្រពន្ធឈ្មោះ កែវ វ៉េត មានកូនប្រុស៤នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០៧ បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ ឈ្នួន ឆែម នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

ឈ្នួន ពេញ អនុវរៈសេនាធំកងពល២៩០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល២៩០ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ចូល ឈ្នួន ពេញ ក្នុងគុកទួលស្លែងនៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៦៧ ថ្ងៃ។

ឈ្នួន យ៉ន ហៅ ញឹម មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ អ៊ូ ឈ្នួន និងមីង ហែរ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ៥ បន្ទប់តូច ៦។ ខ្មែរក្រហមសម្លាប់ ឈ្នួន យ៉ន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ២១ ថ្ងៃ។

ឈ្នួន យ៉ុន ហៅ ពន្ធ័ មានអាយុ២៤ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅអង្គស្នួល ខេត្តកណ្តាល ជាកូនរបស់ពូ ឈ្នួន ណែម និងមីង ចឹក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពាណិជ្ជកម្ម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ ០៣ បន្ទប់តូច ២។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឈ្នួន សារ៉ាត កម្មករអគ្គីសនីចក្រអង្រែ ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ នៅអគ្គីសនីចក្រអង្រែ។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការចូលក្នុងគុកទួលស្លែង និងការសម្លាប់នៅឡើយ។

ឈ្នួន អកដ្ឋា មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅភ្នំពេញ ជាកូនរបស់ពូ ឈ្នួន ដៃ និងមីង គីម ហួយ មានប្រពន្ធឈ្មោះ ទ្រូ ចន្ទលី ហៅ គង់ មានកូនប្រុស២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៧ នៅស្រុកភ្នំស្រុក តំបន់ ៥ (ខេត្តបាត់ដំបង) ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៥ បន្ទប់ធំ ១៤។ ខ្មែរក្រហមសម្លាប់ ឈ្នួន អកដ្ឋា ឬ ឈ្នួន អថា នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

(នៅមានត)

**វ៉ាន់ថាន់ ពៅដារ៉ា និង ឡុង ដានី**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ុន សុដាវី*

*វិទ្យាស្ថានស្ទីករីត, ខែកុម្ភៈ ឆ្នាំ២០១៥*

(តពីលេខមុន)

| ល.រ | លេខកូដ | ឈ្មោះ ជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ៣៥៣ | ៨៦៧៨ | Sok Seng | សុខ សេង | ? | ? | ១៩៨៧ | ១៩២ |
| ៣៥៤ | ៨៦៨២ | Theavy | ធាវី | ? | ? | ? | ១៩៥ |
| | | Chaota | ចៅតា | ? | ? | ? | |
| | | Teng | តេង | ? | ? | ? | |
| ៣៥៥ | ៨៦៨៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩៥ |
| ៣៥៦ | ៨៦៨៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩៥ |
| ៣៥៧ | ៨៦៩០ | Hang Mum (Prey Veng) | ហាង មុំ (ព្រៃវែង) | ? | ? | ? | ១៩៦ |
| ៣៥៨ | ៨៦៩២ | Chan Ny | ច័ន្ទ នី | ? | ? | ? | ១៩៦ |
| ៣៥៩ | ៨៦៩៤ | Sun Sochey | ស៊ុន សុជី | ? | ? | ? | ១៩៩ |
| ៣៦០ | ៨៧០២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩៦ |
| ៣៦១ | ៨៧០៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ១៩៦ |
| ៣៦២ | ៨៧០៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០០ |
| ៣៦៣ | ៨៧០៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០០ |
| ៣៦៤ | ៨៧១០ | Sakk | សាក់ | ? | ? | ? | ២០១ |
| ៣៦៥ | ៨៧១២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០១ |
| ៣៦៦ | ៨៧១៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០២ |
| ៣៦៧ | ៨៧២១ | Hong Sereirithy alias Phau | ហុង សេរីឫទ្ធី ហៅ ផូ | ? | ? | ១៩៨២ | ២០៥ |
| ៣៦៨ | ៨៧២២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៦៩ | ៨៧២៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០២ |
| ៣៧០ | ៨៧២៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៣៧១ | ៨៧២៩ | Chhang Mum | ឆាង មុំ | ? | ? | ? | ២០៣ |
| ៣៧២ | ៨៧៣២ | Cheng Than | ចេង ថន | ? | ? | ១៩៩០ | ២០៥ |
| ៣៧៣ | ៨៧៤០ | Huot | ហួត | ប្រុស | ? | ? | ២០៥ |
| | | Vann Van | វ៉ាន់ វ៉ន | ស្រី | ? | ? | |
| ៣៧៤ | ៨៧៥៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៥ |
| ៣៧៥ | ៨៧៦២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៦ |
| ៣៧៦ | ៨៧៦៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៣៧៧ | ៨៧៧២ | Yem Ching | យ៉ែម ជីង | ? | ? | ? | ២០៦ |
| ៣៧៨ | ៨៧៧៤ | Vong Mao | វង្ស ម៉ៅ | ? | ? | ? | ២០៦ |
| ៣៧៩ | ៨៧៨៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៦ |
| ៣៨០ | ៨៧៧៩ | Sim Sary | ស៊ីម សារី | ស្រី | ? | ១៩៩២ | ២០៦ |
| ៣៨១ | ៨៧៨៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៩ |
| ៣៨២ | ៨៧៩០ | Im Chhun | អ៊ឹម ឈុន | ? | ? | | ២០៩ |
| | | Im Khun | អ៊ឹម ឃុន | ? | ? | ? | |
| ៣៨៣ | ៣៧៩២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៩ |
| ៣៨៤ | ៣៧៩៥ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៩ |
| ៣៨៥ | ៨៨០០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២០៩ |
| ៣៨៦ | ៨៨០២ | Phuon Lin | ភួន លិន | ? | ? | ៣១/?/១៩៨៤ | ២១០ |
| ៣៨៧ | ៨៨០៦ | Minh Simuon | មិញ ស៊ីមួន | ស្រី | ៦១ឆ្នាំ | ២៦/០១/១៩៨៨ | ២១០ |
| ៣៨៨ | ៨៨០៨ | Chim Moeun | ជឹម មឿន | ? | ? | ? | ២១០ |
| ៣៨៩ | ៨៨១១ | Tang Kich | តាំង គិច | ? | ៥០ឆ្នាំ | ២៩/០៨/១៩៨៧ | ២១០ |
| ៣៩០ | ៨៨០៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១០ |
| ៣៩១ | ៨៨១៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣៩២ | ៨៨៣៨ | Chheng Sinan (has photo) | ឆេង ស៊ីណន (មានរូបថត) | ស្រី | ? | ១៧/០៨/១៩៨៧ | ២១៣ |
| ៣៩៣ | ៨៨៤៦ | Tuon Vuthy | ទួន វុទ្ធី | ? | ? | ០២/០៨/១៩៨៣ | ២១៦ |
| ៣៩៤ | ៨៨៤៨ | Cheach? Sech | ជាច? សេជ | ? | ? | ? | ២១៦ |
| ៣៩៥ | ៨៨៥២ | Ngoeu Haiheng | ង៉ៅ ហៃហេង | ? | ? | ? | ២១៩ |
| ៣៩៦ | ៨៨៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១៩ |
| ៣៩៧ | ៨៨៥៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១៩ |
| ៣៩៨ | ៨៨៦០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១៩ |
| ៣៩៩ | ៨៨៦៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២១៩ |
| ៤០០ | ៨៨៦៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២០ |
| ៤០១ | ៨៨៧១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២០ |
| ៤០២ | ៨៨៧៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២០ |
| ៤០៣ | ៨៨៧៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២០ |
| ៤០៤ | ៨៨៨៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២៣ |
| ៤០៥ | ៨៨៨៨ | Prum Viseth | ព្រុំ វិសិទ្ធ | ? | ? | ? | ២២៣ |
| ៤០៦ | ៨៨៨៩ | Kris Ouch | គ្រីស អ៊ូច | ? | ? | ? | ២២៣ |
| ៤០៧ | ៨៨៩៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២៣ |
| ៤០៨ | ៨៨៩៨ | Sun Saran | ស៊ុន សារ៉ន | ? | ? | ? | ២០៩ |
| ៤០៩ | ៨៩០០ | Men Sinavuth alias Sruoch | ម៉ែន ស៊ីណាវុធ ហៅ ស្រួច | ? | ២០ឆ្នាំ | ១៣/០៣/១៩៨៨ | ២២៤ |
| ៤១០ | ៨៩០៣ | Thie? | ធៀ? | ? | ៣៧ឆ្នាំ | ១៣/០៣/១៩៨៩ | ២២៤ |
| ៤១១ | ៨៩១៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២៧ |
| ៤១២ | ៨៩១៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ២២៤ |
| ៤១៣ | ៨៩២១ | Seng Sen | សេង សេន | ? | ១៤ខែ | | ២២៤ |

(នៅមានត)



ផ្លូវភ្នំនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ (រូបថត៖ បណ្ណសារដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា)


**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

**A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 232, April 2019 ◆ Funded by USAID**
**Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.**